ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Nov-2016, 14:13
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៤៤៦**

ចៅក្រមសាលាដំបូង៖

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

ក្រឡាបញ្ជីសាលាដំបូង៖

លោកស្រី សែ កុលវុឌ្ឍី

លោកស្រី ស្តាវ្រូឡា ប៉ាប៉ាដូពូឡូស
*(Ms.Stavoroula PAPADOPOULOS)*

ការិយាល័យសហព្រះរាជអាជ្ញា៖

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

ជនជាប់ចោទ៖

លោក នួន ជា

លោក ខៀវ សំផន

មេធាវីការពារជនជាប់ចោទ នួន ជា៖

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ស្រ៊ា រតនះ | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សេង សឿន (2-TCCP-219) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ÷ លោក សេង សឿន** (2-TCCP-219)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៦

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........ ទំព័រ ៨

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........ ទំព័រ ២២

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ៥២

សួរដោយលោក លីវ សុវណ្ណា ផ្ដើមពី ........ ទំព័រ ៥៥

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........ ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា លោកប្រធាន និល ណុន នឹងបន្តអវត្តមានពីកិច្ចដំណើរការនីតិវិធីសវនាការ ដោយសារតែមូលហេតុសុខភាព។ អង្គជំនុំជម្រះមិនទាន់ដឹងច្បាស់ថា តើពេលណាលោកប្រធាន និល ណុន នឹងអាចវិលត្រឡប់មកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការនោះទេ ប៉ុន្តែអង្គជំនុំជម្រះនឹងផ្តល់ព័ត៌មានបន្ថែមទៀតដល់ភាគី នៅពេលដែលអង្គជំនុំជម្រះទទួលបានព័ត៌មានថ្មី។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-219។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

[០៩:០១:១៥]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-219 ហើយដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-286។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូង អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០២:៥៦]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈវិលមុខពេលងើបឈរ ហើយពេលអង្គុយឈឺចង្កេះ និងឈឺខ្នង និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តមុននឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-219 អង្គជំនុំជម្រះមានបំណងស្ដាប់សារណាផ្ទាល់មាត់របស់ភាគីនានា ទាក់ទងនឹងការប្រើប្រាស់សវនាការជាអសាធារណៈ

នៅក្នុងដំណើរការនៃការធ្វើសក្ខីកម្មរបស់សាក្សី -- របស់ដើមបណ្តឹងរដ្ឋប្បវេណី 2-1002។ ហើយដោយដើមបណ្តឹងរូបនេះត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ស្ថិតនៅក្រុម “គ” ដែលស្តាប់សក្ខីកម្ម គួរធ្វើនៅក្នុងសវនាការជាអសាធារណៈ។ ហេតុដូច្នេះអង្គជំនុំជម្រះមានបំណងស្តាប់មតិយោបល់ភាគីពាក់ព័ន្ធ នឹងដំណើរការនៃការធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ថាតើគួរធ្វើនៅក្នុងសវនាការជាសាធារណៈ ឬអសាធារណៈ។ ជាដំបូង អង្គជំនុំជម្រះសុំប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីលើកឡើងពីមតិយោបល់របស់ខ្លួន។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

[០៩:០៥:២៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ សហព្រះរាជអាជ្ញា មិនមានការជំទាស់ទៅអ្វីចំពោះការធ្វើចំណាត់ថ្នាក់សាក្សីរូបនេះទេ។ តាមពិតសាក្សីនេះ<> ជាសាក្សីផ្តល់បទសម្គាសន៍នៅក្នុងរឿងក្តីផ្សេង។ <ហើយជាសាក្សីសំខាន់> ស្ថិតនៅក្នុងដំណើរការនៃការស៊ើបអង្កេតនៅឡើយ ដូច្នេះហើយយើង<យល់ពីការធ្វើចំណាត់ថ្នាក់ក្នុងករណីនេះហើយយើង>មិនមានជំទាស់អ្វីទៅនឹង<សំណើសុំឲ្យសាក្សីផ្តល់សក្ខីកម្មជាអសាធារណៈ>នេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំគោរពទៅតាមការសម្រេចទាំងស្រុងទៅលើអង្គជំនុំជម្រះ។ ខ្ញុំអត់មានការកត់សម្គាល់អ្វីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[០៩:០៦:៣៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំគ្មានសេចក្តីសង្កេតអ្វីទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំអត់មានការជំទាស់អ្វីទេ គ្រាន់តែខ្ញុំសូមរំឭកថា ធ្វើយ៉ាងម៉េចឲ្យមានតម្លាភាពឲ្យបានខ្ពស់បំផុត។ ហើយខ្ញុំដឹងថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គាត់មានមេធាវីហើយ ហើយខ្ញុំគិតថា បើមានបញ្ហាអ្វីនោះ គឺមេធាវីគាត់អាចនឹងជួយគាត់បាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមអរគុណភាគីដែលបានផ្ដល់ – សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យប្រាកដនៅក្នុងកំណត់ត្រាតុលាការ ប្រហែលជាមានការភ័ន្តច្រឡំរបស់មេធាវី ខៀវ សំផន គឺថាសាក្សីដែលយើងនិយាយហ្នឹង គឺជាសាក្សីទី៤ <-- សាក្សីទី៣ ឬ សាក្សីទី៤> ដែលយើងនឹងស្ដាប់សវនាការនៅអាទិត្យនេះគឺ 2-TCW-1002 មិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ <គឺគ្រាន់តែជាសាក្សី>។ ដូច្នេះ<ខ្ញុំមិនច្បាស់ថា តើ>មេធាវី ខៀវ សំផន <>គាត់<កំពុងតែនិយាយពីបុគ្គលដែលយើងកំពុងតែនិយាយនេះដែរឬយ៉ាងណានោះទេ>។

[០៩:០៨:០០]

**កញ្ញា អង់តា ហ្គីសសេះ**

ពិតហើយ គឺខ្ញុំច្រឡំមែន។ ខ្ញុំច្រឡំរហស្សនាមគាត់ អ៊ីចឹងខ្ញុំនៅតែមានមតិកត់សម្គាល់ដដែល ពាក់ព័ន្ធនឹងភាពចាំបាច់នៃតម្លាភាពនៃសវនាការ។ <ហើយខ្ញុំនឹងគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ។>

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមអរគុណភាគីដែលបានផ្ដល់មតិយោបល់លើបញ្ហានេះ។ ហើយអង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីឲ្យបានឆាប់ ពាក់ព័ន្ធនឹងដំណើរការនៃការរៀបចំស្ដាប់សក្ខីកម្មសាក្សីរូបនេះ។ អង្គជំនុំជម្រះ ក៏សូមជម្រាបដល់ភាគី និងសាធារណជនផងដែរថា អង្គជំនុំជម្រះបានទទួលព័ត៌មានពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា សាក្សី 2-TC-1002 មានបញ្ហាសុខភាព ដែលមិនអាចស្ដាប់សក្ខី

កម្មរបស់គាត់នៅថ្ងៃព្រហស្បតិ៍ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ដូចការគ្រោងទុកនោះទេ។ ហេតុដូច្នេះអង្គជំនុំជម្រះនឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីរូបនេះនៅថ្ងៃចន្ទ ទី០៥ ខែកញ្ញា ឆ្នាំ២០១៦វិញ។ ដូច្នេះសូមភាគី និងសាធារណជនជ្រាប។

ជាបន្តទៅនេះ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់ លើសំណើសុំឱ្យទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តីលោក នួន ជា បានដាក់សំណើជាលាយលក្ខណ៍អក្សរតាមវិធាន៨៧(៤) នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ សូមឱ្យទទួលយកឯកសារចំនួនបួន ធ្វើជាឯកសារភស្តុតាង (ឯកសារ E430)។ ឯកសារចំនួនពីរ ក្នុងចំណោមឯកសារទាំងនេះ ត្រូវបានទទួលយកតាមរយៈសេចក្តីសម្រេចផ្ទាល់មាត់ចេញនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦។

[០៩:០៩:៥១]

នាពេលនេះ អង្គជំនុំជម្រះសូមលើកយកមកដោះស្រាយផ្នែកផ្សេងទៀតនៃសំណើសុំដែលមេធាវីការពារក្តីលោក នួន ជា ស្នើសុំឱ្យទទួលយកសេចក្តីដកស្រង់ចេញពីឯកសារ E319/45.4.8 ដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលេខសម្គាល់ 2-TCCP-286 ដែលត្រូវបានកំណត់ឱ្យមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែក។ ទោះបីជាឯកសារ E430 យោងទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-28 ក៏ដោយ។ តែព័ត៌មានផ្សេងទៀតនៅក្នុងសំណើសុំនេះបង្ហាញច្បាស់ថា មេធាវីការពារក្តីមានបំណងយោងទៅដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-286។ អង្គជំនុំជម្រះកត់សម្គាល់ថា ផ្នែកមួយនៃឯកសារ E319/45.4.8 ដែលបានស្នើសុំមាននៅក្នុងឯកសារ E3/5010 ដែលត្រូវបានទទួលយកធ្វើជាឯកសារភស្តុតាងរួចហើយ ដែលឯកសារនោះក៏ជាពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-286 ដែរ។ សេចក្តីដកស្រង់ដែលមេធាវីការពារក្តី លោក នួន ជា ស្នើសុំឱ្យទទួលយកគឺជាផ្នែកបន្ថែមនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើង។

អង្គជំនុំជម្រះកត់សម្គាល់ថា មានកំហុសឆ្គងចំពោះលេខ ERN មួយចំនួនដែលបានលើកឡើងក្នុងសំណើសុំនេះ។ ហេតុដូច្នេះ ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសូមសំអាងទៅលើសេចក្តីដកស្រង់ដែលមានភ្ជាប់មកជាមួយនឹងឯកសាររបស់មេធាវីការពារក្តីជំនួសវិញ។

[០៩:១១:៤៨]

អង្គជំនុំជម្រះសាលាដំបូងសូមរំឭកដល់ការអនុវត្តរបស់ខ្លួន ក្នុងការទទួលយកចម្លើយពីមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះធ្វើជាឯកសារភស្តុតាង អនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង។ វាជាប្រយោជន៍ក្នុងការស្វែងរកការពិត ដែលថាអង្គជំនុំជម្រះនិងភាគីអាចចូលពិនិត្យមើលចម្លើយទាំងអស់របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២។ ហេតុនេះអង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់មេធាវីការពារក្តី លោក នួន ជា ដែលស្នើសុំឲ្យទទួលយកសេចក្តីដកស្រង់ដែលបានស្នើសុំពីឯកសារ E319/45.4.11 ដែលមាននៅក្នុងឯកសារ E430.2 និងឯកសារ E430.4 ធ្វើជាឯកសារភស្តុតាង។ អង្គជំនុំជម្រះដាក់លេខសម្គាល់ E3/5010b សម្រាប់សេចក្តីដកស្រង់ទាំងអស់នេះ។

ជាបន្តទៅនេះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-219 មកកាន់កន្លែងផ្តល់សក្ខីកម្មចំពោះអង្គជំនុំជម្រះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកឈ្មោះអីដែរ?

**លោក សេង សឿន៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[០៩:១៤:៥៣]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនដំណើរការ ហើយចេញភ្លើងក្រហម ចាំលោកឆ្លើយ។ សូមលោកឆ្លើយម្តងទៀត។ សូមអញ្ជើញឆ្លើយ! សូមលោកៗដើមបណ្តឹងរដ្ឋប្បវេណី សូមលោកឆ្លើយម្តងទៀត ហើយនៅពេលដែលមីក្រូហ្វូនដំណើរការ ចេញភ្លើងពណ៌ក្រហម។

លោកដើមបណ្តឹងរដ្ឋប្បវេណី លោកឈ្មោះអី?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** សូមលោកឆ្លើយម្តងទៀត ព្រោះពេលលោកឆ្លើយអម្បាញ់មិញនេះ មីក្រូហ្វូនមិនទាន់ដំណើរការ ចេញភ្លើងក្រហមទេ។ តើលោកដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះអី?

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ សេង សឿន។

**ស៖** តើលោកកើតនៅថ្ងៃខែឆ្នាំណាដែរ? ហើយនៅកន្លែងណា?

**ឆ៖** ខ្ញុំបាទឆ្នាំកំណើត១៩៥៦។ ភូមិកំណើតភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** តើបច្ចុប្បន្នលោករស់នៅទីណាដែរ?

**ឆ៖** បច្ចុប្បន្ន ខ្ញុំបាទរស់នៅភូមិខ្សាច់ទប់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ -- អឺ!ច្រឡំ ភូមិខ្សាច់ទប់ ឃុំជ្រោយបន្ទាយ ស្រុក១ ខេត្តក្រចេះនេះ។

**ស៖** អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ តើសព្វថ្ងៃលោកប្រកបមុខរបរធ្វើអីដែរ?

**ឆ៖** ខ្ញុំបាទបច្ចុប្បន្នចូលនិវត្តន៍ខាងកងទ័ព។

[០៩:១៨:០៩]

**ស៖** តើឪពុកម្តាយលោកឈ្មោះអីដែរ?

**ឆ៖** ម្តាយខ្ញុំឈ្មោះ ដួង យុន នៅភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។ ស្លាប់អស់ហើយ។

**ស៖** តើប្រពន្ធលោកឈ្មោះអី? ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សុខ ចាន់នី នៅភូមិខ្សាច់ទប់ ឃុំជ្រោយបន្ទាយ ស្រុក -- ខេត្តតាកែវ។

**ស៖** អរគុណដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះកោះអញ្ជើញលោកមកផ្តល់សក្ខីកម្មថ្ងៃនេះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះនៅចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោក លោកអាចមានសិទ្ធិធ្វើសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម មានន័យថា ផលអន្តរាយដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើមាន ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបានធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណាខ្លះ? លោកចាំទេ?

**ឆ៖** ខ្ញុំបាទ មិនបានចាំទេ តែបានជួបនឹងលោកមេធាវី ហើយបានជួបហ្នឹងក៏បានច្រើនដង មិនដែលបានកំណត់ថាប៉ុន្មានដង ប៉ុន្មានដង អត់ច្បាស់ អត់ចាំដែរ។

[០៩:២០:១៤]

**ស៖** អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំ

ជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអានទូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនជាមួយអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ឥឡូវនេះ ខ្ញុំបាទមិនឃើញ -- បានឃើញ តែមិនអាចនិយាយ ឬអានសៀវភៅដែលខ្ញុំបានកត់ត្រាជូនលោកមេធាវីបានទេ ព្រោះក្រោយពីខ្ញុំមានជំងឺបាត់បង់ស្មារតីអស់៣យប់៣ថ្ងៃទៅ មកជាមនុស្សវិញ ភ្លេចអស់រលីង។ ទាល់តែមេធាវីហ្នឹងមកនាំរំឭកទៅ ខ្ញុំឃើញដឹងខ្លះ ដល់គាត់និយាយទៅបានខ្ញុំបាទដឹង។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នា ទៅនឹងសក្ខីកម្មដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីមុនដែរឬទេ?

**ឆ៖** បាទ រឿងនេះ ជារឿងពិត ដែលខ្ញុំបានពិនិត្យមើល ហើយដែលខ្ញុំបានជូនព័ត៌មានកន្លងមកនេះ គឺពិត អត់មានក្លែងក្លាយទេ គឺខ្ញុំបាននិយាយពិតពីរបស់ខ្ញុំ ដែលកត់ត្រាហ្នឹងកត់បានពិតប្រាកដ អត់ក្លែងក្លាយដែរ។

[០៩:២២:០៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អនុវត្តតាមបញ្ញត្តិ៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរដេញដោលដើមបណ្តឹងរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហមេធាវីនាំមុខ រួមជាមួយតំណាងសហព្រះរាជអាជ្ញា មានរយៈពេលបីវគ្គសវនាការ។

សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចោទសំណួរមួយចំនួនព្រឹកនេះ ជាពិសេស

ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបន្ទាប់មកទៀត ខ្ញុំនឹងផ្ដល់វេទិកាទៅសហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែមុននឹងចោទសំណួរទៅលោក ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍នៅរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសូមឲ្យលោកពន្យល់ទៅអង្គជំនុំជម្រះអំពីអ្វីដែលលោកបានធ្វើនៅចន្លោះពេលដែលលោកចូលបដិវត្តន៍ និងពេលរបបនេះបានរលត់ផុតទៅ។ សំណួរទី១របស់ខ្ញុំ គឺថាតើលោកបានចូលបដិវត្តន៍ហ្នឹងដែរឬទេ? ហើយបើបានចូលវិញ ចូលនៅពេលណាដែរ?

[០៩:២៣:៤៩]

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំមិនដឹងថា ថាម៉េចទេ។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី យល់សំណួរទេ?

សូមអញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សួរតាំងសំណួរសាជាថ្មី។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ខ្ញុំនឹងសួរសំណួរឲ្យស្រួលៗ។ តើលោកបានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ហើយបើបានចូលរួមនុ៎ង តើចូលរួមនៅឆ្នាំណាដែរ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំ កាលនោះគេហៅថា ចូលជួរឆ្នាំ៧០ សម័យនោះគេហៅសម័យប្រជាជាតិ ប្រជាធិប-តេយ្យ។ តែខ្ញុំចូលជួរហ្នឹង គ្រូបង្រៀនខ្ញុំមុន៧០ គាត់នាំខ្ញុំយកមកចូល គេហៅបង្កើតសិល្បៈតំបន់១៣ គឺលោកគ្រូខ្ញុំឈ្មោះគាត់ ខៀវ វ៉ាន់ហាន ថ្ងៃខែ១០ ឆ្នាំ៧០។ ខ្ញុំមិនទាន់បានចូលជាស.យុវកក ឬក៏បក្ខជននៅឡើយទេពេលនោះ។ រហូតបម្រើនៅសិល្បៈតំបន់១៣ហ្នឹង ដល់ខែ ថ្ងៃ១០ ខែ១ -- ៧២ បានខ្ញុំចេញពីសិល្បៈមកកងទ័ព។ ពេលនោះបានដើរតួនាទីពីដើមទី គឺធ្វើមេក្រុមក្នុងកងទ័ព។ រួចមកបានធ្វើបញ្ជាការកងអនុសេនាតូច។ ពេលនោះខ្ញុំបានចូល គេហៅថាក្រុមមិនទាន់បក្ខជនទេ ស.យុវកក។ រួចមកបានខ្ញុំគេបញ្ចូលស.យុវកក ហើយបន្ទាប់មកទៀតទៅបញ្ចូលជាបក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជា។ បានឡើងតួនាទីកងទ័ពជាបញ្ជាការកងអនុសេនាធំ រហូតក៏១៧ មេសា បែកភ្នំពេញក្រោយមក បានខ្ញុំត្រូវរបួសពិការ វែនៅព្រំដែនខ្មែរ-វៀតណាមត្រឹមហ្នឹង។

[០៩:២៦:៣១]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** ខ្ញុំសូមអរគុណ។ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះ ថាតើលោកបានទៅណាក្រោយពីរបួសនៅលើសមរភូមិហើយ ក្រោយពីរំដោះបានភ្នំពេញហើយនេះ លោកទៅណាដែរ?

**ឆ៖** ពេលខ្ញុំបម្រើហ្នឹងរហូតមក ១៧ មេសា យួនវៃចូលស្រុកខ្មែរទៅ ខ្ញុំឡើងដល់ភ្នំដងរែកហើយបានរៀបចំចុះមកវិញ មុខសញ្ញារបស់ខ្ញុំខេត្តក្រចេះ ក្រោមការរៀបចំរបស់អ្នកដឹកនាំសំខាន់ ពេលនោះនៅព្រំដែនភ្នំដងរែកហ្នឹង គឺមាន បងខៀវ ហៅ សុន សេន ហើយនិង តាម៉ុក គាត់អ្នកទៅចាត់តាំងកន្លែងឲ្យចុះធ្វើសកម្មភាពតវ៉ាវិញ ដើម្បីលុបលាងកំហុសមេដឹកនាំខ្មែរក្រហមកន្លងមក។ អ៊ីចឹងក៏នៅបម្រើហ្នឹងរហូតៗ ច្របាច់បញ្ចូលខ្ញុំជាមួយកងទ័ព ជាមួយរដ្ឋាភិបាលទាល់ថ្ងៃហ្នឹងទៅ ខ្ញុំពិការចូលនិវត្តន៍ហើយហ្នឹង។

**ស៖** ក្រោយពីរបួសនៅសមរភូមិនៅឆ្នាំ១៩៧៥ហើយនោះ តើលោកបានទៅណាដែរ? <យើងកំពុងនិយាយពី>ឆ្នាំ១៩៧៥ <>គឺថាបន្ទាប់ពីលោករបួសហើយនោះ នៅសមរភូមិនោះលោកបានទៅណាដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនប្រតិបត្តិការសិន ចេញភ្លើងក្រហមចាំឆ្លើយ។

[០៩:២៨:៣៩]

**លោក សេង សឿន៖**

**ឆ៖** បាទ សូមបន្ត ខ្ញុំក្រោយពីរបួសហ្នឹង ខ្ញុំទៅមន្ទីរពិការតំបន់១៣ ក្រោយមកទៀតគេផ្លាស់ខ្ញុំចេញ ជនពិការទាំងអស់ប្រមូលមកដាក់ភូមិភាគនិរតីទៅនៅជិតភ្នំពេញ។ រួចពីហ្នឹងមកបានដកខ្ញុំចេញពីមន្ទីរពិការភូមិភាគនិរតីនៅតាខ្មៅហ្នឹង ក៏មកនៅស្រុកស្អាង នៅធ្វើការងាររដ្ឋបាល ធ្វើជាមន្ទីរស្រុករបស់ស្រុកស្អាង។ រួចពីតមក បានផ្លាស់ខ្ញុំឲ្យទៅក្រចេះ មិនបានពេញមួយខែទេ ដែលយួនវៃចូលស្រុកខ្មែរនេះក៏ឡើងភ្នំដងរែកត្រឹមហ្នឹងទៅ។

**ស៖** ខ្ញុំសូមអរគុណ។ លោកទើបតែនឹងនិយាយថា ក្រោយពីរបួសហើយហ្នឹង គឺលោកត្រូវបានបញ្ជូនទៅអង្គភាពពិការ។ តើលោកអាចជម្រាបជូនតុលាការបានដែរទេថា មន្ទីរយោធាពិការនេះនៅកន្លែងណាដែរ? ហើយលោកទៅនៅទីនោះអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំមិនអាចចាំបានទេរឿងទីកន្លែង ថ្ងៃ ពេល។ ដឹងតែតំបន់ពិការរបស់តំបន់តាកែវ តំបន់

១៣នេះ វាម្តុំធន់មន់អាម៉េចទេ ខ្ញុំភ្លេចបាត់ហើយ។ រួចចេញពីហ្នឹងទៅបានទៅមន្ទីរពិការភូមិភាគនិរតី ហើយជិតភ្នំពេញ ម្តុំតាខ្មៅនោះ។ បាទ ផ្លាស់ខ្ញុំចេញទៅអ៊ីចឹងទៅ។

**ស៖** ខ្ញុំសូមអរគុណ។ ឥឡូវខ្ញុំសូមអានចម្លើយរបស់លោកដែលលោកបានផ្តល់ទៅឱ្យអ្នកស៊ើបអង្កេតនៅពេលដែលគាត់សួរសំណួរទៅលោក កាលពីឆ្នាំ២០០៩។ គឺឯកសារ E3/409 នៅចម្លើយទី៦ ហើយជាគ្រប់ភាសាទាំងអស់។ អ្នកស៊ើបអង្កេតសួរលោកដូចតទៅនេះថា៖ "តើមានរឿងអ្វីកើតឡើងខ្លះ បន្ទាប់ពីលោកបានចេញពីមន្ទីរពេទ្យ? ហើយលោកឆ្លើយថា៖ គេបានបញ្ជូនខ្ញុំទៅមន្ទីរយុវជនពិការតំបន់១៣ ខេត្តតាកែវដែលស្ថិតក្នុងភូមិធន់មន់ ឃុំបារាយណ៍ ស្រុកទ្រាំង ខេត្តតាកែវ។" លោកដើមបណ្តឹងរដ្ឋប្បវេណី តើចម្លើយនេះវាស៊ីក្នុងនឹងការចងចាំរបស់លោកដែរឬទេ? គឺនៅមន្ទីរយុវជនពិការតំបន់១៣នេះ ហើយ ឬក៏យ៉ាងម៉េច?

[០៩:៣២:០០]

**ឆ៖** ខ្ញុំទៅតើ ធន់មន់នេះ។

**ស៖** អម្បាញ់មិញនេះលោកបានឆ្លើយថា យុទ្ធជនពិការទាំងអស់ហ្នឹងត្រូវបានប្រមូលផ្តុំមកជិតភ្នំពេញ។ អ៊ីចឹងខ្ញុំសូមអានចម្លើយមួយទៀតដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតដែរ គឺឯកសារ E3/409 ចម្លើយទី១១ នៅគ្រប់ភាសាទាំងអស់។ អ្នកស៊ើបអង្កេតសួរលោកដូចតទៅនេះ៖ "តើលោករស់នៅមន្ទីរយុវជនពិការហ្នឹង<រយៈ>ពេល<ប៉ុន្មាន>ដែរ? លោកឆ្លើយ៖ ខ្ញុំមិនចាំទេ ព្រោះខ្ញុំត្រូវបានគេផ្លាស់ពីកន្លែងមួយទៅកន្លែងមួយជាច្រើនដង ប៉ុន្តែខ្ញុំគិតថាខ្ញុំបានចាកចេញពីមន្ទីរយុវជនពិការនោះ នៅឆ្នាំ១៩៧៧។ បន្ទាប់មកទៀត គេបញ្ជូនខ្ញុំទៅមន្ទីរយុវជនពិការភូមិភាគនៅតាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។" តើព័ត៌មានដែលខ្ញុំអាចជូននេះ ធ្វើឱ្យលោកនឹកឃើញវិញទេអំពីទីកន្លែងមន្ទីរយុវជនពិការនោះ លោកនឹកឃើញវិញទេ ខ្ញុំអានជូនលោកស្តាប់អ៊ីចឹងទៅ?

**ឆ៖** បាទៗ ត្រូវហើយខ្ញុំនឹកចាំហើយ អត់ខុសទេ។

**ស៖** តើអង្កាល់នោះ លោកមានមុខងារអ្វីដែរកាលដែលលោកនៅមន្ទីរយុទ្ធជនពិការនៅខេត្តតាកែវនោះ? នៅមន្ទីរទី១ដែលគេបញ្ជូនឱ្យលោកទៅធ្វើការនោះ ក្រោយពីពេលលោករបួសនៅសមរភូមិ ហើយនុ៎ង លោកទៅដល់មន្ទីរយុទ្ធជនពិការនៅតាកែវហ្នឹង លោកមានមុខងារអីដែរនៅទីនោះ?

[០៩:៣៤:០៩]

**ឆ៖** ខ្ញុំទៅនៅមន្ទីរពិការតំបន់១៣ហ្នឹង ខ្ញុំបានគេឱ្យមុខតំណែងជាអនុប្រធានមន្ទីរពិការតំបន់

១៣។

**ស៖** តើលោកអាចពន្យល់ជូនតុលាការបានដែរឬទេ ថាអ្នកណាជាអ្នកដែលបញ្ជូនលោកហ្នឹងទៅ? អ៊ីចឹងខ្ញុំសួរលោកថា តើអ្នកពិការទាំងអស់នុ៎ងៗជាអ្នកណាដែរ? ហើយគេបញ្ជូនគាត់ទៅមន្ទីរហ្នឹងប្រភេទមនុស្សយ៉ាងម៉េចបានគេ ទាល់តែប្រភេទមនុស្សបែបម៉េចដែរដែលគេបញ្ជូនទៅកន្លែងហ្នឹងៗ?

**ឆ៖** គេបញ្ជូនទៅនៅកន្លែងមន្ទីររស់នៅខាងមន្ទីរពិការហ្នឹង គឺកងទ័ពដែលធ្វើកងទ័ព ហើយវាយច្បាំងគ្នាហ្នឹង សម័យលន់នល់ហ្នឹង ត្រូវរបួស ហើយពិការហ្នឹង បានគេហៅថាជនពិការ មិនមែនពិការដោយផ្សេងទេ គឺត្រូវៗរបួស ត្រូវគ្រាប់ ទៅនៅកន្លែងមន្ទីរពិការហ្នឹង។

**ស៖** តើមានយុទ្ធជនដែលមានបញ្ហាពិការភ្នែកអីអ៊ីចឹង គាត់មើលមិនសូវច្បាស់ហ្នឹង គេបញ្ជូនទៅនុ៎ងដែរទេ?

**ឆ៖** ពាក្យថា "ពិការ" ត្រឹមបាក់ជើង ឬក៏ដៃ ដើរលែងកើតដោយសាររបួស មិនបាច់ដល់ភ្នែកមើលមិនឃើញទេ អាហ្នឹងក៏រីតតែពិការធំទៀតហើយ អាហ្នឹងហៅថា "ពិការ"។

**ស៖** តើមានបុរស និងស្ត្រីរួមគ្នា ឬក៏នៅមន្ទីរជនពិការហ្នឹងមានតែបុរសទេ?

**ឆ៖** វាមានអ្នកដែលមានប្រពន្ធ ហើយពិការមកនៅកន្លែងខ្ញុំហ្នឹង អ្នកណាគេអត់មាន នៅលីវៗដូចខ្ញុំ ដូចអីហ្នឹង នៅៗ គ្រាន់ធ្វើផ្ទះ ធ្វើជាប់ៗគ្នាហ្នឹង អ្នកមានប្ដីប្រពន្ធ កូនហ្នឹង គេនៅប្ដីប្រពន្ធហ្នឹងក្បែរៗហ្នឹង នៅក្នុងជុំវិញមន្ទីរហ្នឹង កន្លែងហ្នឹងតែម្ដង។

[០៩:៣៧:៣៨]

**ស៖** តើយោធានៅលីវទាំងអស់នោះ មានត្រូវបានគេឲ្យរៀបការដែរឬទេ នៅមន្ទីរយុទ្ធជនពិការនោះ ពេលដែលលោកធ្វើការនៅទីនោះៗ? តើគេមានឲ្យជនពិការទាំងអស់នុ៎ងរៀបការទេ?

**ឆ៖** កាលនៅជាមួយខ្ញុំ អត់មានទេ អត់ទាន់រៀបការឲ្យអ្នកពិការទេ កាលខ្ញុំនៅមន្ទីរពិការភូមិភាគ អ៎!តំបន់១៣ហ្នឹង។ គេមានប្រពន្ធមានអីគេមុនមកស្រេចទេ មកនៅកន្លែងខ្ញុំ ដែលគេរៀបចំមកនៅជាមួយខ្ញុំ អត់ទាន់រៀបចំឲ្យមានការទេ។

**ស៖** ដើមបណ្ដឹងរដ្ឋប្បវេណី លោកបានឆ្លើយតបទៅនឹងសំណួរមួយចំនួន នៃមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ២០០៦។ នេះគឺជាឯកសារដែលធ្វើ១០ឆ្នាំកន្លងមកហើយ។ កាលនុ៎ងគេចោទសំណួរលោកទាក់ទងនឹងចំណុចជាក់លាក់មួយហ្នឹង គឺឯកសារ E3/5643, ERN ជាភាសាបារាំងគឺ 00756626, ជាភាសាអង់គ្លេសគឺ 00753878, ជាភាសាខ្មែរគឺ 00059380។ ខ្ញុំសូមឲ្យសហភាតារបស់ខ្ញុំ គឺ

លោក ពេជ អង្គ អានជាភាសាខ្មែរ ជាច្បាប់ដើមតែម្តង។ អានសំណួរដែលសួរទៅលោក ហើយនិងចម្លើយដែលលោកបានឆ្លើយ។ ហើយបន្ទាប់មកទៀត ខ្ញុំនឹងសូមឱ្យលោកឆ្លើយបញ្ជាក់លើចំណុចមួយចំនួន។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ខ្ញុំសូមអាន ដោយដកស្រង់ដូចតទៅ៖ "បូលី៖ ចេញឈ្មោះ សឿន ស្នងពុកហ្នឹង? សឿន៖ ក៏គេឱ្យមកនៅគ្រប់គ្រងយុវជនពិការតំបន់តាកែវ តំបន់១៣។ ដល់ពេលនេះគេប្រមូលអ្នកពិការមួយភូមិភាគនិរតីហ្នឹងមានខេត្តកណ្តាល ហៅតំបន់២៥, កំពង់ស្ពឺ ហៅតំបន់៣៣, តាកែវ១៣, កំពត៣៥។ គេប្រមូលមកដាក់នៅតាខ្មៅ មានដែលស្គាល់តាខ្មៅទេ ចាប់ព្រំពីអាស្ពានព្រែកហូរមកអីចេះ ពីអាព្រែកពេទ្យឆ្លួតមកអីចេះ មកផ្សារកំពង់សំណាញ់រោងចក្រកង់ឡានមកអីចេះ អាហ្នឹងគេឱ្យអ្នកពិការនៅហើយ។ ពេលដែលខ្ញុំមកដល់ហ្នឹង គេឱ្យខ្ញុំធ្វើប្រធានអនុកង -- ធ្វើប្រធានកងអនុសេនាធំ ក្តាប់១២០នាក់ គ្មានប្រធាន អនុប្រធានទេ។ វំលងមិនបាន៣ខែ គេចាប់អាប្រធានមន្ទីរហ្នឹងទៅ សុទ្ធតែជាប់ខ្សែក្បត់លិចកើត។ គេឱ្យតាមួយទៀតធ្វើប្រធានរោងចក្រសាប៊ូនៅជាប់ជ្រុងតាខ្មៅយើងនេះ។ តាហ្នឹងប្រធាន ខ្ញុំហ្នឹងអនុប្រធានវាអីចឹង។ ឡើងត្រួតត្រាហ្នឹង រៀបការឱ្យពួកអាអង្គុតដៃ អង្គុតជើងហ្នឹង យកប្រពន្ធយកអីទៅ យកកាលហ្នឹងមាននារីៗធ្វើចម្ការម្រេចនៅកំពត ទៅដឹកគេទាំងឡាន១យកមករៀបការឱ្យទៅ។" សូមចប់ សូមអរគុណលោកប្រធាន។

[០៩:៤២:២០]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី លោកបានស្តាប់ឮចម្លើយដែលលោកបានឆ្លើយនៅឆ្នាំ២០០៦ហើយ។ តើសព្វថ្ងៃនេះលោកនៅចាំពីស្ត្រីដែលគេនាំ<ពី>ចម្ការម្រេច ដើម្បីរៀបការជាមួយនឹងយោធាពិការនៅតាខ្មៅដែរឬទេ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំនៅចាំ ប៉ុន្តែគ្រាន់ខុសបន្តិច ពេលនោះមិនមែនខ្ញុំទេ។ ខ្ញុំទៅលេង គ្រាន់ដឹងថាពេលនោះមកនៅស្រុកស្អាងហើយ ដល់ខ្ញុំទៅលេងហ្នឹង តាប្រធានហ្នឹងគាត់ប្រាប់ខ្ញុំថា អញយកពួកអ្នកដែលយកប្តីប្រពន្ធហើយ ព្រោះយកស្រីៗពី ធ្វើគេចម្ការស្អីទេ! ភ្លេចហើយ ខ្ញុំភ្លេចតាហ្នឹង រួចឡានគេដឹកឱ្យមក

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រៀបការឲ្យ ឲ្យពួកហ្នឹង ខ្ញុំបាននៅចាំកន្លែងត្រង់ហ្នឹង។ ប៉ុន្តែគ្រាន់មិន ពេលនោះមិនមែនខ្ញុំអ្នកទៅរៀបការឲ្យជនពិការនៅភូមិភាគនិរតីហ្នឹងទេ។

**ស៖** តើនៅសម័យនោះលោកមានដឹងដែរឬទេ ថាហេតុអ្វីបានជាគេរៀបការឲ្យយុទ្ធជនពិការទាំងអស់ហ្នឹង?

**ឆ៖** ពេលនោះខ្ញុំក្រោមការដឹកនាំ ណែនាំប្រាប់មកថា "ពួកអស់ហ្នឹងគេចាស់ៗអស់ហើយ រកប្រពន្ធឲ្យវា"។ អាហ្នឹង តាម៉ុក គាត់បញ្ជាមក ហើយខ្ញុំស្តាប់បន្តគ្រាន់តែពីផ្ទាល់ទេ គឺវាមានប្រធានគេអ្នកផ្ទាល់ គាត់មកស្តាប់ឮអីចឹងៗមក អារឿងដែលរៀបការហ្នឹង ព្រោះឲ្យតែពិការ គឺរៀបការឲ្យទាំងអស់ អាហ្នឹងខ្ញុំស្តាប់ មិនដឹងគាត់បន្តគ្នាទេ។

[០៩:៤៤:៤៨]

**ស៖** នៅពេលដែលលោកនិយាយថា ជនពិការទាំងអស់ហ្នឹងចាស់ៗហើយនេះៗ តើលោកមាននៅចាំអាយុពួកគាត់ដែរឬទេ កាលនៅសម័យនោះហ្នឹងអាយុប៉ុន្មានដែរ?

**ឆ៖** ពេលនោះ មិនដឹងជាចង់សួរថាអាយុខ្ញុំ ឬក៏អ្នកជនពិការដែលត្រូវរៀបការទេនេះ?

**ស៖** ខ្ញុំសួរពីអាយុរបស់ជនពិការទាំងអស់ហ្នឹង ដែលយើងឲ្យគាត់រៀបការហ្នឹង គាត់អាយុប៉ុន្មានដែរ អង្កាល់នៅសម័យនុ៎ង?

**ឆ៖** កាលហ្នឹង វាត្រឹមអាយុច្រើនចាប់ពី២៥ រហូតដល់៣០ជាង នៅពិការដែលត្រូវរៀបការ គឺអាយុប៉ុណ្ណឹង។

**ស៖** តើលោកមានបានជួបយោធា ឬក៏ប្រពន្ធយោធាដែលមកពីចម្ការម្រេចកំពត<>ដែរឬទេ ក្រោយពីគាត់រៀបការហើយ<ពេលលោកទៅលេងនៅតាខ្មៅ>នោះ? នៅពេលដែលលោកទៅលេងនៅតាខ្មៅ តើលោកមានធ្លាប់ជួបយោធា ហើយនិងស្ត្រីទាំងអស់ហ្នឹង ដែលគេបានឲ្យរៀបការហ្នឹង? មានបានជួបពួកនុ៎ងទៀតទេ?

**ឆ៖** ខ្ញុំបានជួបខ្លះដែរ ប៉ុន្តែមិនបានសួរនាំទេ គ្រាន់តែទៅលេងឲ្យតែឃើញមុខ មិនដឹងសួរឈ្មោះអី អីណា នៅណាណី ក៏អត់បាននិយាយអីទេ បានតែប៉ុណ្ណឹង។

**ស៖** អម្បាញ់មិញនេះលោកបានឆ្លើយថា យុទ្ធជនមួយចំនួនហ្នឹងរស់នៅក្នុងមន្ទីរហ្នឹងជាគ្រួសារជាមួយប្រពន្ធ និងកូនរបស់ពួកគាត់។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា ប្រពន្ធរបស់គាត់ទាំងអស់ហ្នឹងជាអ្នកណា? ហើយគាត់ហ្នឹងជាយុទ្ធនារីដែរ ឬក៏ជាជនស៊ីវិលទេ? អ៊ីចឹងលោកអាច

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01355173



ជម្រាបជូនតុលាការបានដែរឬទេ ថាតើស្ត្រីដែលគេឲ្យរៀបការជាមួយយោធាទាំងអស់ហ្នឹងៗ គាត់ជាជនស៊ីវិល ឬក៏គាត់ជាយុទ្ធនារីដែរ?

[០៩:៤៧:៤៥]

**ឆៈ** រឿងនារីៗ ដែលយកមករៀបការសម័យនុ៎ង អត់មានទេ នៅសុទ្ធតែជានៅតាមភូមិ ហើយនិងយកនៅចម្ការម្រេចណោះទេ។ អត់មានអី នារីយោធាអីមករៀបការទេ អត់មានទេ។

**សៈ** ហើយចំពោះយោធាដែលរៀបការហើយនោះ អម្បាញ់មិញនេះ លោកបាននិយាយថាមានយោធាមួយចំនួននោះបានរៀបការហើយមានកូន ហើយរស់នៅជាមួយប្រពន្ធកូនគាត់ ហើយគឺនៅមន្ទីរជនពិការហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកថាតើលោកស្គាល់ប្រពន្ធពួកគាត់ទាំងអស់ហ្នឹងទេ? ហើយប្រពន្ធគាត់ហ្នឹងធ្វើអីដែរ?

**ឆៈ** ខ្ញុំមិនអាចស្គាល់ដឹងទាំងអស់ទេ ហើយមិនដឹងឈ្មោះអីផង វាគ្រាន់តែ ខ្ញុំគ្រាន់ធ្លាប់ស្គាល់កាលនៅមន្ទីរពិការតំបន់១៣ រហូតពិការ មន្ទីរពិការភូមិភាគនិរតីហ្នឹង ស្គាល់ គេមានប្រពន្ធនៅកំណើតរបស់គេ ហើយពេលហ្នឹងប្រមូលមកនៅទីមន្ទីរពិការ ជាអ្នកៗស្រែទេ នៅតាមភូមិ តាមឃុំរៀងខ្លួនទេ។ ដល់អ៊ីចឹងប្រមូលមកជួបជុំប្តីប្រពន្ធទៅ មកនៅកន្លែងអង្គភាព មកមន្ទីរពិការហ្នឹងទៅ។ ប៉ុន្តែខ្ញុំមិនដឹងឈ្មោះអីៗទេ ភ្លេចឈ្មោះអស់ហើយ ស្គាល់ដែរ ប៉ុន្តែស្គាល់មិនអស់សម័យនោះ។

**សៈ** សូមអរគុណ។ អម្បាញ់មិញនេះលោកបានឆ្លើយថា ក្រោយមកលោកត្រូវបានគេបញ្ជូនទៅស្រុកស្អាង។ តើនៅស្រុកស្អាងហ្នឹង លោកមានមុខងារអ្វីដែរ លោកធ្វើអីដែរនៅស្រុកស្អាងហ្នឹង?

[០៩:៥០:០៥]

**ឆៈ** នៅស្រុកស្អាង ខ្ញុំមានតួនាទី គេឲ្យធ្វើប្រធានមន្ទីរស្រុករបស់ស្រុកស្អាង ចាត់ចែងកិច្ចការរបស់ស្រុក ហៅថារបស់សាលាស្រុក។

**សៈ** តើលោកមានចាំដោយប្រហាក់ប្រហែល ថាតើលោកត្រូវបានបញ្ជូនទៅស្រុកស្អាងហ្នឹងនៅឆ្នាំណាដែរ? គ្រាន់តែប្រហាក់ប្រហែលក៏បានដែរ។

**ឆៈ** ខ្ញុំរកថាច្បាស់ ព្រោះខ្ញុំទៅនៅមន្ទីរពិការភូមិភាគហ្នឹង ក្រោយ១៧ មេសាហើយ មកនៅភ្នំពេញហើយ។ រហូតផ្លាស់ចេញពីហ្នឹង បានទៅនៅស្រុកស្អាងហ្នឹងទៀត ប៉ុន្តែខ្ញុំគ្រាន់តែចាំថា ខ្ញុំទៅនៅហើយ មិនដឹងបានប៉ុន្មានឆ្នាំទេ ស្រាប់តែត្រូវផ្លាស់ខ្ញុំចេញពីស្រុកស្អាងមកក្រចេះ ហើយមកដល់ក្រចេះហ្នឹងបានតែ១ខែ ឬខ្វះ២ថ្ងៃទេ ប្រហែល១ខែ បានឃ្មួនចូលស្រុកហ្នឹងទៅ។ ហ្នឹងខ្ញុំនៅចាំប៉ុណ្ណឹង។

**សៈ** នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោកនៅឆ្នាំ២០០៩ គឺឯកសារដដែល E3/409នៅចម្លើយទី២៤ លោកឆ្លើយថាលោកបានទៅដល់ស្រុកស្អាងហ្នឹង គឺនៅខែមិថុនា ឆ្នាំ១៩៧៨។ តើលោកនឹកឃើញឡើងវិញទេ ថាលោកបានទៅដល់ស្រុកស្អាងហ្នឹង គឺនៅឆ្នាំ១៩៧៨ទេ?

**ធៈ** ពីពេលឥឡូវនេះទៀត ខ្ញុំលែងចាំអស់ទៅហើយ និយាយថ្ងៃខែដែលខ្ញុំទៅនៅនេះ។ គេផ្លាស់ទៅនេះ ពីកន្លែងមួយទៅកន្លែងមួយ អត់ចាំទាំងអស់។

**សៈ** នៅពេលដែលលោកធ្វើជាប្រធានមន្ទីរស្រុកស្អាង តើលោកធ្លាប់រៀបចំការឲ្យអ្នកណាទេ?

[០៩:៥៣:១៦]

**ធៈ** ហ្នឹងខ្ញុំបាន មិនមែនជាដឹងទេ តែខ្ញុំបានទទួលបញ្ជារបស់គណៈស្រុក គឺបង សៅ ផុន គាត់ជាគណៈស្រុក គាត់ចាត់តាំងឲ្យខ្ញុំយកប្រវត្តិរូបរបស់យុវជន និងរបស់នារីរបស់កងចល័តស្រុក ដើម្បីរៀបការ។ គិតទៅខ្ញុំធ្វើបានពីរសា ប៉ុន្តែមិនដឹងចាំណា ពេលណា ហើយភ្លេចចំនួនទៀត ប៉ុន្តែដឹងថា ក្នុងមួយរៀបការមួយសាអ៊ីចឹង ប្រហែលជា២០ទៅ៣០គូ។ ពេលនោះខ្ញុំបានជាដឹង បងផុន គាត់ធ្វើគណៈស្រុក គាត់ណែនាំឲ្យខ្ញុំថា ឲ្យមេកងចល័តទាំងប្រុសទាំងស្រីហ្នឹង យកប្រវត្តិរូបមក ហើយអ្នែងចាំធ្វើអ៊ីចេះ ផ្គុំស្រីនិងប្រុសនៅភូមិ នៅក្នុងឃុំជាមួយគ្នា ហើយអាយុ បើថា បើអាប្រុសបានអាយុ២៥ ឲ្យស្រីហ្នឹងប្អូន៣ទៅ៥ឆ្នាំ អាហ្នឹងផ្គុំយកទៅ ហើយដាក់យកមកអញ ឯកសារហ្នឹង។ ខ្ញុំបាន គិតទៅខ្ញុំធ្វើបានពីរសាហ្នឹង រួចខ្ញុំផ្លាស់ទៅក្រចេះទៅ ហ្នឹងដែលរៀបការ។

**សៈ** តើឈ្មោះដែលលោកសរសេរនៅក្នុងបញ្ជីទាំងអស់ហ្នឹង សុទ្ធតែមកពីកងចល័តមែនទេ?

**ធៈ** គឺប្រធានចល័តគេផ្នែកខាងបុរស ហើយនិងផ្នែកនារី យកប្រវត្តិរូបហ្នឹងមកឲ្យខ្ញុំគូ។

**សៈ** លោកអាចពន្យល់ជូនតុលាការបានទេថា តើលោកធ្វើយ៉ាងម៉េចដើម្បីផ្គូផ្គងប្រវត្តិរូបទាំងអស់ហ្នឹង? លោកមានលក្ខខណ្ឌអ្វីខ្លះដែលត្រូវគោរពតាម ដើម្បីយកប្រវត្តិរូបហ្នឹងមកផ្គូផ្គងចាប់គូគ្នានោះ?

**ធៈ** ខ្ញុំមិនដឹងថា យ៉ាងម៉េចទេ ព្រោះនេះជាផែនការរបស់គណៈស្រុកគាត់ដាក់កំណត់ឲ្យខ្ញុំធ្វើអ៊ីចឹង ព្រោះយកប្រវត្តិរូបទាំងសងខាង គឺខាងនារី ខាងយុវជនហ្នឹងឲ្យប្រធានកងចល័តគេជ្រើសមកអាយុណាដែលត្រូវរៀបការ ទាំងស្រី ទាំងប្រុស។ អ៊ីចឹងខ្ញុំធ្វើតាមផែនការរបស់បញ្ជាសាលាស្រុក អ៎នែ! គណៈស្រុកទេ មិនមែនខ្ញុំអ្នកទៅប្រមែប្រមូលខ្លួនឯងឯណា។

[០៩:៥៦:៥៨]

**ស៖** តើលោកដឹងថា គណៈស្រុកទទួលបញ្ជាពីខាងណាទេ? អម្បាញ់មិញនេះលោកនិយាយអំពី តាម៉ុក ដែលចេញគោលការណ៍ណែនាំទៅយុទ្ធជនពិការ។ អ៊ីចឹងតើ តាម៉ុក ហ្នឹងគាត់មានបានចេញសេចក្ដីណែនាំ ឬក៏ចេញបញ្ជាប្រហាក់ប្រហែលគ្នាហ្នឹងទៅកងចល័តទេ?

**ឆ៖** រឿង តាម៉ុក ហ្នឹងគាត់មានមកអី *(ឮមិនច្បាស់)* ប្រាប់ពួកខាងក្រោមនេះទេ គ្រាន់តែបញ្ជាទៅគណៈតំបន់ទេ ហើយគណៈតំបន់ទទួលផែនការមកៗស្រុក អ៊ីចឹងស្រុកត្រូវអនុវត្តតាមផែនការឲ្យរៀបការ ព្រោះយុវជន នារី ឥឡូវហ្នឹងវាចាស់ៗច្រើនហើយ ទៅរៀបការឲ្យគេ។ ហើយកុំឲ្យនៅច្រើនពេក ឲ្យ ដូចថាឲ្យទៅតាមផែនការរបស់គាត់ គឺធ្វើបន្តបន្ទាប់ មិនមែនគឺ ថាថ្ងៃហ្នឹងភ្លាមឯណាទេ ច្រើនតែធ្វើបន្តបន្ទាប់មក រៀបការឲ្យគេ កុំឲ្យនៅគេចាស់អស់។ អាហ្នឹងជាផែនការវាបន្តបន្ទាប់គ្នាអ៊ីចឹង។

**ស៖** ក្រោយពីលោកធ្វើការផ្គូផ្គងប្រវត្តិរូបរួចហើយ រៀបចំបញ្ជីហើយហ្នឹង តើលោកត្រូវធ្វើអ្វីទៀតបន្ទាប់មកទៀត? តើសាមីខ្លួនហ្នឹងគាត់ដឹងដោយរបៀបណា ថាខ្លួននឹងត្រូវរៀបការនៅពេលណានោះ?

**ឆ៖** ខ្ញុំគ្រាន់គិតក្នុងចិត្តទេ សាមីខ្លួនដែលត្រូវរៀបការយុវជន យុវនារីទាំងអស់ហ្នឹង គ្មានដឹងខ្លួនអីទេ ស្រេចលើប្រធានទេ គេជិតដល់ថ្ងៃហ្នឹងហើយ គេហៅទៅ ឈ្មោះនេះឈ្មោះនោះមកនៅជួបជុំនៅមន្ទីរស្រុក។ រហូតដល់ -- អាហ្នឹងបើនិយាយអ៊ីចឹងថា គ្មានដឹងខ្លួនទេ ទាំងប្រុសទាំងស្រី ស្រាប់តែដល់ថ្ងៃហ្នឹងគេហៅ ក្រែងទៅរៀនសូត្រ អីក៏ប្រជុំ ក៏មិនដឹងអីទេ ស្រាប់តែទៅដល់ល្មម។ នេះតាមខ្ញុំដឹង។

[០៩:៥៩:៤៨]

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកគឺឯកសារ E3/409 លោកបានឆ្លើយនៅចម្លើយទី៦៥។ ខ្ញុំនឹងអានចម្លើយលោកកាលពីនោះ ហើយនិងសូមប្រតិកម្មរបស់លោក។ លោកបានថា៖ “បុរស<ជាប្រជាជន>ថ្មី ត្រូវផ្គុំជាមួយនឹងស្ត្រីដែលមកពីប្រជាជនថ្មី ហើយប្រជាជនមូលដ្ឋាន ត្រូវផ្គុំជាមួយនឹងប្រជាជនមូលដ្ឋាន។” តើចម្លើយរបស់លោកកាលពីមុននេះ វាស្របគ្នាទៅនឹងគោលការណ៍ណែនាំដែលលោកបានទទួលពីគណៈស្រុកមែនទេ?

**ឆ៖** បាទៗ ហ្នឹងគឺពិតជារបស់ផែនការរបស់គណៈស្រុកដែលនាំណែប្រាប់ខ្ញុំថា អាថ្មីដាក់ដោយថ្មី មូលដ្ឋានចាត់តាមមូលដ្ឋាន។ អាហ្នឹងខ្ញុំនៅចាំច្បាស់ដែរ ក៏វាភ្លេចពីមុនទៅ ឥឡូវបាននឹកឃើញ។

**ស៖** តើលោកមានបានចូលរួមក្នុងពិធីរៀបការហ្នឹងទេ ពេលដែលលោកធ្វើបញ្ជីហើយនោះ?

**ឆ៖** ខ្ញុំបានចូលរួមទាំងពីរវគ្គដែលខ្ញុំអ្នកប្រមូលឯក -- ប្រវត្តិរូបហ្នឹង គឺគ្រាន់តែបានប្រគល់ឲ្យ

បងគណៈស្រុកទៅ ហើយខ្ញុំនៅអង្គុយចាំមើល ហើយគាត់នេះ ប្រកាសឈ្មោះ ឈ្មោះនេះនឹងគូនេះ ឲ្យក្រោកមើល។ ហើយគ្រាន់ បងផុន គណៈស្រុក គាត់បញ្ចប់ទៅ គាត់ប្រកាសថា គូណាក៏ដោយ បើខាងស្រីក៏ដោយ ខាងប្រុសក៏ដោយ បើមិនពេញចិត្ត ក្រោកចេញ។ បើថាត្រូវចិត្តហើយ នៅស្ងៀមធម្មតា។ ហ្នឹងខ្ញុំបានអង្គុយមើលតែប៉ុណ្ណឹង។ រួចខ្ញុំដើរមកហើយ គេ ការហ្នឹងគេធ្វើម៉េចទៀត ខ្ញុំអត់ដឹងដែរ។

**ស៖** ចុះពេលហ្នឹង តើមានអ្នកណាក្រោកចេញដូចដែលលោកនិយាយអម្បាញ់មិញហ្នឹងទេ? មានន័យថា មានអ្នកណាប្រកែកមិនព្រមរៀបការទេ?

**ឆ៖** ខ្ញុំ មុនខ្ញុំដើរចេញ ខ្ញុំឃើញចេញពីរបីគូ ខ្ញុំដើរចេញមកបណ្ដោយ ពេលនេះអត់នៅចាំមើលទេ ខ្លាចវាមានរឿងរ៉ាវអីទៀត ខ្ញុំខ្ជិលណាស់។ ប៉ុន្តែចេញ មានស្រី ភាគច្រើនប្រុសចេញ។ សាក្រោយមានស្រីចេញៗច្រើនជាង។ ហ្នឹងខ្ញុំបានតាមមើលទាំងពីរវគ្គហ្នឹង តែរួចពីហ្នឹងគេយកទៅណាទៅណើហ្នឹងខ្ញុំចប់ត្រឹមហ្នឹងហើយ លែងដឹង លែងដឹងអីទៀតហើយ។

[១០:០៣:២២]

**ស៖** ខ្ញុំសូមអានចម្លើយមួយចំនួនដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត កាលពីឆ្នាំ ២០០៩ គឺឯកសារ E3/409 គឺចម្លើយ៧១ ទៅដល់៧៣។ អ្នកស៊ើបអង្កេតសួរលោកដូចតទៅ ខ្ញុំសូមដកស្រង់៖ "តើពួកគេអាចបដិសេធមិនរៀបការបានទេ? លោកឆ្លើយថា៖ ពួកគេអាចបដិសេធបាន។ អ្នកស៊ើបអង្កេតក៏សួរលោកតទៅទៀតថា៖ តើគេតែងតែយល់ព្រមក្នុងការរៀបការនេះមែនទេ? លោកឆ្លើយតបទៅវិញ៖ អ្នកខ្លះអាចមិនសប្បាយចិត្ត ប៉ុន្តែអ្នកខ្លះសប្បាយចិត្ត ហើយអ្នកដែលមិនសប្បាយចិត្ត មិនហ៊ានបដិសេធឡើយ។ ហើយជាចុងក្រោយ អ្នកស៊ើបអង្កេតក៏សួរលោកបន្ថែមថា៖ ហេតុអ្វីបានជាគេមិនហ៊ានបដិសេធ? លោកថា៖ គេខ្លាចរបបខ្មែរក្រហមសម្លាប់គេ។" ដូច្នេះលោកនឹកឃើញឡើងវិញទេថា អ្នកខ្លះនុ៎ង ទោះបីជាមិនសប្បាយចិត្ត ក៏មិនហ៊ានប្រកែកដែរ ព្រោះខ្លាចខ្មែរក្រហមសម្លាប់?

**ឆ៖** បាទៗ ចម្លើយរបស់ខ្ញុំដែលថានេះគឺពិតហើយ ព្រោះខ្ញុំ ដូចថាវានៅក្នុងជួរហ្នឹង វាដូចជាពិត មិនដែលនិយាយភូតភរអីទេហ្នឹង។ ហ្នឹងខ្ញុំបានជូនដំណឹងទៅថា របបហ្នឹង គេធ្វើអ៊ីចឹងមែន គ្រាន់តែត្រឹមថា ទោះបីស្រឡាញ់ប៉ុនណា អាហ្នឹងអត់អីទេ។ ប៉ុន្តែមិនប្រកែក តែហ៊ានតែប្រកែក ដឹងតែបាត់ខ្លួនតែប៉ុណ្ណឹងឯង។ អាហ្នឹងខ្ញុំច្រើននិយាយអស់លោកទាំងអស់ដែលនៅស្ដាប់បន្ត។

**ស៖** ពេលដែលលោកធ្វើជាប្រធានមន្ទីរស្រុកស្អាង តើខ្លួនលោកផ្ទាល់ធ្លាប់ឃើញហេតុការណ៍ដូចដែលលោកបានរៀបរាប់ហ្នឹងទេ គឺថាបានឃើញដោយផ្ទាល់ភ្នែកនូវគូណាមួយដែលមិនព្រមរៀបការ

01355177



ហើយបន្ទាប់មក គឺគូហ្នឹងបាត់ខ្លួន? លោកអាចផ្ដល់ឧទាហរណ៍បែបហ្នឹងជូនតុលាការបានទេ?

[១០:០៦:០០]

**ឆ៖** ខ្ញុំឃើញនឹងភ្នែកតែរឿងរៀបការហើយ អ្នកណាមិនព្រមក្រោកចេញ។ តែខ្ញុំអត់បានតាមមើលថា អ្នកដែលក្រោកចេញដោយមិនពេញចិត្តនោះ បាត់ខ្លួនអីទៅណាមកណា ខ្ញុំវាមិនបានគិតពេលនោះ។ ព្រោះពួកហ្នឹងសុទ្ធតែកងចល័តទេ បើថា រួចចេញពីហ្នឹងកើតមិនកើតអីហ្នឹង មានតែទៅអង្គភាពគេវិញហើយ ប៉ុន្តែខ្ញុំណា ឆ្ងាយពីកន្លែង ខ្ញុំមិនដែលដើរទៅទេ។ អ៊ីចឹងទៅខ្ញុំអត់យកចិត្តទុកដាក់អីរឿងចេញទៅហ្នឹង គេទៅឲ្យធ្វើ ដាក់កំហុសអី ខ្ញុំអត់បានតាមដានមើលផងកាលនោះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

បាទ លោកប្រធាន។ ខ្ញុំនៅសល់សំណួរមួយចំនួនតូច អ៊ីចឹងខ្ញុំចង់សួរបញ្ចប់ ឬក៏លោកប្រធានចង់ឈប់សម្រាកសិន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី!

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកខ្លួនឯងផ្ទាល់ហ្នឹង មានបានរៀបការទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[១០:០៧:៣៥]

**លោក សេង សឿន៖**

**ឆ៖** បាទ និយាយរឿងខ្លួនខ្ញុំមានដែលកាលហ្នឹង។ ខ្ញុំគ្មានទឹកចង់បានប្រពន្ធអ៊ីចឹងទេ ចង់តែទៅផ្លាស់ទៅនេះទៅនោះ។ គ្រាន់តែស្រុកស្អាងហ្នឹងមានរឿងខ្ញុំផ្ទាល់ រៀបការពីរគូ ខ្ញុំមួយ ពីរគូទៀត ខ្ញុំភ្លេចឈ្មោះហើយ។ ឯខ្ញុំ បងសៅ ផុន ហ្នឹងគាត់ថា "អ្អែងល្មមយកប្រពន្ធហើយ"។ ខ្ញុំចេះតែប្រកែក១ គាត់ឲ្យបងស្រីមួយស្រុកកំណើតនៅជិតដំណាក់សេកដែរ គាត់ ខ្ញុំភ្លេចឈ្មោះគាត់ដែរ គាត់ធ្វើអនុប្រធានពេទ្យស្រុកហ្នឹង។ ចេះមកសួរខ្ញុំម្ដង ខ្ញុំថា អ្អេ! ខ្ជិលណាស់ ដឹងយកអីទេ។ គឺថារាប់លើកទី៣ អ្អឺ! ងាកសួរ១ម្ល៉េះ គ្រប់បីដងហើយ សួរឲ្យយកប្រពន្ធ ខ្ញុំថា "អ្អ! អ៊ីចឹងព្រមក៏ព្រមទៅ"។ ក៏ បងផុន រៀបការឲ្យខ្ញុំទៅ។ ប្អូនខ្ញុំកាលហ្នឹងរៀបការឲ្យខ្ញុំ គឺជាប្អូនជីដូនមួយរបស់ សៅ ផុន គណៈស្រុកហ្នឹង។ អាហ្នឹងរឿងខ្ញុំផ្ទាល់។ ខ្លាចគេថាផង ហើយនិងចិត្តមិនចង់ មិនចង់ផង ដល់ថាចុះថាឡើងទៅ អ្អេ យកក៏យក *(ឮមិន*

*ច្បាស់)* អានេះខ្ញុំផ្ទាល់។

**ស៖** តើលោកធ្លាប់ជួបបងប្អូនជីដូនមួយប្រធានគណៈស្រុកហ្នឹងពីមុនមកទេ មុនពេលរៀបការហ្នឹង?

**ឆ៖** ខ្ញុំអត់ដែលឃើញដែលជួបទេប្រពន្ធដែល បងផុន រៀបការឲ្យ តែទើបមក ខ្ញុំមកនៅមន្ទីរពិការហ្នឹងទៅ ស្រាប់តែបងស្រីមួយធ្វើអនុប្រធានពេទ្យហ្នឹង គាត់នាំដើរចុះឡើងចូលកន្លែងមន្ទីររបស់ខ្ញុំនៅហ្នឹង។ រហូតដល់ថ្ងៃរៀបការទៅបានដឹងថា ភូមិ ស្គាល់កំណើត ស្រុកអីណា ដែលគេនៅភូមិដូង ឃុំដូង ស្រុកស្រែក្នុង ខេត្តកំពត ដែលជាប្អូនជីដូនមួយ បងផុន ហ្នឹង។

[១០:១០:០២]

**ស៖** លោកចាំទេថា លោករៀបការនៅឆ្នាំណា? ពេលដែលលោកនៅតាខ្មៅ ឬក៏នៅពេលដែលគេផ្លាស់លោកទៅស្រុកស្អាង?

**ឆ៖** កាលហ្នឹងខ្ញុំមកនៅស្រុកស្អាងហ្នឹង ហើយ បងផុន គណៈស្រុកហ្នឹងគាត់អ្នករៀបការឲ្យខ្ញុំហ្នឹង គឺប្អូនជីដូនមួយរបស់គាត់ហ្នឹង មកពីនៅខាងភូមិដូង ឃុំដូង ស្រុកស្រែក្នុង។

**ស៖** លោកបាននិយាយថាមានពីរគូទៀតដែរ រៀបការនៅក្នុងថ្ងៃតែមួយជាមួយលោកហ្នឹង។ អ៊ីចឹងពេលលោករៀបការហ្នឹងមានបីគូមែនទេ ឬក៏មានតែពីរគូទេ លោកមួយគូ ហើយនិងមួយគូផ្សេងទៀត?

**ឆ៖** មានបី ខ្ញុំមួយគូ ហើយពីរគូទៀត តែខ្ញុំភ្លេចទៅហើយ។ មីមួយ អ៎! នៅចាំថាមីមួយនោះប្រធានចល័តស្រុកហ្នឹង ហើយអាមួយទៀតនៅខាងចុងភៅដាំនៅកន្លែងមន្ទីរស្រុកហ្នឹង។ ខ្ញុំចាំតែប៉ុណ្ណឹង។

**ស៖** តើមានច្បាប់អ្វីពិសេសសម្រាប់អ្នកដែលរៀបការដូចជាលោក ដែលជាបក្ខជនហ្នឹង ឬក៏ថា អ្នកណាក៏ដោយឲ្យតែការ គឺថាគេធ្វើដូចតែគ្នាទេ អត់មានអីជាករណីពិសេសអីទេ?

**ឆ៖** ចូលពេលហ្នឹង លែងគិតពីរឿង ស.យុវកក សន-កក ហើយក៏បក្ខជនអីទេ ដល់ពេលគេហៅថារៀបការទូទៅតែម្ដង តាមអង្គភាព មន្ទីរអីរបស់សម័យនុ៎ង។

**ស៖** ក្រោយពីរៀបការរួច តើលោកបានរស់នៅជាមួយប្រពន្ធរបស់លោកទេ?

[១០:១២:៤៧]

**ឆ៖** ក្រោយមក រៀបការរួច ខ្ញុំរយៈពេលបានមិនពេញ៣ខែស្រួលបួលទេ ត្រូវទាំង ផុន ទាំងខ្ញុំ

ហើយនិងពីរនាក់ទៀតនៅស្រុកស្អាងជាមួយខ្ញុំហ្នឹង ផ្លាស់ទៅក្រចេះ ទាំងគាត់ ទាំងខ្ញុំហ្នឹងទៅ ប៉ុន្តែខ្ញុំឲ្យស្រីៗនៅនេះទៅ ចាំយកតាមក្រោយ កាលហ្នឹង។

**ស៖** ចុះប្រពន្ធលោកក្រោយមកហ្នឹង គេបានបញ្ជូនទៅរស់នៅជុំគ្នាជាមួយលោកទេ នៅក្រចេះហ្នឹង?

**ឆ៖** ប្រពន្ធដែល បងផុន រៀបការកាលនោះ អត់ទេ ខ្ញុំមកនៅក្រចេះណោះរហូត។ ចូលៗយួនមកហើយ ខ្ញុំឡើងភ្នំដងរែក ចុះមកវិញមកទៀត លែងបានទៅណា ទៅយកប្រពន្ធក្នុងជួរហ្នឹងទៀត។ ក៏បងផុន ហ្នឹងរៀបការឲ្យទៀត ហើយប្រពន្ធ អើមកនៅស្រុកស្អាង អ៎! នៅភូមិភូមិដូង ស្រុកស្រែក្នុងហ្នឹង អត់ដែលបានឮដំណឹង បងផុន ហ្នឹងក៏ជ្រាប គាត់ថាទៅនៅ ចេះតែស៊ើបសួរ សួរបងផុន ហ្នឹងគាត់ទៅនៅឯនេះជាមួយបងមុត – មាស មុត នៅឯៗម្តុំឯជិតនេះណោះ ប៉ៃលិន សំឡូតណោះ គ្រាន់ដំណឹង តែមិនបានដឹងអស់ទេ ខ្ញុំ។

**ស៖** សំណួរចុងក្រោយលោកប្រធាន សូមអនុញ្ញាត។ មុននេះលោកឆ្លើយថា លោកព្រមរៀបការ ព្រោះថាលោកខ្លាច ផុន។ អ៊ីចឹងលោកខ្លាចគាត់ហ្នឹង ខ្លាចដោយសារហេតុអី?

**ឆ៖** អារឿងសម័យនោះ ខ្ញុំវាពិបាកនឹងជម្រាបថា ខ្លាចអី រឿងអី ព្រោះមួយ ក្រោមការដឹកនាំរបស់គេ ហើយសម័យនោះ ពិបាកណាស់ ស្រួលមិនស្រួលហ្នឹង ងាប់ បាត់ខ្លួន មិនដឹងជាស្អីៗ អាហ្នឹងមិនថា ឋានៈអីថ្នាក់អីទេ តែមិនស្រួលបាត់។ ហើយអ៊ីចឹងចេះតែគិតអីអ៊ីចឹង អ៎! ថាឲ្យយកក៏យកទៅអាហ្នឹង។ ខ្ញុំបានគិតឃើញតែអ៊ីចឹងទេ សម័យនោះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធានសូមអរគុណ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:១៦ នាទី ដល់ម៉ោង ១០:៣៥ នាទី)*

[១០:៣៥:៤៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្ត សូមអញ្ជើញលោកសហព្រះរាជអាជ្ញាឡើងមានសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់អំពីជំហាររបស់យើង ដោយសារសាក្សីរូបនេះគឺថាកំណត់ពេលវេលាសម្រាប់គាត់មួយថ្ងៃកន្លះ ដូច្នេះភាគីនីមួយៗគឺមានរយៈពេលបីវគ្គ។ <ខ្ញុំមិនដឹងថាតើយើងនឹងប្រើទាំងពីរវគ្គនៅព្រឹកនេះ ហើយនិងមួយវគ្គទៀតនៅពេលរសៀលនោះឬយ៉ាងណាទេ។ ប៉ុន្តែ> ខ្ញុំសូមបញ្ជាក់ថា សាក្សីរូបនេះ គឺថាយើងបានកំណត់ពេលវេលាសម្រាប់គាត់គឺមួយថ្ងៃកន្លះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវខ្ញុំសូមត្រឡប់ទៅសួរលោកអំពីប្រវត្តិសាវតាររបស់លោកនៅក្នុងរបបខ្មែរក្រហម។ លោកបានផ្ដល់សក្ខីកម្មថា លោកបានរងរបួស ហើយសម្រាកនៅមន្ទីរពេទ្យ ហើយក្រោយពីចេញពីមន្ទីរពេទ្យមកវិញ លោកបានចូលទៅរស់នៅ<មន្ទីរជនពិការនៅ>តំបន់១៣<>។ <ខ្ញុំគ្រាន់តែសុំសួរបញ្ជាក់> តើ<លោកចេញ>ពីមន្ទីរពេទ្យ<សំដៅ>ទៅមន្ទីរជនពិការ<នៅតំបន់១៣>នុំង<តែម្ដង ឬក៏លោកទៅផ្ទះ>លោកនៅឯត្រាំកក់<សិន> មុននឹងលោកទៅមន្ទីរជនពិការ? <តើលោកចាំទេថា លោកបានចំណាយពេលនៅ>ស្រុកកំណើតនៅត្រាំកក់<> មុនពេល<ពេលលោក>ទៅកាន់មន្ទីរជនពិការ<នៅតំបន់១៣>?

[១០:៣៧:៥៦]

**លោក សេង សឿន៖**

**ឆ៖** បាទ ខ្ញុំភ្លេចអស់ហើយថ្ងៃខែ ហ្នឹងហើយ។ ចេញពីពេទ្យ ជាហើយ ដឹងថាខ្លួនពិការ ទៅអង្គភាព ក៏បានអង្គភាពនៅកងវរសេនាតូច មានប្រធានខ្ញុំគេឈ្មោះ បាវ គេបានបញ្ជូនឲ្យខ្ញុំគ្នាបីបួននាក់អ្នកត្រូវពិការដែរហ្នឹង ប៉ុន្តែខ្ញុំធ្ងន់ជាងគេ ដើរជើងឈើម្ខាង ហើយគេបញ្ជូនទៅ។ ទៅដល់មន្ទីរស្រុកខេត្តតាកែវនេះ ទើបបានគេបញ្ជូនចេញទៅមន្ទីរពិការភូមិភាគ -- តំបន់១៣ហ្នឹង ឈ្មោះ យ៉ាវ ដែលគេធ្វើប្រធានមន្ទីរពិការ ទើបរកនឹកឃើញឈ្មោះ។ តែភ្លេចថ្ងៃខែឆ្នាំហើយ ប៉ុន្តែក្រោយ ១៧ មេសា តិចហើយបែកយួនចេញ ម្ល៉ោះហើយខ្ញុំបានទៅពិការហ្នឹង។

**ស៖** សូមអរគុណ។ លោកចាំទេ នៅថ្ងៃ១៧ មេសា ១៩៧៥ គឺនៅថ្ងៃដែលខ្មែរក្រហមកាន់កាប់

ទីក្រុងភ្នំពេញ ហើយនិងក្តោបក្តាប់អំណាចបាននៅទូទាំងប្រទេស លោកចាំដែរនៅថ្ងៃ១៧ មេសា ៧៥ លោកនៅឯណាដែរ?

**ឆ៖** ពេលហ្នឹងខ្ញុំអត់ទាន់ពិការទេ គឺនៅក្នុងអង្គភាពវរសេនាតូចព្រំដែនតាកែវហ្នឹង ជិតទៅមានប្រាសាទមួយ ខេត្តតាកែវម៉ុំហ្នឹង នៅព្រំដែនហ្នឹង នៅប្រចាំការហ្នឹង ដែលរហូតវ៉ៃគ្នាចុះឡើងជាមួយយួនព្រំដែនហ្នឹងបានពិការហ្នឹងទៅ។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងស្រុកកំណើតរបស់លោក គឺស្រុកត្រាំកក់។ តើលោកមានចំណាយពេលវេលា<នៅស្រុកត្រាំកក់ទេ នៅ>ក្នុងរបបខ្មែរក្រហមនោះ បើគិតពីឆ្នាំ១៧ មេសា ៧៥ ដល់ថ្ងៃ០៧ មករា ៧៩? តើលោកមានបានទៅលេងស្រុកកំណើត<នៅត្រាំកក់ ឬក៏លោកបានទៅរស់នៅទីនោះទេ>?

[១០:៤០:៣៦]

**ឆ៖** ខ្ញុំទៅលេងបានបីបួនដងហើយ បើតាមគិតតាំងនៅមន្ទីរពិការតំបន់ រហូតដល់មន្ទីរពិការភូមិភាគនិរតីហ្នឹង បានគឺបានបីទៅបួនហ្នឹង តាមចំណាំ។ ជួបម្តាយខ្ញុំ ពុកខ្ញុំ បងប្អូនអីហ្នឹង។

**ស៖** ឥឡូវនាំគ្នានិយាយអំពីមន្ទីរជនពិការតំបន់ និងភូមិភាគ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា<តើនៅទីនោះមានមនុស្សប៉ុន្មាននាក់ តើ>មានអតីតយុទ្ធជនដែលរងរបួស<នៅមន្ទីរយុវជនពិការនៅ>តំបន់១៣<ប៉ុន្មាននាក់ ហើយតើមានប៉ុន្មាននាក់>នៅឯមន្ទីរភូមិភាគ<>នៅតាខ្មៅនេះ<>?

**ឆ៖** ប្រាប់ចំនួនកើន គ្រាន់តែដឹងថា គេរៀបជាកង វាមន្ទីរពិការភូមិភាគនិរតី វារៀបជាបីកងអនុសេនាធំ។ ក្នុងមួយកងអនុសេនាធំ គេប្រើតាំងពី១០០ ឬក៏លើស ឬតិច គេហៅថាមួយកងអនុសេនាធំ។ អ៊ីចឹងក្នុងមួយអង្គភាពមន្ទីរពិការ វាមានបីកងអនុសេនាធំ គេហៅថា ស្មើនឹងមួយវរសេនាតូច។ ហ្នឹងជនពិការ ដែលខ្ញុំនៅ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺលោកថា មានជនពិការនៅមន្ទីរជនពិការនៅតាខ្មៅហ្នឹង មានចំនួនសរុបទាំងអស់ហ្នឹង ប្រហែលជា៤០០នាក់ ត្រឹមត្រូវដែរឬទេ?

**ឆ៖** កាលនោះខ្ញុំមិនបានរង់ចាំនៅចាំនៅឡើយទេ គ្រាន់តែថា គ្រាន់ប្រហាក់ ឬប្រហែល ព្រោះវាបីកងអនុសេនាធំ មួយកងអនុសេនាធំ វាស្មើទៅនឹង១២០។ អ៊ីចឹងវាបីកងអនុសេនាធំ វាស្មើនឹងជាង៣០០នាក់ហ្នឹង។

[១០:៤៣:២៦]

**ស៖** សូមអរគុណ។ លោកក៏បានលើកឡើងដែរ ព្រឹកមិញនេះថា យុទ្ធជនខ្លះ គឺថាបានរៀបការពីមុនរួចហើយ មានគ្រួសាររួចហើយ ហើយអ្នកខ្លះទៀតនោះគឺថានៅលីវ។ តើលោកអាចប៉ាន់ប្រមាណបានទេ ក្នុងចំណោមទាំងអស់នេះ ប៉ុន្មាននាក់ដែលបានរៀបការរួចមកហើយ? ហើយប៉ុន្មាននាក់នៅលីវ?

**ឆ៖** តាមខ្ញុំប៉ាន់ប្រមាណ ដោយមិនបានគិតចំនួននៅឡើយទេ វាមានប្រពន្ធហើយ ប្រហែលជា១០ភាគរយ ក្នុងចំណោមជនពិការដែលនៅកោះគរកាលនោះ។

**ស៖** អ៊ីចឹងបើយើងនិយាយថា ភាគច្រើននៃយុទ្ធជនពិការទាំងអស់នេះគឺនៅលីវ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទៗ ត្រឹមត្រូវ។

**ស៖** សំណួរមួយទៀត ពាក់ព័ន្ធទៅនឹងប្រវត្តិរូបរបស់លោក។ លោកបានបញ្ជាក់ថា លោកនៅឯមន្ទីរជនពិការតំបន់<១៣>ហ្នឹង គឺថាលោកជាអនុប្រធានមន្ទីរជនពិការ។ ចុះនៅ<មន្ទីរជនពិការភូមិភាគនៅ>តាខ្មៅ<លោកមានតួនាទីអ្វីដែរ>?

**ឆ៖** ពីមុនមកដល់ គេមានមនុស្សមកមុនខ្ញុំហ្នឹង គេហៅមន្ទីរភូមិភាគនិរតីមានហើយ មានប្រធាន អនុប្រធានអីហើយ ខ្ញុំមកក្រោយគេទេ។ គ្រប់តំបន់គេមកមុន នៅតំបន់១៣នេះ គេយកជនពិការដូចខ្ញុំអីហ្នឹងក្រោយគេ។ បានរៀបចំទៅបានបំពេញមួយកងវរសេនាតូច បីកងវរសេនាធំ ពេលដែលខ្ញុំមកដល់ហ្នឹង បានមានឲ្យខ្ញុំធ្វើជាប្រធានកងអនុសេនាធំ។

**ស៖** តើមានពេលណាមួយពេលដែលលោកមកដល់ ប្រធានមន្ទីរ ឬក៏ទាំងអនុប្រធានមន្ទីរផងនោះត្រូវបានគេចាប់ខ្លួន ហើយលោកក៏ត្រូវបានគេដំឡើងបុណ្យស័ក្តិនៅពេលនោះ តើលោកអាចជម្រាបជូនតុលាការបានទេពីរឿងនេះ?

[១០:៤៦:៣០]

**ឆ៖** បាទ ចាំ ប៉ុន្តែគ្រាន់ថាមិនដឹងថ្ងៃទីប៉ុន្មាន ប៉ុន្តែគ្រាន់តែចាប់ប្រធាន អនុប្រធានទៅៗ គេយកតាមួយនៅចេញពីរោងចក្រធ្វើសាប៊ូឲ្យធ្វើប្រធានមន្ទីរពិការហ្នឹង ប្រហែលជា២ខែ បានអនុប្រធានមន្ទីរភូមិភាគហ្នឹង គេមកប្រកាសចាត់តាំងឲ្យខ្ញុំឡើងទៅជាអនុប្រធានរបស់ពូចាស់ដែលនៅមន្ទីរពិការមុនទៅនៅរោងចក្រធ្វើសាប៊ូនោះ តែអត់ចាំទេថ្ងៃខែ។

**ស៖** សូមអរគុណ។ ខ្ញុំយល់ហើយ <>ថា<លោក>មិនចាំកាលបរិច្ឆេទច្បាស់លាស់បាននោះទេ។ លោក<>ថា<>អនុប្រធាន<>ភូមិភាគ<>ប្រកាស<ដំឡើងតំណែងលោក។ តើ>លោកចាំទេឈ្មោះ<បុគ្គលហ្នឹងទេ>? <តើលោកសំដៅលើអ្នកណា ដែលលោកថាអនុប្រធានភូមិភាគហ្នឹង?>

**ឆ៖** ខ្ញុំភ្លេចឈ្មោះអស់ហើយពេលហ្នឹង។ គ្រាន់នៅចាំដែលមកប្រកាសចាត់តាំងឲ្យធ្វើជាអនុប្រធានមន្ទីរពិការភូមិភាគហ្នឹង។ នែ! ប្រធានមន្ទីរភូមិភាគ បងមួយហ្នឹងជាប្អូនថ្លៃ តាម៉ុក។ បងមួយទៅប្រកាសឲ្យខ្ញុំហ្នឹងធ្វើអនុប្រធានមន្ទីរពិការហ្នឹង ធ្វើជាអនុ ត្រូវប្រកាសខ្ញុំអាហ្នឹងក៏ខ្ញុំ នែ! អត់ចាំឈ្មោះគាត់ដែរ។ តែកាលហ្នឹងធ្វើនៅរោងចក្រស៊ីគេទេ ក្រឡឹងដែកជិតភ្នំពេញនេះដែរ គេមកធ្វើអនុប្រធានភូមិភាគ។ ប្រធានមន្ទីរភូមិភាគនិរតីនេះ ពូខ្ញុំភ្លេចមុខដែរ អាហ្នឹងគឺប្អូនថ្លៃ តាម៉ុក។ ហើយបងមួយហ្នឹងចេញពីទ័ពនៅកងពលលេខ២ ភូមិភាគនិរតីហ្នឹង ទៅកាន់រោងចក្រអីក្រឡឹងអីដែរជិតភ្នំពេញ បានគេឡើងធ្វើអនុប្រធានភូមិភាគ ទៅប្រកាសចាត់តាំងខ្ញុំទៅ។ អាហ្នឹងរកហៅឈ្មោះពីណាក៏ពីមុន ពីមុនចេះតែស្គាល់ទាំងអស់ ឈ្មោះអីៗ ឥឡូវភ្លេចច្រើនដែរ។

[១០:៤៩:១៣]

**ស៖** មិនថ្វីទេលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកបានបញ្ជាក់ថា ការចងចាំរបស់លោកអំពីពេលវេលានេះគឺថា លោកចាំមិនបានច្បាស់លាស់ទេ។ ប៉ុន្តែឥឡូវនេះខ្ញុំសូមអានសម្រង់ខ្លីៗដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបញ្ជាក់មើលថាតើចម្លើយរបស់លោកហ្នឹងត្រឹមត្រូវអត់។ លោកប្រធាននេះគឺឯកសារ E3/5643 ខ្មែរ00059402, អង់គ្លេស 00753896, បារាំង 00756647។ នេះគឺជាអ្វីដែលលោកបានឆ្លើយប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា៖ “គឺវានៅក្នុងពាក់កណ្ដាលឆ្នាំ១៩៧៥ នៅពេលខ្ញុំធ្វើការនៅតំបន់១៣ នៅតាកែវ។ បន្ទាប់មកខ្ញុំមកតាខ្មៅ នៅឆ្នាំ១៩៧៧។ ហើយនៅក្នុងខែមិថុនា ១៩៧៨ ខ្ញុំបានទៅធ្វើការនៅស្អាង គឺចេញពីមន្ទីរជនពិការទៅ។” បញ្ចប់ការដកស្រង់។ តើកាលបរិច្ឆេទពេលវេលាទាំងនេះ វាត្រឹមត្រូវដែរឬទេ ពាក់ព័ន្ធទៅនឹងការផ្លាស់ប្ដូរ<តួនាទីផ្សេងៗ>របស់លោកដែលថានៅដើមឆ្នាំ៧៧ លោកទៅតាខ្មៅ ហើយនៅម៉្ដុំខែមិថុនា ៧៨ លោកក៏បានទៅធ្វើការនៅស្អាង លោកចាកចេញពីមន្ទីរជនពិការទៅ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** មួយសំណួរទៀតពាក់ព័ន្ធនឹងប្រវត្តិសាវតារ។ នៅពេលលោកទៅធ្វើការនៅស្រុកស្អាងទៅធ្វើជាប្រធានស្រុកនៅទីនោះ តើលោកនៅចាំទេ នៅមន្ទីរស្រុកហ្នឹង នៅពេលនោះមានមនុស្សប៉ុន្មាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01355184



នាក់ដែរ?

[១០:៥១:៣៨]

**ឆ៖** ខ្ញុំស្ដាប់មិនច្បាស់ទេថា រកមនុស្សណា មកពីស្រុកណា? ចង់និយាយថា ខ្ញុំនៅស្រុកស្អាង ដែលខ្ញុំទៅនៅហ្នឹង ទៅនៅពីមន្ទីរស្រុកស្អាងហ្នឹង ខ្ញុំចេញពីមន្ទីរពិការនេះទៅម្នាក់ឯងទេ ទៅនៅស្រុកស្អាង។ រួចបានបងគណៈស្រុកហ្នឹងរៀបការប្រពន្ធឱ្យខ្ញុំទៅ រួចក៏ផ្លាស់ទៅក្រចេះ។ ដល់ចំបានមួយខែស្រួលបួលហ្នឹង ចប់ត្រឹមហ្នឹងហើយ យួនចូលស្រុកខ្មែរបណ្ដោយទៅ ក៏ធ្លាក់ដល់ភ្នំដងរែកនោះ ខ្ញុំ។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំយល់ហើយ។ សំណួររបស់ខ្ញុំសួរថា នៅពេលដែលលោកទៅធ្វើការនៅស្រុកស្អាង តើលោកចាំទេថា មានប្រជាជនទាំងអស់សរុបប្រហែលជាប៉ុន្មាននាក់ដែរ រស់នៅក្នុងស្រុកស្អាងនៅពេលនោះ?

**ឆ៖** ខ្ញុំអត់បានដឹងចំនួនប្រជាជនប៉ុន្មានទេ។ ខ្ញុំពេលនោះនៅមន្ទីរស្រុក ដឹងតែបញ្ជីតាមឃុំហើយសហករណ៍ បូកចូលចំនួនប្រជាជន ជាប្រជាជនចាស់ ប្រជាជនថ្មីអីហ្នឹង ក្នុងបញ្ជីខ្ញុំអ្នកកាន់កាប់ តែមិនដឹងនៅចាំថាប៉ុន្មានៗ ខ្ញុំអត់បានចាំដែរ ព្រោះមន្ទីរស្រុក សួរថាបញ្ជីម្រយហ្នឹងហើយ ខាងខ្ញុំ តែមិនបានចំណាំចាំទេ។

**ស៖** មិនថ្វីទេលោកដើមបណ្ដឹងរដ្ឋប្បវេណី សូមអរគុណច្រើន។ ឥឡូវនេះ ខ្ញុំសូមចូរទៅនិយាយអំពីប្រធានបទដែលសហមេធាវីនាំមុខបានសួរសំណួរលោករួចមកហើយ <ហើយខ្ញុំនឹងសួរលោកបន្តពីរបីសំណួរទៀត>ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ។ ដំបូងការរៀបការទៅឱ្យយុទ្ធជនពិការដែលលោកបានរៀបរាប់ហ្នឹង គឺឱ្យរៀបការជាមួយស្ត្រីដែលគេយកមកពីខេត្តកំពត។ លោកបានបញ្ជាក់ថាដំបូងគឺ<>ក្រោយពេលលោកចេញពីមន្ទីរជនពិការហើយ ទៅធ្វើការនៅស្រុកស្អាង ហើយបន្ទាប់មកលោកបានរៀបរាប់អំពីព្រឹត្តិការណ៍ និងបានបញ្ជាក់ថា មានការបញ្ជាពី តាម៉ុក ឱ្យរៀបការឱ្យយុទ្ធជនទាំងនេះ។ លោកមិនបានស្ដាប់ឮ តាម៉ុក និយាយដោយផ្ទាល់មាត់ទេ ក៏ប៉ុន្តែលោកបានឮពីមេបញ្ជាការម្នាក់ ហើយមេបញ្ជាការនេះបញ្ជូនសេចក្ដីសម្រេចរបស់ តាម៉ុក នោះមកលោក ហើយប្រាប់ថា យុទ្ធជនទាំងនោះ<ចាស់ហើយ>ត្រូវតែរៀបការឱ្យពួកគេ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់អំពីចំណុចនេះបន្តិច តើលោកច្បាស់ទេ ថាការរៀបការនេះ គេរៀបចំឡើងក្រោយពេលលោកចេញពីមន្ទីរជនពិការទៅស្រុកស្អាងហើយ ឬក៏<ការចងចាំរបស់លោកនៅថ្ងៃនេះមិនច្បាស់> ថាតើការរៀបការហ្នឹង គឺគេរៀបការឱ្យយុទ្ធជនទាំងហ្នឹង គឺនៅពេលដែលលោកនៅមន្ទីរជនពិការ <ឬក៏នៅ>ក្រោយពេលដែលលោកទៅដល់

ស្រុកស្អាងហើយនោះទេ<>?

[១០:៥៥:៣៨]

**ឆ៖** ហ្នឹងខ្ញុំនៅចាំ ខ្ញុំចេញផុតហើយ បានមានដឹងផែនការ តាម៉ុក ដាក់ឲ្យប្រធានមន្ទីរពិការភូមិភាគហ្នឹងទៅ រកយកនារីៗមករៀបការឲ្យជនពិការ ហើយពេលហ្នឹងពេលខ្ញុំមកនៅស្រុកស្អាងផុតហើយ។ តែខ្ញុំបានដឹងហ្នឹង ព្រោះខ្ញុំឧស្សាហ៍ដើរទៅលេងគាត់ ដូចថាកន្លែងចាស់ធ្លាប់នៅ បានទៅបានដឹង ហ្នឹងរឿងខ្ញុំ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ មាននារីប៉ុន្មាននាក់ដែលគេយកមកឲ្យរៀបការជាមួយយុទ្ធជនពិការហ្នឹង យកពីកំពតមកហ្នឹង មានសរុបទាំងអស់ប៉ុន្មាននាក់?

**ឆ៖** ខ្ញុំអត់ដឹងបានថាចំនួនណាទេ។ អ្អែងកុំប្រើពាក្យថា របៀបប្រហែលៗ ក៏មិនហ៊ានថាដែរ ព្រោះខ្ញុំអត់បានឃើញច្បាស់ គ្រាន់តែឮគេថាដែរ អ៊ីចឹងខ្ជិលនិយាយ។

**ស៖** លោកបានបញ្ជាក់ថាលោកដឹងរឿងនេះ គឺនៅពេលដែលលោកទៅពិនិត្យមើលមន្ទីរជនពិការ។ តើលោកមានបានដឹងថាមានស្ត្រីណាម្នាក់ដែលគេបញ្ជូនមកពីកំពត មកឲ្យរៀបការជាមួយយុទ្ធជនពិការហ្នឹង លោកដឹងមាននារីណាម្នាក់ មានផ្ទៃពោះដែរអីទេ?

**ឆ៖** បាទ ខ្ញុំទៅលេងហ្នឹង ដូចអត់ឃើញមានអ្នកណាអីកើតអីទេ។ ឃើញតែជួបជុំគ្នាដដែលៗ អ្នករៀបការហើយ។ ខ្ញុំឃើញបានអាប្អូនជីដូនមួយទេ ទៅយក ពិការហ្នឹងទៅយកប្រពន្ធ គេរៀបការហ្នឹង មិនទាន់ពិការហ្នឹងដែរ មិនដឹងឈ្មោះអីទេមីស្រីហ្នឹង ប៉ុន្តែអាប្រុសហ្នឹងប្អូនជីដូនមួយខ្ញុំ។ មិនឃើញកើតអីផង ខ្ញុំឃើញតែប៉ុណ្ណឹង ក្រៅពីហ្នឹងខ្ញុំអត់បានឃើញអីទេ ទៅលេងមួយភ្លែតដែរ។

[១០:៥៨:១៣]

**ស៖** លោកបានបញ្ជាក់ថាយុទ្ធជនពិការម្នាក់ ដែលបានរៀបការដែរនោះ គឺថាជាក្មួយប្រុសរបស់លោក។ តើក្មួយប្រុសរបស់លោកមានប្រាប់លោកដែរ<ទេអំពីការរៀបការនោះ ហើយនិងអំពី>នារី<ដែលគេនាំ>មកពីខេត្តកំពត<នោះ? តើលោកធ្លាប់និយាយជាមួយគាត់អំពីរឿងនេះទេ>?

**ឆ៖** ឈ្មោះហ្នឹងមិនមែនក្មួយទេ ប្អូនជីដូនមួយដែល បងផុន រៀបការឲ្យខ្ញុំហ្នឹង។ តាមខ្ញុំដឹងខាងស្រីក៏មិនដឹងខ្លួនដែរ ហើយខ្ញុំក៏មិនដឹងថាអ្នកណាដែរ គេចេះថា មក! អ្អែងយកប្រពន្ធទៅ។ ថាពីរបីដងហ្នឹង បានខ្ញុំព្រមហ្នឹង បានយកមកឲ្យជួបមុខទៅ បានដឹងត្រឹមពេលហ្នឹងទៅទេខ្ញុំ អត់មានបានទាក់ទងអី ទៅស្រឡាញ់អីមុន អត់សោះ។

**សៈ** លោកដើមបណ្តឹងរដ្ឋប្បវេណី <យើងបាននិយាយអំពី>ព័ត៌មាន<ទាក់ទងទៅនឹង>ការរៀបការយុទ្ធជនពិការនៅមន្ទីរជនពិការភូមិភាគនៅតាខ្មៅ ដែលលោកធ្លាប់ធ្វើការនៅទីនោះៗ គឺថា -- ចុះលោកធ្លាប់ដែលឮថា នៅកន្លែងផ្សេងៗទៀតនៅក្នុងផ្ទៃប្រទេសទាំងមូលហ្នឹង មានគេរៀបការយុទ្ធជនពិការឲ្យជាមួយនារីៗណាផ្សេងទៀតទេ? តើលោកដឹងថាគេមានផ្សំផ្គុំរៀបការជនពិការជាមួយនារីដទៃទៀតនៅកន្លែងដទៃទៀតនៅក្នុងប្រទេសកម្ពុជាទាំងមូលនេះដែរទេ?

**ឆៈ** ខ្ញុំអត់ដឹងទេ ព្រោះដែលទៅណា នៅតែ បើនៅស្រុកស្អាង នៅមន្ទីរស្រុកហ្នឹង ដល់ទៅក្រចេះ នៅតែត្រង់នុ៎ង មិនដែលទៅណាទេ ចំអាពេលយួនមកគេឲ្យ មុត ទៀត បញ្ជាខ្ញុំឲ្យដើរប្រមូលទ័ពមាស មុតហ្នឹង ពេលហ្នឹងដើរទៅណាខ្ញុំទេ បានតែប៉ុណ្ណឹង មានដឹងរឿងអីទៀតទេ។

[១១:០០:៥៣]

**សៈ** ខ្ញុំសូមអានសម្រង់ខ្លះៗ ពាក់ព័ន្ធទៅនឹងភស្តុតាងដែលបានឆ្លើយជូនចំពោះមុខតុលាការនេះ គឺឯកសារ E3/9833 – E3/9833 ជាកិច្ចសម្ភាសន៍អតីតយុទ្ធជនមកពីភូមិភាគនិរតី ដែលក្នុងឆ្នាំ ១៩៧៨នោះ ត្រូវគេបញ្ជូនទៅភូមិភាគពាយ័ព្យ ហើយចាត់តាំងឲ្យធ្វើជា<>ប្រធានស្រុក។ ហើយនៅត្រង់ចម្លើយ២១៩ ដល់ចម្លើយ២២១ និង២២៦ទៅដល់២២៨ នៃកិច្ចសម្ភាសន៍របស់គាត់នោះ គាត់បានឆ្លើយថា ក្នុងឋានៈគាត់ជាលេខាស្រុកហ្នឹង គឺគាត់ត្រូវបាន<លេខាតំបន់>បញ្ជា<>ឲ្យរៀបចំរៀបការយុទ្ធជនពិការជាមួយកម្មករ<នារី>ដែលមកពីស្រែអំបិល ដែលត្រូវបានគេបញ្ជូនទៅពីកំពតមក ទៅភូមិភាគពាយ័ព្យ។ <នៅពេលដែល>ស្ត្រីពីរនាក់បានបដិសេធមិនព្រម<រៀបការ> លេខា<តំបន់>បាន<ណែនាំគាត់ឲ្យ>ពន្យល់ទៅឲ្យស្រីនោះថា សូមដកស្រង់៖ "គឺថាគេមានការទទួលខុសត្រូវ ដើម្បីរៀបការ និងថែទាំយុទ្ធជនទាំងអស់ហ្នឹង ដែលបានក្លាយទៅជាជនពិការ ដោយសារតែពួកគាត់ប្រយុទ្ធក្នុងសង្គ្រាមដើម្បីប្រទេសជាតិ។" បញ្ចប់ការដកស្រង់។ ដូច្នេះអតីតយុទ្ធជន<ភូមិភាគនិរតី ដែលត្រូវបានគេបញ្ជូនទៅ>នៅភូមិភាគពាយ័ព្យហ្នឹង គឺត្រូវបានគេរៀបការជាមួយស្ត្រីដែលគេយកពីស្រែអំបិលទៅ ពីកំពតទៅ ទៅរៀបការឲ្យពួកគាត់នៅទីនោះ។ <តើលោកចាំទេ?> តើលោកមានបានឮដែរថា គេបញ្ជូនស្ត្រីពីស្រែអំបិល កំពតហ្នឹង ទៅឲ្យរៀបការជាមួយយុទ្ធជនពិការនៅភូមិភាគពាយ័ព្យនោះ?

**ឆៈ** តែអត់ ខ្ញុំអត់ដឹងអីទាំងអស់។

**សៈ** ហើយបន្តពីរយៈពេលដែលលោកនៅស្រុកស្អាង ហើយលោកបាននិយាយអំពីការចាត់តាំង ឬក៏បញ្ជាដែលលោកទទួលបានពីគណៈស្រុក ដើម្បីប្រមូលប្រវត្តិរូប ដើម្បីផ្គូផ្គងមនុស្ស ដើម្បីរៀប

01355187



ការ។ បន្ទាប់ពីលោកបានផ្តល់ប្រវត្តិរូបទាំងអស់នោះទៅគណៈស្រុក តើអ្នកណាជាអ្នកសម្រេចថា ត្រូវរៀបការបុរសណាជាមួយនារីណា តើ<វាជាគណៈ>ស្រុក<>ឬ<អ្នកណាផ្សេង>?

[១១:០៤:១២]

**ឆ៖** កាលឲ្យខ្ញុំផ្គូងផ្គួរប្រវត្តិរូបខាងកងចល័ត ទាំងខាងប្រុស ខាងស្រីហ្នឹង ខ្ញុំគ្រាន់ជាអ្នកផ្គូផ្គងទេ តាមអាយុ និងឃុំជាមួយគ្នា។ ហើយបើជនថ្មី ជនជាតិចាស់ ថ្មី ចាស់អីហ្នឹងក៏ដោយឡែក។ ឯការសម្រេចអ្វីទាំងអស់ ខ្ញុំគ្រាន់តែត្រឹមផ្គូផ្គងតាមផែនការរបស់ បងផុន គណៈស្រុកទេ។ ឯដល់ពេលគេប្រកាស ទទួលស្គាល់ឲ្យអ្នកអស់ អ្នកមានគូស្រករពីពេលនេះតទៅ អាហ្នឹងគឺគណៈស្រុកទេ គាត់អ្នកប្រកាស។ ឯខ្ញុំគ្រាន់ជាអ្នកផ្គូផ្គងតាមផែនការឲ្យខ្ញុំធ្វើតាមផែនការគាត់កំណត់ផ្គូផ្គងអ៊ីចឹងទេ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ ហើយលោកក៏បាននិយាយពីករណី គឺថាមានការរៀបការពីរដែលលោកបានចូលរួម។ ហើយលោកនិយាយថា <ក្នុងមួយ>ពេល<>ៗ<គេរៀបការ>ប្រហែលរវាង<២០ទៅ>៣០<គូ>។ តើការរៀបការទាំងពីរហ្នឹងធ្វើឡើងនៅកន្លែងណា? ថាតើអ្នកណាខ្លះជាគណៈអធិបតី ឬក៏ជាអ្នករៀបចំការរៀបការទាំងពីរកន្លែងហ្នឹង?

**ឆ៖** ការរៀបចំទាំងពីរវគ្គហ្នឹង គឺលើ បងផុន –សៅ ផុន– ហ្នឹងគាត់ជាគណៈស្រុក។ ឯអ្នកមកចូលរួមគឺគណៈឃុំ គ្រប់ឃុំក្នុងស្រុកស្អាងមកចូលរួម។ ចូលរួម ហើយទទួលយកគូដែលរៀបការហ្នឹងនៅក្នុងឃុំរបស់ខ្លួន គណៈឃុំហ្នឹងយកទៅ ព្រោះរៀបការឲ្យរួច អត់នៅក្នុងកងចល័តទៀតទេ គឺទៅនៅសហករណ៍ អ៊ីចឹងទៅនៅតាមឃុំ សហករណ៍របស់ខ្លួន។ អ៊ីចឹងមេឃុំមួយៗនៅចាំទទួលហ្នឹងចូលរួមពេលនុ៎ង។

**ស៖** តើហេតុការណ៍រៀបការហ្នឹងគេធ្វើនៅកន្លែងណា? គេរៀបការនៅកន្លែងដូចជា ភូមិ ឃុំ ស្រុកណា?

[១១:០៦:៥៩]

**ឆ៖** រៀបការហ្នឹង កន្លែងហ្នឹងអនុវិទ្យាល័យទេ មិនមែនកន្លែងមន្ទីររបស់ស្រុកអង្កាល់សម័យនុ៎ង ឥឡូវមិនដឹងគេមានអីទៀតទេ ប៉ុន្តែកន្លែងចាស់ហ្នឹងធ្វើពិធីរៀបការឲ្យយុវជន យុវនារីហ្នឹងពេលហ្នឹង គេហៅថាមន្ទីររបស់ស្រុក។ សាលាស្រុកក៏នៅត្រង់ហ្នឹង អាសាលាអនុវិទ្យាល័យនៅត្រង់ហ្នឹង គេយកសាលាអនុវិទ្យាល័យហ្នឹង គេធ្វើជាកន្លែងប្រជុំរបស់ស្រុក ពេលនោះ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំក៏ចង់សួរសំណួរបន្តទៅទៀត អំពីអ្វីដែល

លោកបាននិយាយនៅក្នុងបទសម្ភាសន៍ពីររបស់លោក គឺបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា <E3/5643> ខ្មែរ 00059381, អង់គ្លេស 00753879, បារាំង 00756626។ លោកបាននិយាយថា សូមដកស្រង់៖ “ក្នុងសមត្ថភាពខ្ញុំជាប្រធាន ខ្ញុំបានរៀបចំការរៀបការ ដើម្បីអនុវត្តផែនការនៅតំបន់ <២៥>។” ចប់សេចក្តីដកស្រង់។ ហើយលោកបានបញ្ជាក់ស្រដៀងនេះដែរនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតគឺ E3/409 ចម្លើយ៧៥ លោកនិយាយថា៖ “ការរៀបការត្រូវបានធ្វើឡើងផ្អែកលើផែនការរបស់តំបន់”។ ចប់សេចក្តីដកស្រង់។ ហើយក្នុងបទសម្ភាសន៍ទាំងពីរនេះ លោកលើកឡើងថា ការរៀបការនេះគឺត្រូវធ្វើឡើងតាមផែនការរបស់តំបន់។ តើលោកនិយាយបែបនេះសំដៅទៅលើអ្វី?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

[១១:០៩:២៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាខ្ញុំមិនបានឮច្បាស់ទេលោកប្រធាន <ប៉ុន្តែ>ចម្លើយនេះនិយាយថា “គឺមិនមែនជាការរៀបការដោយបង្ខំទេ <ប៉ុន្តែការរៀបការគឺបានធ្វើឡើងដោយផ្អែកទៅលើផែនការរបស់តំបន់>។” គឺខ្ញុំមិនបានស្តាប់ចម្លើយទាំងស្រុង<នោះ>ទេ <ហើយខ្ញុំគិតថាវាសំខាន់សម្រាប់>កំណត់ត្រា<ប្រតិចារឹក> គឺ<>ប្រយោគនោះគួរតែ<អានឲ្យពេញលេញតែម្តង។> “គឺថាមិនមែនជាការរៀបការដោយបង្ខំនោះទេ <ប៉ុន្តែជាការរៀបការដែលធ្វើឡើងដោយផ្អែកទៅលើផែនការរបស់តំបន់>”។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** មិនបញ្ហាទេ។ សំណួរខ្ញុំលោកដើមបណ្តឹងរដ្ឋប្បវេណី តើអ្វីជាផែនការរបស់តំបន់? ដែលថាផែនការតំបន់ឲ្យរៀបការ តើមានអត្ថន័យដូចម្តេច?

**លោក សេង សឿន៖**

**ឆ៖** មិនយល់ថាហេតុអីនោះទេ ព្រោះវានេះតាមរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយដល់ដំណាក់កាលនេះ គឺថាត្រូវរៀបការឲ្យប្រជាជនទូទៅ មិនមែនតែខេត្តណាមួយទេ។ ត្រូវតែរៀបការ ព្រោះពីមុនហ្នឹងរឿងសង្គ្រាម ឥឡូវចប់សង្គ្រាមហើយ ត្រូវតែនេះ អាហ្នឹងជាផែនការ។ ឯខ្ញុំទទួលដឹងអីដឹងតែពីគណៈស្រុកទេដែលនៅ គាត់នៅផ្ទាល់នោះ ខ្ញុំបានដឹង អត់មានដឹងពីណាហ្នឹងទៀតទេ។ ប៉ុន្តែ

ទូទៅគេផ្សាយ ផ្សព្វផ្សាយថា ទូទាំងប្រទេស គេក្រោយចប់សង្គ្រាមហើយទេ ត្រូវតែរៀបការអ៊ីចឹង។

[១១:១១:០៣]

**សៈ** លោកបានឆ្លើយព្រឹកមិញនេះថា លោកទទួលបញ្ជាពីគណៈស្រុក គឺឲ្យរៀបការនារីគឺដែលត្រូវរៀបការហ្នឹង ត្រូវមានអាយុតិចជាងបុរស២ ឬ៣ឆ្នាំ។ ហើយលោកបាននិយាយឆ្លើយទៅសហចៅក្រមស៊ើបអង្កេតហ្នឹង ស្រដៀងនេះដែរ គឺថាឯកសារ E3/409 ត្រង់ចម្លើយ៦៧៖ “សំណួរ៖ តើមានគោលនយោបាយអ្វីដែលណែនាំមកពីរបបខ្មែរក្រហមថា មនុស្សត្រូវតែរៀបការនោះ? ហើយលោកឆ្លើយថា៖ គឺមានគោលនយោបាយពីរបបខ្មែរក្រហម ដែលថានៅពេលដែលមនុស្សមានអាយុក្នុងកម្រិតមួយ គេត្រូវតែរៀបការ។ ចំពោះស្រី គឺត្រូវមានអាយុពី២០ឡើង ហើយ<>បុរសអាចមានអាយុពី២៥ឬក៏លើសពីហ្នឹង។” អ៊ីចឹងសំណួរថា តើផែនការ ឬនយោបាយដែលលោកនិយាយនេះ តើលោកបានឮហេតុផលអ្វី ដែលថានារីត្រូវរៀបការចាប់ពីអាយុ២០ឡើង ហើយបុរសត្រូវមានអាយុលើសពីកម្រិតមួយ ឬខ្ពស់ពីហ្នឹង? តើគេបានបញ្ជាក់មូលហេតុអ្វីដែរឬទេ កាលនោះ?

**ឆៈ** ខ្ញុំនៅចាំ គឺតាមការប្រជុំណែនាំរបស់គណៈស្រុក ហើយប្រហែលហៅគណៈឃុំមកទាំងអស់ ក្នុងស្រុកស្អាងហ្នឹង ឲ្យគាត់ដឹង ផ្សព្វផ្សាយថា ត្រូវធ្វើតាមផែនការហ្នឹងដែលត្រូវដល់អាយុហើយហ្នឹង ត្រូវរៀបការឲ្យគេតាមឃុំរៀងខ្លួន។ ដោយឡែក ដែលខ្ញុំបានធ្វើបញ្ជីរៀបការនេះ អាហ្នឹងគេហៅជាកងចល័តរបស់ស្រុកទេ ឯក្រៅពីហ្នឹង គឺរៀបការតាមឃុំសហករណ៍របស់ខ្លួន។ អ៊ីចឹងមេឃុំមួយៗចាត់តាំងដោយខ្លួនឯង។ ខ្ញុំបាននិយាយសព្វថែម។

**សៈ** នៅពេលដែលគណៈស្រុកពន្យល់ពីផែនការហ្នឹង តើគាត់ពន្យល់មូលហេតុដែរឬទេថា ហេតុអ្វីដែលថា គេឲ្យនារីចាប់ពីអាយុ២០ឡើងហ្នឹងត្រូវរៀបការ? តើគេមានបញ្ជាក់មូលហេតុពន្យល់ទេ?

**ឆៈ** បាទ អត់ពន្យល់អី ពន្យល់អីទេ ប៉ុន្តែគ្រាន់តែផ្សព្វផ្សាយ ហើយនិងគេហៅផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណឹង។

[១១:១៤:១៦]

**សៈ** សូមអរគុណដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះខ្ញុំត្រឡប់ទៅប្រធានបទមួយផ្សេងទៀត ជាហេតុការណ៍ដែលកើតឡើងនៅក្នុងស្រុកស្អាង ដែលលោកបានរៀបរាប់ជាលម្អិតនៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមលោកជម្រាបតុលាការ តើមានអ្វីកើតឡើងចំពោះប្រជាជនវៀត-

ណាម ហើយនិងពួកចិនដែលរស់នៅក្នុងស្រុកស្អាងនៅក្នុងឆ្នាំ១៩៧៨ បន្ទាប់ពីលោកបានទៅដល់ទីនោះ ហើយធ្វើការនៅមន្ទីរស្រុកនោះ?

**ឆ៖** ខ្ញុំទៅដល់ស្រុកស្អាងហ្នឹង ខ្ញុំជួបតែបញ្ហាមួយដែលចម្លែកខុសគេ គឺតាមបញ្ហា មិនដឹងថ្នាក់ណាទៀត ហើយខ្ញុំក៏អត់ដឹង តែលួចស្ដាប់ដោយដឹង មិនមែនគេរាយការណ៍មកទេ គឺគេប្រមូលជនជាតិយួន ចិន យកមកដឹក គេសម្លាប់ចោលនៅកោះគរ។ នេះអាហ្នឹងមិនមែនថាឮគេថាទេ អាហ្នឹងខ្ញុំឃើញផ្ទាល់ភ្នែក ហើយខ្ញុំទៅសូមមើលគេកន្លែងគេសម្លាប់ពួកដែលយកមកហ្នឹងទៀត។ តែអាប្រធានគុកកោះសាគរហ្នឹង វាអត់ឲ្យខ្ញុំចូល ខ្ញុំ អេ្ហ! ចង់ដឹងអ្ហ៎! ឯងមានសិទ្ធិធ្វើប្រធានមន្ទីរស្រុកហើយ អញ! ខ្លាចអីអ្ហ៎ មើលអញទៅបម្រាស់តែម្ដង ចូលមែន ឡើងទៅកោះ ទៅឃើញមែន គេសម្លាប់។ បានខ្ញុំឃើញនឹងភ្នែកពិតប្រាកដ តែខ្ញុំឃើញម្ដងហ្នឹង។ តែគេ មុនហ្នឹងតាមគេរាយការណ៍ឈ្មោះនេះមកឲ្យនៅមន្ទីរស្រុកហ្នឹងវាដល់ទៅបីសាហើយ ប្រមូលចិនហើយនិងយួនមកសម្លាប់នៅកោះគរ។ តែខ្ញុំឃើញផ្ទាល់ភ្នែក ឯឈ្មោះៗនៅបញ្ជីគេយកឲ្យខ្ញុំមែន តែខ្ញុំមិនបានមើល ខ្ជិលមើលណ៎ា ព្រោះគេសម្លាប់ហើយយកឈ្មោះធ្វើអី។ អាហ្នឹងរឿងពិតរបស់ខ្ញុំនៅស្រុកស្អាង។

[១១:១៦:៤៥]

**ស៖** លោកបានបញ្ជាក់ថា ពួកចិន ហើយនិងពួកយួននោះ ត្រូវបានគេប្រមូល ហើយយកទៅសម្លាប់នៅកន្លែងមួយហៅថា“កោះគរ”។ តើជាកោះហ្នឹងគឺទីតាំងវាឋិតនៅកន្លែងណា? <តើ>ជា<ទី-តាំង>មន្ទីរសន្តិសុខស្រុក ឬក៏ជាទីតាំងសម្លាប់មនុស្ស? តើនៅឋិតនៅក្នុងភូមិអី ឬក៏កន្លែងណា? សូមលោកបន្ថែមបន្តិច។

**ឆ៖** ខ្ញុំភ្លេចហើយឈ្មោះ។ ទៅពី ចេញពីក្រចេះទៅមិនដឹងមានកោះមួយ ដូចកោះអន្លង់ចិនអីហើយបានដល់កោះគរហ្នឹង ប៉ុន្តែខ្ញុំវាភ្លេចអស់ទៅ អារឿងថាក៏ថាមិនត្រូវដែរ។ ប៉ុន្តែកោះហ្នឹងក្នុងស្រុកស្អាងហ្នឹង។ បាទខ្ញុំនៅចាំគេយកកន្លែងហ្នឹង ពីមុនគេដាំដំណាំអី ធ្វើការធំដុំពីមុនហ្នឹង ដល់សម័យហ្នឹងវាកើតជាកន្លែងយកដាក់អ្នកទោសទៅសម្លាប់ ចាប់ពីមាន១២ មេសា អីមកនៅត្រង់ហ្នឹង រហូតជនជាតិភាគតិច ដូចចិន យួន វិះនឹងចាមទៀតហើយកាលហ្នឹង ប៉ុន្តែខ្ញុំវាដូចក្រោយគេដែលទេមកនៅ។ កាលហ្នឹងធ្វើហ្នឹង ពេលសម័យហ្នឹង បងផុន នៅគណៈស្រុកហ្នឹង ដែលខ្ញុំទៅនៅនឹងគាត់។ បានខ្ញុំទៅឃើញស្គាល់នឹងភ្នែករឿងកោះគរ ដែលកន្លែងគេប្រមូលទៅសម្លាប់។

**ស៖** លោកបានបញ្ជាក់ថា លោកបានទៅដល់ស្រុកស្អាងនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨។ តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្រោយពីទៅដល់រយៈពេលប៉ុន្មានបានគេកំណត់យកពួកប្រជាជន<ចិន> ហើយនិងប្រជាជនវៀតណាម ដើម្បីយកទៅសម្លាប់នោះ?

ឆ៖ ពេលហ្នឹងខ្ញុំទៅនៅមិនពិតប្រាកដទេ គ្រាន់តែថា មុនគេរៀបការឱ្យខ្ញុំ រៀបការប្រពន្ធហ្នឹង រួចបានហ្នឹង ខ្ញុំផ្លាស់ទៅក្រចេះហ្នឹង តែរកពេលកំណត់ អត់ចាំ ព្រោះភ្លេចថ្ងៃខែអស់ហើយពេលនោះដល់ ឥឡូវ។

[១១:១៩:៣២]

ស៖ លោកបានបញ្ជាក់ខាងដើមនេះបន្តិចថា លោកបានឃើញបញ្ជី<ឈ្មោះមនុស្ស>ដែលគេ <រៀបចំដើម្បី>សម្លាប់។ តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើគេកំណត់ជនជាតិវៀតណាម និងចិន ហើយដាក់លើបញ្ជីហ្នឹង គេកំណត់ដូចម្ដេច តើលោកអាចដឹងបានទេ? <តើនរណាជាអ្នករៀបចំបញ្ជី ហ្នឹង?>

ឆ៖ ខ្ញុំបានទទួលបញ្ជីឈ្មោះដែលត្រូវសម្លាប់តាមឃុំមួយៗ គេ ដែលមានជនជាតិយួន ចិន។ ខ្ញុំ គ្រាន់បានតែមើលទៅ ប៉ុន្តែទិសដៅទៅមុខអីយ៉ាងម៉េចៗ ខ្ញុំអត់ដឹង គ្រាន់មើលតែសៀវភៅបញ្ជីឈ្មោះ ហ្នឹងទៅ។ គណៈស្រុកក៏អត់ប្រាប់ថា បញ្ជីម្រយហ្នឹងត្រូវធ្វើអីទៀត បានតែប៉ុណ្ណឹងបាន ខ្ញុំអត់ដឹងអីទៀត ទេ។

ស៖ នៅពេលដែលលោកបានទទួលបញ្ជីពួកជនជាតិចិន និងវៀតណាមនោះ <មកពីតាមឃុំ នីមួយៗ> តើលោកបានបញ្ជីហ្នឹងហើយ តើលោកផ្ដល់ទៅឱ្យអ្នកណាបន្តទៀត ឬក៏ធ្វើអ្វី?

ឆ៖ បញ្ជីដែលតាមឃុំមួយគេឱ្យមកខ្ញុំទុកហ្នឹង ទុកចោលត្រង់ហ្នឹង មានយកទៅណាទេ នៅតែ កន្លែងខ្ញុំនៅហ្នឹង មន្ទីរស្រុកហ្នឹង។

ស៖ តើអ្នកណាជាអ្នកប្រមូលប្រជាជនទាំងអស់ហ្នឹង ហើយយកទៅកោះគរ? តើអ្នកណាជា អ្នកប្រមូល ហើយដឹកញ្ជូនអ្នកទាំងហ្នឹងទៅកោះគរ?

ឆ៖ ហ្នឹងតាមឃុំរៀងខ្លួនហ្នឹង។ ឃុំណា មានប៉ុន្មាន តាមបញ្ជីឈ្មោះហ្នឹង ដឹកទូក កាណូតហ្នឹង របស់ខ្លួន ឃុំខ្លួនឯងមក យកមកកោះគរហ្នឹងទៅ។ អាអ្នកនៅកោះគរមានប្រធាន កូនចៅគេពេញហ្នឹង គេចាំទទួលទៅ ចាក់ខ្មោះ ចាក់អីហ្នឹង។ អាហ្នឹងគេ កន្លែងរបស់គេត្រង់ហ្នឹងទៅ។

[១១:២២:៣០]

ស៖ នៅមុននេះបន្តិច លោកបានបញ្ជាក់ថា ខ្លួនលោកផ្ទាល់បានចូលទៅកន្លែងគេសម្លាប់មនុស្ស

ហើយបានឃើញពីអ្វីដែលកើតឡើងនៅទីនោះ ថាលោកបានទៅកោះគរ។ សុំលោកប្រាប់តុលាការ តើលោកបានឃើញអ្វីខ្លះនៅកោះគរ នៅពេលដែលលោកទៅនោះ?

**ឆ៖** ពេលនោះខ្ញុំដូចជានឹកចុះឡើងចុះឡើង មិន -- ការពិតខ្ញុំអត់មានសិទ្ធិទៅត្រួតត្រាទេអាកន្លែងកោះគរហ្នឹង។ ប៉ុន្តែដូចជាចង់ដឹង ហើយអត់ឲ្យគណៈស្រុក បងផុន ហ្នឹងគាត់ដឹងទេ។ ខ្ញុំទៅហើយឲ្យនីរសារជូនទៅ ទៅដល់ឆ្លងទឹកទៅលើកោះ ចង់ដឹងរឿង។ ទៅបានឃើញគេចាប់អាអ្នកមុនមិនទាន់គេសម្លាប់នោះ គេគណៈឃុំអីមួយជំនាន់ពីរបីនាក់ អ្ហ៎! អត់បាយអត់ទឹក ស្គមកំព្រឹងកំព្រោម។ ហើយថាពេលនេះ គេត្រូវសម្លាប់ចោល។ គេសម្លាប់អាប្រុសៗមុន ស្រីៗក្រោយ។ ខ្ញុំឃើញបន្តិច បានខ្ញុំអ្ហ៎! អត់កើតទេ។ ខ្ញុំក៏ដាក់លេខ*អាយែរ*មកកោះ មកកន្លែងវិញមក បានតែប៉ុណ្ណឹង ខ្ញុំ។

**ស៖** តើលោកបានឃើញដោយផ្ទាល់ភ្នែកថា ជនជាតិវៀតណាម ហើយនិងជនជាតិចិនដែលត្រូវគេសម្លាប់នៅកោះគរហ្នឹងដែរឬទេ? ក្នុងករណីដែលឃើញ ថាតើគេសម្លាប់អ្នកទាំងអស់នោះ ដោយរបៀបណា?

**ឆ៖** ខ្ញុំឃើញនៅកោះគរ កាលហ្នឹងខ្ញុំឃើញនឹងភ្នែកដែលខ្ញុំលួចទៅមិនឲ្យសុំ ឲ្យគណៈស្រុកដឹងទេ ចង់ដឹង។ ទៅគេសម្លាប់ចិន និងយួន បោសសម្អាតហ្នឹង។ ពាក្យ "សម្អាត" សម័យខ្មែរក្រហម គេប្រើពាក្យថា "បោសសម្អាត" អត់ឲ្យមានជនជាតិអីផ្សេងក្រៅពីខ្មែរទេ។ ហើយវ៉ៃហ្នឹង ខ្ញុំឈរមួយភ្លែតឃើញគេមួយប្រាវហ្នឹង គេវ៉ៃមួយសា១០ដាក់ ចងឃ្នុំមុខអស់ហើយ អាអ្នកវ៉ៃគេម្នាក់ៗ ម្នាក់វ៉ៃ១០ ម្នាក់វ៉ៃម្នាក់ ម្នាក់វ៉ៃម្នាក់ហ្នឹង ប្រាវៗហ្នឹង អស់១០អីចឹងទៅ បានគេអូសអីចឹងទៅ។ ខ្ញុំរួចក៏ ខ្ញុំបានហើយ តែប៉ុណ្ណឹងដឹងហើយ តិចដល់វេនអញវិញហើយយ៉ាងមើលទៅ គ្រាន់តែគិតក្នុងចិត្តទេ។ បានតែប៉ុណ្ណឹងខ្ញុំ។

[១១:២៥:៤០]

**ស៖** លោកបាននិយាយថា គេប្រើពាក្យថា "បោសសម្អាត" ហើយគេមិនចង់ឲ្យមានពូជសាសន៍ណាផ្សេងក្រៅពីខ្មែរទេ។ តើលោកបានឮពាក្យនេះពីអ្នកណា?

**ឆ៖** ពាក្យនេះ មិនមែនថា ណាក៏ឮដែរ តែខ្ញុំគ្រប់វគ្គរៀនសូត្រតាមកាលសម័យខ្ញុំមិនទាន់ មកនៅស្រុកស្អាងនេះក៏ដោយ ពាក្យនេះគឺថា មាគ៌ារបស់បក្សកុម្មុយនីស្តហ្នឹង បោសសម្អាតៗ។ នេះគឺខ្ញុំនៅចងចាំពាក្យគេហ្នឹងរហូតទៅ។ ដល់អីចឹងគេធ្វើបន្តបន្ទាប់មែន។

**ស៖** លោកបាននិយាយថា លោកបានឮពាក្យហ្នឹងពីវគ្គសិក្សារៀនសូត្រ ឬការប្រជុំ ថាតើលោកចៅចាំអ្នកណាជាអ្នករៀបចំការវគ្គរៀនសូត្រហ្នឹង ដែលគេប្រកាសពាក្យហ្នឹង?

**ឆ៖** ពាក្យហ្នឹងខ្ញុំ កាលហ្នឹងនៅជួរខ្មែរក្រហម គេមានបើកវគ្គនិងរៀនសូត្រ។ ពាក្យថា "វគ្គៗ" ហ្នឹង គឺ៣ថ្ងៃរៀនជួបជុំ ការណែនាំថ្នាក់អភិបាលបន្តបន្ទាប់។ អាមួយថ្នាក់រៀនសូត្រ អាហ្នឹងមួយអាទិត្យ។ អ៊ីចឹងខ្ញុំតាមពាក្យហ្នឹងតាំងពីខ្ញុំនៅពិការប៉ុន្មាននោះទេ មិននៅរៀនសូត្រ តែក្នុងជួរទ័ព ក៏ខ្ញុំមករៀនសូត្រ កាលខ្ញុំនៅទ័ពដែរ ទ័ពរបស់តំបន់តាកែវហ្នឹង វាមានឈ្មោះ សោម គណៈតំបន់១៣អីហ្នឹង។ គេសុទ្ធតែប្រើពាក្យហ្នឹងហើយ "បោសសម្អាត"។ ឯឮពេញពី តាម៉ុក របស់ភូមិភាគ មិនសូវឮស្គាល់ទេ គាត់គ្រាន់តែណេះណោះ អ្នេរអ្នូទៅ គាត់ដើរទៅបាត់ទៅ។

[១១:២៨:២០]

**ស៖** បាទ អ៊ីចឹងត្រឡប់មកនិយាយពីការសម្លាប់ជនជាតិវៀតណាម និងជនជាតិចិននៅស្រុកស្អាង។ លោកនិយាយមួយចំនួននៅក្នុងការសម្ភាសទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា មនុស្សជាច្រើនត្រូវបានគេសម្លាប់ទៅតាមផែនការរបស់គេ។ លោកនិយាយអំពីបញ្ជី តើលោកអាចនិយាយប៉ាន់ចំនួនប៉ាន់ប្រមាណនៃជនជាតិចិន ហើយនិងជនជាតិវៀតណាម ដែលត្រូវបានគេសម្លាប់នៅស្រុកស្អាង នៅពេលដែលលោកទៅទីនោះក្នុងឆ្នាំ១៩៧៨ ហ្នឹងបានទេ?

**ឆ៖** ខ្ញុំមិនអាចយកចំនួនឲ្យពិតប្រាកដ ឬក៏គិតជាភាគរយក៏មិនបាន ព្រោះខ្ញុំឃើញ ខ្ញុំឃើញម្ដង ប៉ុន្តែមិនដឹងគេធ្វើបានប៉ុន្មានដងហើយ ប៉ុន្តែខ្ញុំទៅឃើញម្ដងហ្នឹង ដែលខ្ញុំទៅ ថាលួចកុំឲ្យគណៈស្រុកគាត់ឃើញ អត់ដឹងថាខ្ញុំទៅទេ។ ខ្ញុំឃើញម្ដង ប៉ុន្តែខ្ញុំឃើញម្ដងហ្នឹង គេប្រមូលតាមឃុំ ព្រោះច្រើនឃុំដែរ នៅស្រុកស្អាង។ ខ្ញុំគិតទៅប្រហែលពីមិនពី១០០នាក់ បើមិនខ្វះ ឬលើស ក៏ប្រហាក់ប្រហែលប៉ុណ្ណឹង តាមដែលខ្ញុំឃើញប៉ាន់មួយសា ហ្នឹងគិតទាំងប្ដីប្រពន្ធ និងកូនតូច។ តាមខ្ញុំប៉ាន់ដឹង កាលណោះ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំអាចឈប់ត្រឹមហ្នឹង ឬក៏អាចបន្ត?

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកអាចសម្រាកបានហើយ អង្គជំនុំជម្រះអញ្ជើញលោកមកកាន់កន្លែងផ្ដល់សក្ខីកម្មវិញ ឲ្យបានមុនម៉ោងមួយកន្លះរសៀល។

បង្គាប់ឲ្យអនុរក្សពន្ធនាគារ -- មន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ យើងបានជជែកគ្នាអំពីការសម្លាប់ជនជាតិវៀតណាម ហើយនិងជនជាតិចិននៅក្នុងស្រុកស្អាង។ ខ្ញុំចង់សួរលោក សំណួរមួយចំនួនទាក់ទងទៅនឹងរបាយការណ៍ប្រចាំខែដែលយើងទទួលបានជាភស្តុតាង គឺឯកសារ E3/1094 គឺ E3/1094 លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកអាចអានអក្សរបានទេ? របាយការណ៍មួយ ឬក៏ងាយជាងឲ្យខ្ញុំអានសេចក្ដីដកស្រង់ឲ្យលោកស្ដាប់ស្រួលជាង?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំអានអត់កើតទេឥឡូវ មើលអក្សរមិនទាំងស្គាល់ផង។

[១៣:៣១:៤៦]

**ស៖** គឺមានបញ្ហាពីរបីដែលខ្ញុំចង់សួរលោកអំពីឯកសារនេះ គឺដំបូងលោកបាននិយាយនៅក្នុងបទសម្ភាសន៍មួយ លោកនិយាយអំពីរបាយការណ៍ដែលគេរៀបចំនៅពេលដែលលោកនៅមន្ទីរស្រុកស្អាងនៅពេលនោះ។ របាយការណ៍នេះ គឺ<ជារបាយការណ៍ប្រចាំខែផ្ញើ>មកពីភូមិភាគបស្ចិម គេបែងចែកទៅជាពីរបីផ្នែក។ ផ្នែកទី១ ក្នុងរបាយការណ៍និយាយអំពីការការពារប្រទេស ហើយនិងស្ថានភាពខ្មាំង។ ទី២ និយាយអំពីការកសាងសង្គមនិយម ដែលមានន័យថា កសាង លើកទំនប់ ជីកប្រឡាយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្នែកទី៣ គេរាយការណ៍អំពីជីវភាពរស់នៅរបស់ប្រជាជន។ តើលោក<ស្គាល់ពីទម្រង់នៃ>របាយ-ការណ៍នេះ<ទេ? តើវាដូចគ្នានឹងប្រភេទទម្រង់របាយការណ៍ដែលលោកបានប្រើ> នៅពេលដែលលោកធ្វើការស្រុកស្អាង ហើយក៏នៅក្នុងក្រចេះផងដែរ<ទេ>? តើទម្រង់បែបបទនៃរបាយការណ៍វាបែបនេះដែរឬទេ?

**ឆ៖** រឿងនេះ ជាទូទៅគឺផែនការរបស់រដ្ឋាភិបាលទេ អ៊ីចឹងមិនមែននរណាម្នាក់គ្រាន់តែថា ទៅរៀនសូត្របន្តៗតាមថ្នាក់ទេ ព្រោះជាផែនការរបស់បក្សទាំងមូល មិនមែនរបស់គណៈស្រុក គណៈតំបន់ណាទេ ផែនការហ្នឹង។

[១៣:៣៣:២៦]

**ស៖** ខ្ញុំសូមអានសេចក្ដីដកស្រង់សង្ខេបចេញពីកំណត់ហេតុស្ដាប់ចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតគឺ E3/409 សំណួរចម្លើយ៤៩ សំណួរសួរថា៖ “<តើ>តំបន់រាយការណ៍ជាទៀងទាត់ទៅ<គណៈមជ្ឈិម>ពីបញ្ហាការសម្លាប់<ទេ>? ហើយលោកឆ្លើយថា៖ យើងបានជូនដំណឹងទៅគណៈមជ្ឈិម<អំពីបញ្ហាផ្សេងៗ>ជារៀងរាល់ខែម្ដង។ យើងជូនដំណឹងពីស្ថានភាពខ្មាំង ការបង្កបង្កើតផល ហើយនិងស្ថានភាពទូទៅរបស់ប្រជាជន។” ចប់សេចក្ដីដកស្រង់។ សំណួរ តើនៅកន្លែងណាដែលលោកដឹងថា របាយការណ៍ប្រចាំខែ ដែលនិយាយពីបញ្ហាទាំងអស់នេះ? ពេលដែលលោកដឹងថាមានរបាយការណ៍ហ្នឹង លោកធ្វើការនៅកន្លែងណា?

**ឆ៖** កាលខ្ញុំនៅស្រុកស្អាង ការរាយការណ៍ពីក្រោមមកគឺថ្នាក់ឃុំ រាយមក ជូនមកស្រុក ប៉ុន្តែខ្ញុំជាអ្នកចាំទទួលបូកសរុបរបាយការណ៍របស់ឃុំទាំងអស់ដែលជូនមកស្រុកហ្នឹង។ អាហ្នឹងគឺខ្ញុំនៅមន្ទីរស្រុកតែម្ដង កន្លែង។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងរបាយការណ៍ប្រចាំខែនេះដែលធ្វើនៅភូមិភាគបស្ចិម គឺសម្រាប់ខែកក្កដា ឆ្នាំ១៩៧៨ គឺរយៈកាលដែលលោកបញ្ជាក់ថា លោកនៅក្នុងស្រុកស្អាង។ ហើយរបាយការណ៍នេះគឺនៅក្នុងទំព័រខ្មែរ 00143610, អង់គ្លេស 00315374, បារាំង 0059 3530។ របាយការណ៍ គឺនិយាយអំពីតំបន់៣៧ និយាយអំពីសម្រិតសម្រាំងខ្មាំង ហើយនិងសមាសភាពមិនល្អ។ ចំណុចទី១ នៅក្នុងរបាយការណ៍នេះ ក៏សូមដកស្រង់៖ “កម្ទេច<>ជនជាតិយួន១00នាក់ទាំងអ្នកតូច ធំ មនុស្សចាស់ ហើយនិងកុមារ។” ចប់សេចក្ដីដកស្រង់។ ដើមបណ្ដឹងរដ្ឋប្បវេណី <>របាយ-ការណ៍នេះមកពីភូមិភាគបស្ចិម ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ គឺ<សម្រាប់ខែ>កក្កដា ឆ្នាំ១៩៧៨ តើ

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01355196



ក្នុងអំឡុងពេលហ្នឹងឬ ដែលថាគេបានសម្លាប់ជនជាតិវៀតណាមនៅក្នុងស្រុកស្អាងហ្នឹង?

[១៣:៣៦:៤៤]

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំជំទាស់នឹងសំណួរនេះ ដោយ>ខ្ញុំគិតថាសំណួរនេះ គឺដឹកមុខទៅសាក្សីហើយលោកប្រធាន។

**លោក ឌេល លីសាក់៖**

លោកប្រធានយើងបានសួរសំណួរ<បើកទៅ>សាក្សីរួចហើយពីមុន <សាក្សី>បញ្ជាក់<ថា គាត់មិនច្បាស់ថា>ខែ<ណា>ទេ ប៉ុន្តែគាត់ថានៅក្នុងស្រុកស្អាងមុនពេលដែលគេរៀបការគាត់។ អ៊ីចឹង <>ខ្ញុំ<គិតថា នេះជាសំណួរសមស្របក្នុងការ>រំឭកការចងចាំពីពេលវេលា<ថាតើព្រឹត្តការណ៍នោះកើតឡើងនៅពេលណា>។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកនឹកឃើញពីអ្វីដែលលោកចងចាំទេលោកដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលថាហេតុការណ៍ហ្នឹងកើតឡើងប្រហែលក្នុងរវាងខែកក្កដា ឆ្នាំ១៩៧៨ ដែលថាការសម្លាប់វៀតណាមហ្នឹងកើតឡើងនៅក្នុងស្រុកស្អាងនាពេលនោះ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំមិនអាចចងចាំបានទាំងអស់ទេក្នុងរឿងនេះ ប៉ុន្តែខ្ញុំគ្រាន់តែនឹក ហើយចាំក្នុងចិត្តកាលណោះ គេឲ្យទិសដៅថា "យួនត្រូវសម្លាប់"។ ឧបមាថាប្រុសខ្មែរយើងទៅយកប្រពន្ធយួន ហើយមានទាំងកូន ពេលនោះយកតែប្រពន្ធ ស្រីយួនៗទៅទេដែលត្រូវសម្លាប់។ ឯកូនមួយកំណាត់ទុក ហើយនិងឪពុកក៏ទុកវិញ។ អាហ្នឹងខ្ញុំនៅចង់ច្បាស់តែប៉ុណ្ណឹងទេ ឯផ្សេងទៀតអត់ដឹងចាំទេ។

[១៣:៣៨:៣៨]

**ស៖** លោកបានបញ្ជាក់ថា លោកដឹង ឬក៏បានស្គាល់អំពីរបាយការណ៍ដែលគេធ្វើឡើងនៅស្រុកស្អាង។ តើលោកនៅចាំដែរឬទេ នៅស្រុកស្អាង<>គេដាក់បញ្ចូលនៅក្នុងរបាយការណ៍<> ដូចដែលភូមិភាគបស្ចិមធ្វើដែរឬទេ ដែលថាគេរាយការណ៍ទៅថ្នាក់លើអំពីការសម្លាប់ជនជាតិវៀតណាម ហើយនិងជនជាតិចិននៅក្នុងស្រុកនៅពេលនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ផ៖** តាមខ្ញុំនៅចាំ អត់រាយការណ៍ឡើងទៅទៀតទេ ព្រោះគេដាក់ផែនការឲ្យមកធ្វើអ៊ីចឹង ត្រូវអនុវត្តទៅបានហើយ មិនបាច់រាយការណ៍ថា សម្លាប់បានប៉ុន្មានអីប៉ុន្មានទេ។ ខ្ញុំតាមអ្នកកត់ត្រាដែលគេបញ្ជូនមកឲ្យខ្ញុំតាមឃុំមកហ្នឹង គ្រាន់តែដឹងឈ្មោះៗហើយ ទុកចោលនៅហ្នឹង អាដែលគេត្រូវសម្លាប់ហ្នឹងក៏ គេអត់ពូនិយាយអីទៀតទេ ចប់ត្រឹមហ្នឹង។

**ស៖** តើលោកបានឃើញដោយខ្លួនឯងទេថា ស្រុកធ្វើរបាយការណ៍ទៅតំបន់? តើលោកដឹងថាតើគណៈស្រុកដាក់បញ្ចូលនៅក្នុងរបាយការណ៍ពីចំនួនជនជាតិវៀតណាម ដើម្បីរាយការណ៍ទៅថ្នាក់លើទេ? តើលោកបានឃើញរបាយការណ៍ ឬឃើញគណៈស្រុកហ្នឹងរាយការណ៍ទៅតំបន់ដោយផ្ទាល់ទេ?

**ផ៖** បាទ ខ្ញុំអត់បានដឹងទេ ព្រោះកិច្ចការហ្នឹងគណៈស្រុកប្រជុំរាល់អាទិត្យ -- ជួនអាទិត្យ ជួនមួយខែទៅកន្លែងតំបន់។ ដល់អ៊ីចឹងខ្ញុំអត់ដឹង មិនដឹងគេប្រជុំរឿងអី ផែនការអី ខ្ញុំអត់ដឹងដែរ។

[១៣:៤០:៤៩]

**ស៖** សូមទោស ខ្ញុំចង់សួរឲ្យយើងបានព័ត៌មានច្បាស់។ លោកបានឃើញរបាយការណ៍មកពីឃុំ ប៉ុន្តែលោកមិនបានឃើញរបាយការណ៍ដែលស្រុកគេរៀបចំដើម្បីផ្ញើទៅតំបន់ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ផ៖** បាទ អាហ្នឹងខ្ញុំដឹង ជារឿងពិត។

**ស៖** ចំណុចមួយទៀតដែលខ្ញុំចង់សួរលោក ទាក់ទងទៅនឹងរបាយការណ៍ប្រចាំខែ ដែលទទួលមកពីភូមិភាគបស្ចិមគឺ E3/1094 <នៅ>ទំព័រ<ចុងក្រោយ>មានតារាង ដែលភូមិភាគរាយការណ៍អំពីចំនួនទារកកើត ហើយនិងចំនួនអ្នកដែលរៀបការនៅក្នុងប្រចាំខែ។ តើលោកចាំដែរឬទេ នៅក្នុងស្រុកស្អាង តើគេមានរបាយការណ៍ដែលបញ្ជាក់ពីកំណើតកូន ហើយអំពីចំនួនមនុស្សរៀបការប្រចាំខែ គេរាយការណ៍ពីស្រុកទៅតំបន់? តើលោកចាំថា <តើគេមាន>របាយការណ៍បែបនេះទេ?

**ផ៖** រឿងហ្នឹង ខ្ញុំបានចាំ ហើយគេរាយការណ៍តាមឃុំមកឲ្យ ខ្ញុំបូកសរុប ដោះស្រាយឲ្យស្រុក។ ខ្ញុំបានដឹង បានទទួល ប៉ុន្តែឲ្យខ្ញុំយកដឹងជាការពិតទៅ ខ្ញុំលែងដឹងអស់អាហ្នឹង វង្វេងវង្វាន់អស់ទៅហើយបាទ។

**ស៖** ខ្ញុំចូលទៅប្រធានបទមួយទៀត លោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកបានធ្វើសក្ខីកម្មថ្ងៃនេះ ដែលវិធីដែលលោកដឹងពីគោលនយោបាយរបស់បក្សកម្មុយនីស្តកម្ពុជា តាមរយៈវគ្គរៀនសូត្រដែលថា គោលនយោបាយខ្លះ លោកដឹងពី សោម ដែលជាគណៈតំបន់១៣ ហើយនិង<តាមរយៈ>ការ<ប្រជុំនិងការ>ណែនាំមកពីថ្នាក់លើ។ ប្រធានបទដែលខ្ញុំចង់សួរលោកនៅពេលនេះគឺថា តើនៅក្នុងរបបខ្មែរ

ក្រហម ចំពោះអ្នកដែលគេកំណត់ថាជាអតីតមន្ត្រីរបបមុន ទាហាន លន់ នល់ របបមុននោះ ជាពិសេស អ្នកដែលមានបណ្ដាស័ក្តិ តើពួកនោះជួបបញ្ហាអ្វីដែរទេ? តើលោកដឹងថា មានគោលនយោបាយដូចម្ដេច ទាក់ទង ឬក៏សំដៅអ្នកទាំងអស់នោះដែរឬទេ?

[១៣:៤៣:៤០]

**ឆៈ** តាមខ្ញុំដឹង រឿងនេះឲ្យតែរឿងចាស់របស់សម័យមុន គឺទាហាន លន់ នល់ តាំងជំនាន់សម្ដេច សីហនុ មកៗ ឲ្យតែអ្នកបម្រើរាជការខ្លះ ទាហាន ប៉ូលិសចាស់អីហ្នឹង សល់តិចណាស់។ ភាគច្រើន គឺថាពួកប្រវត្តិរបបចាស់កម្រិល គេត្រូវបោសសម្អាតហើយអាហ្នឹង។ ផែនការ តាមខ្ញុំស្ដាប់ពេលដែលខ្ញុំបានទៅរៀនសូត្រម្ដងៗ អាហ្នឹងជាទិសដៅរបស់បក្សទូទាំងប្រទេសតែម្ដង ត្រូវតែបោសតែម្ដង មិនត្រូវទុកទេ។

**សៈ** សូមអរគុណ។ ខ្ញុំសួរសំណួរបន្តពីនេះបន្តិច នៅក្នុងចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតគឺ <E3409>*(ស៊ីក)* គឺចម្លើយ៤៣ ដល់៤៤ នៅក្នុងឯកសារនោះ លោកបានពិភាក្សាអំពីកន្លែងលត់ដំ។ លោកសរសេរដូចខាងក្រោមនេះ៖ “អ្នកដែលធ្វើខុស គេបញ្ជូនទៅ<ធ្វើការនៅ>កន្លែងនោះ។ បើសិនជាខ្មែរក្រហមរកឃើញថា អ្នក<ទាំងនោះ>ធ្លាប់ធ្វើជាទាហាន លន់ នល់ គេនឹងសម្លាប់អ្នកទាំងនោះ។ សំណួរ៖ តើលោកដឹង<>ដោយរបៀបណា? លោកឆ្លើយថា៖ គឺជាគោលការណ៍ដែលថាទាហាន លន់ នល់ ត្រូវតែកម្ទេច។ កម្មាភិបាលមកពីតំបន់ហៅគណៈស្រុកឲ្យចូលរួមប្រជុំ ហើយក្នុងពេលប្រជុំនោះ មានការសម្រេចចំពោះអ្នកណាដែលត្រូវសម្លាប់ និងអ្នកដែលមិនត្រូវសម្លាប់។ <>អ្នកដែលធ្វើការនៅក្នុងរបបចាស់ ប្រធានឃុំជាដើមត្រូវគេសម្លាប់។ ហើយ<នៅចម្លើយទី៤៧>លោកបន្ថែមថា ខ្ញុំដឹងពីបញ្ហានេះ ពីព្រោះខ្ញុំបានជជែកជាមួយគណៈស្រុក ហើយនិងគណៈតំបន់ ហើយពួកគាត់ប្រាប់ខ្ញុំពីរឿងនេះ។” លោកបានលើកឡើងអំពីវគ្គរៀនសូត្រ លោកបញ្ជាក់នៅក្នុងទីនេះ ហើយលោកបានឮពីបញ្ហានេះនៅក្នុងវគ្គរៀនសូត្រពីគណៈស្រុក និងគណៈតំបន់។ តើលោកនៅចាំទេ តើអ្នកណាដែលមកពីគណៈតំបន់ ហើយនិងមកពីគណៈស្រុកដែលនិយាយប្រាប់លោកអំពីគោលនយោបាយបែបនេះ?

[១៣:៤៦:២៨]

**ឆៈ** ខ្ញុំនៅចាំបានខ្លះ។ ខ្ញុំរៀនសូត្រមិនសូវបានខាងភូមិភាគទេកាលនោះ ខ្ញុំរៀននៅត្រឹមថ្នាក់តំបន់។ អ៊ីចឹងនយោបាយអីយ៉ាងណា ពីថ្នាក់លើមក មកត្រឹមថ្នាក់តំបន់ហ្នឹងទេ ដែលផ្សព្វផ្សាយមក

ឲ្យខាងក្រោម។ ហើយអ៊ីចឹងកិច្ចការដែលខ្ញុំជម្រាបជូនព្រះរាជអាជ្ញានេះក៏ដោយ គឺមិនខុសទេដែលខ្ញុំបានជូនកាលមុននេះ ដែលកត់ត្រាទុកនោះ។ ឯការនិយាយពេលនេះ ខ្ញុំនិយាយវាថា និយាយមិនកើត ប៉ុន្តែអារឿងនេះដែលនិយាយហ្នឹង គឺជារឿងពិតរបស់ខ្ញុំដែរដែលខ្ញុំបានដឹង ហើយចូលរួមក្នុងចលនានេះផ្ទាល់ខ្ញុំតាំងពីនោះមក។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំនឹងពិភាក្សាជាមួយលោកពេលនេះអំពីមុខតំណែងចុងក្រោយរបស់លោក ដែលលោកបានបម្រើការឲ្យកម្ពុជាប្រជាធិបតេយ្យ។ លោកបានបញ្ជាក់ប្រាប់តុលាការថ្ងៃនេះ ហើយនៅក្នុងបទសម្ភាសន៍ផងដែរ<ថា> នៅដើមខែធ្នូ ឆ្នាំ១៩៧៨ ហើយលោក<និង>កម្មាភិបាលមួយចំនួនទៀតមកពីស្អាង <ភូមិភាគនិរតី ត្រូវបាន>គេបញ្ជូនទៅក្រចេះ នៅហៅតំបន់៥០៥។ ខ្ញុំចង់ដឹងថា តើមានមូលហេតុអ្វីខ្លះដែលគេបញ្ជូនពួកលោកទៅក្រចេះនៅពេលនោះដើម្បីឲ្យទៅធ្វើអ្វី ឬក៏មូលហេតុអ្វី?

[១៣:៤៨:២៥]

**ឆ៖** ខ្ញុំសូមឆ្លើយ។ កាលគេបញ្ជូនខ្ញុំ មើល៍ មួយ ពីរ បី បួនទាំងខ្ញុំគឺ បងផុន (សៅ ផុន ហ្នឹង) អនុស្រុកទេជំនាន់នោះ។ តំបន់ក្រចេះហ្នឹង គេតែងតាំង បងមុត ហ្នឹងឲ្យធ្វើជាអនុលេខាតំបន់ ហើយយកម្នាក់ទៀតឈ្មោះ ភាព មកធ្វើលេខាតំបន់។ ភាព ហ្នឹងគេនៅកងពលជើងទឹកជាមួយ បងមុត។ ហើយពួកខ្ញុំទាំងអស់ ហើយការចាត់តាំង តែងតាំងឲ្យគេអ្នកទាំងខ្ញុំហ្នឹងធ្វើមន្ទីរស្រុក -- ប្រធានមន្ទីរតំបន់។ ម្នាក់ហ្នឹងដែលជាបញ្ជាការស្រុកក្រចេះ ម្នាក់ទៀតនៅក្រសួងកសិកម្ម។ ក្នុងការប្រកាសចាត់តាំងហ្នឹង គឺមាន តាមុត (មាស មុត) ហ្នឹងគាត់អ្នកទៅរៀបចំ ខេត្តក្រចេះហ្នឹង ព្រោះគេ ពេលនោះគេដកចាប់ខ្លួនអស់ហើយគណៈតំបន់អីៗ គណៈស្រុកមួយចំនួន ពេលខ្ញុំដែលឡើងស្រុកហ្នឹងៗ គឺ បងមុតគាត់ជាអ្នករៀបចំចាត់តាំងជួសមុខ ប៉ុល ពត កាលហ្នឹង។

**ស៖** តើចំពោះកម្មាភិបាលតំបន់នៅក្រចេះពីមុននោះ ដែលពួកលោកទៅជំនួសគាត់ តើអ្នកចាស់នោះ មានរឿងអ្វីកើតឡើងចំពោះពួកគាត់?

**ឆ៖** ខ្ញុំអត់ដឹងទេ គេចាប់បាត់អស់ហើយ បានពួកខ្ញុំបីបួននាក់ ខ្ញុំជម្រាបអំមិញហ្នឹង គេថាសុទ្ធតែខ្សែក្បត់ៗអីអាម៉ែចទេ ហើយខ្ញុំទៅក្រោយគេ ហើយចេះតែទៅៗ គេចាត់តាំងឲ្យធ្វើអីៗអ៊ីចឹងតាមការចាត់តាំងរបស់ បងមុត (មាស មុត)ហ្នឹងគាត់ទៅជំនួសមុខ ប៉ុល ពត នោះ កាលហ្នឹង។ ហើយខ្ញុំមិនដឹងថាគេមានអំពើខុសត្រូវអីក្នុងរដ្ឋាភិបាលទេ ដែលត្រូវគេចាប់ សុទ្ធតែប្រធានកងពល អនុកងពល គណៈ

តំបន់នៅក្រចេះហ្នឹង។ ហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** នៅពេលដែលគេបញ្ជូនលោកពី<ភូមិភាគនិរតី>ទៅក្រចេះ ដើម្បីទៅជំនួសកម្មាភិបាលដែលត្រូវគេបោសសម្អាត តើលោកមានលិខិតដែលយកទៅជាមួយខ្លួនដែរឬទេ ដែលជាលិខិតតែងតាំងឱ្យលោកកាន់តំណែង? តើអ្នកណាជាអ្នកចេញសំបុត្រតែងតាំង ចាត់តាំងទាំងនោះ?

[១៣:៥១:៥៥]

**ឆ៖** អត់មានសំបុត្រ ឬលិខិតអីទេ កាលនោះ។ បងផុន ហ្នឹងទៅថា គេឱ្យទៅហើយ ទាំងបងផុន , ខ្ញុំ ម្នាក់ទៀតបញ្ជាការស្រុកក្រចេះ មួយទៀតកាលរៀនខាងកសិកម្ម។ ទៅៗដល់ហ្នឹងទៅជួបអីហ្នឹង ហៅប្រជុំ អត់មានលិខិតអីទេ។ ប្រជុំហ្នឹង បងមាស មុត ហ្នឹងប្រកាសឱ្យ មិត្តភាព លេខាតំបន់ បងនេះហ្នឹង អនុលេខាតំបន់។ ហើយអ្នកទៅចាស់ហ្នឹងសល់តែគណៈស្រុកពីរទេ ស្រុកសំបូរ ហើយស្រុកឆ្លូង។ ហើយពេលនោះ ខ្ញុំ, បងមុត គាត់ឱ្យទៅកាន់អនុស្រុកសំបូរ ហើយខ្ញុំ អ្នេប្រកែកហើយ ខ្ញុំអត់ចេះធ្វើទេបង។ អ្នកអីចឹង សឿន ឯងនៅមន្ទីរចុះអីចឹង ហើយរើសអីចឹងទៅ។ អារឿងលិខិតអី គឺអត់មានទេ។

**ស៖** ខ្ញុំអានជូនលោកអំពីបទសម្ភាសន៍<របស់លោកប្រាប់>ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបំភ្លឺ គឺនេះជាឯកសារបទសម្ភាសន៍ E3/409 ពី២៦ ដល់២៧ សំណួរនិងចម្លើយ។ "សំណួរ៖ តើអ្នកណាជាអ្នកបញ្ជូនលោកទៅខេត្តក្រចេះ? តើអ្នកណាជាអ្នកតែងតាំងលោក? ចម្លើយ៖ ខ្ញុំមិនដឹងថាអ្នកណាបញ្ជូនខ្ញុំមកក្រចេះទេ ប៉ុន្តែឈ្មោះរបស់ខ្ញុំត្រូវបានគេបញ្ចូលទៅក្នុងលិខិតបញ្ជាជាលាយលក្ខណ៍អក្សរ ជាមួយនឹងមនុស្សផ្សេងៗ ដែលបញ្ជូនទៅខេត្តក្រចេះ។ តាមខ្ញុំយល់ គឺចេញដោយគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ <នៅពេលដែលយើងជិះយន្តហោះពីភ្នំពេញ ទៅចុះចតនៅក្រចេះ យើងបានជូន>សំបុត្រនោះ<>ទៅ មាស មុត។ ហើយ<លិខិតនោះបញ្ជាក់ថា> មាស មុត ជាអ្នកទទួលបន្ទុកខុសត្រូវក្នុងការចាត់ចែងការងារឱ្យមនុស្ស<ដែលមានឈ្មោះខាងលើ>ទទួលតំណែង<>។" អីចឹងខ្ញុំចង់ឱ្យច្បាស់លោកដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដែរឬទេ <ថា>លោក<មាន>សំបុត្រ<មួយ នៅ>ពេលដែលលោកបាន<ទៅដល់>ខេត្តក្រចេះ? <>នៅពេលណាមួយ<>ក្រោយ<មកទៀត តើ>លោកបាន<ឃើញ>លិខិត ឬសំបុត្របញ្ជាតែងតាំង<>លោក <និងអ្នកផ្សេងទៀតដែល>ចេញពីស្នាង<ទៅកាន់តួនាទីទាំងនោះដែរទេ>?

[១៣:៥៤:៥៨]

**ឆ៖** ពេលនោះខ្ញុំដឹង ប៉ុន្តែមិនមែនជាលិខិតតែងតាំងទេ។ គ្រាន់តែកត់ត្រាប្រវត្តិរូប នេះឈ្មោះ

អី? អីៗ អាយុប៉ុន្មានៗ ប៉ុន្មាននាក់ហ្នឹងគេកត់ទៅ គ្រាន់តែកាត់ឈ្មោះហ្នឹងទៅទេ ហើយកាន់ទៅ។ ទៅគេឲ្យទៅៗជិះយន្តហោះទៅ។ ទៅដល់ហ្នឹង ឲ្យប្រវត្តិរូបហ្នឹងឲ្យទៅ បងមុត មិនមែនលិខិតតែងតាំងទេ។ អាហ្នឹងគ្រាន់តែប្រវត្តិរូប ឈ្មោះអីៗ តែប៉ុណ្ណឹងទេ។

**ស៖** លោកបានបញ្ជាក់ពីរបីនាទីនេះ ដែលលោកថា មាស មុត ទៅទីនោះក្នុងនាម ប៉ុល ពត។ តើលោកដឹងបែបនេះដោយរបៀបណា? ហេតុអីបានជាលោកយល់<បែបនេះ? តើលោកយល់ថា> មាស មុត <មានតួនាទីអ្វីទៅ>ខេត្តក្រចេះពេលនោះ? <>គាត់ជាមេកងពល១៦៤ខាងជើងទឹក<> ប៉ុន្តែពេលគាត់ទៅក្រចេះ លោកថា ជំនួសក្នុងនាម ប៉ុល ពត? តើ<គាត់មានតួនាទី>អ្វី<នៅក្រចេះ>?

**ឆ៖** ខ្ញុំដឹងនេះ ដោយសារពេលគាត់ទៅរៀបចំចាត់តាំងខ្ញុំនៅក្រចេះ រួចគាត់រាយការណ៍ទៅម៉េត។ អីចឹង បងមុត ក្រោមការបញ្ជារបស់ ក្រោមការដឹកនាំរបស់ ស៊ូ ម៉េត។ បងម៉េត កាន់កងពលដែរ ភូមិភាគនៅនិរតីដែរ។ ពីមុនគាត់កាន់ទី១ ហើយ បងមុត កងពលលេខ៣។ ដល់ពេលនេះ វាដូចថាអស់ហើយ យូរៗវាបាត់ទៅណ៎ា ថាពូនេះក៏ផ្លាស់ពីឧត្តរ អ៊ំនែ! ហ្នឹងហើយ ពូសុន សេន នោះ ក្រសួងការពារជាតិហ្នឹងក៏លែងទៅណាណីដែរ ស្រាប់តែពីរនាក់ហ្នឹង គាត់ទៅកាន់តំណែងក្រសួងការពារជាតិហ្នឹងទៅ។ ស្រាប់ដល់ បងមុត ទៅចាត់តាំងខ្ញុំហ្នឹង ពេលការរាយការណ៍មក រាយការណ៍ឲ្យ បងម៉េត។ ខ្ញុំអង្គុយស្ដាប់គាត់រាយការណ៍តាម មិនមែនទូរសព្ទទេ កាលនោះគេនេះទេ ដល់អីចឹងខ្ញុំអង្គុយស្ដាប់ក្បែរគាត់ហ្នឹងទៅ។ បានជាខ្ញុំដឹងនោះ។

[១៣:៥៧:៤៣]

**ស៖** ខ្ញុំសូមសួរលោកអំពីចំណុចមួយ ថាតើលោកដឹងថាតើ មាស មុត កាន់មុខតំណែងនៅក្រោម សុន សេន ដែលជាតំណែងជាអនុ<រដ្ឋ>មន្ត្រីការពារប្រទេសក្រោម សុន សេន ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងកុំ! ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានស្ដាប់សំណួររបស់សហព្រះរាជអាជ្ញាអស់មួយរយៈមកហើយ ហើយខ្ញុំមានអារម្មណ៍ថា គាត់ដូចជាកំពុងតែសួររឿងដែលវាមិនពាក់ព័ន្ធ។ អីចឹងខ្ញុំគិតថា ដូចជាយើងងាកចេញពីសវនាការស្ដីពីការរៀបអាពាហ៍ពិពាហ៍ហើយ។ អ្វីដែលគាត់ធ្វើហ្នឹង ដូចជាមិនមែន

សវនាការលើសំណុំរឿង០០២/០២ទេ លោកប្រធាន។ អ៊ីចឹងបើគាត់នៅតែបន្តបែបនេះ ខ្ញុំសូមជំទាស់ទៅនឹងសំណួរបែបនេះ។

**លោក ខេល លីសាក់៖**

ខ្ញុំមិនយល់ពីការលើកឡើងនេះទេ លោកប្រធាន។ យើងនិយាយអំពីការបោសសម្អាតដែលកើតឡើង ហើយគេបានបញ្ជូនជនរងគ្រោះមកស-២១ <ដែលជាផ្នែកនៃសំណុំរឿងនេះ>។ ហើយគាត់នេះជាដើមបណ្តឹងរដ្ឋប្បវេណី ជាមនុស្សទី២<ដែលយើងបានស្តាប់សក្ខីកម្ម។ យើងបានឮពីសាក្សីម្នាក់> អំពីតួនាទីរបស់ មាស មុត។ ហេតុអ្វីក៏ មាស មុត នៅទីនោះ? តើគាត់ធ្វើការក្នុងតំណាងអ្នកណា? ហើយយើងមិនពាក់ព័ន្ធអ្វីទៅរឿងក្តីផ្សេងទេ យើងគ្រាន់តែចង់ដឹង<ថាហេតុអ្វីបានជាបុគ្គលម្នាក់នេះទៅក្រចេះនោះ ហើយពិនិត្យមើល>ការចាប់មនុស្សនៅទីនោះ ហើយបញ្ជូនមកស-២១ តែប៉ុណ្ណឹងទេបាទ។

[១៣:៥៩:៤៥]

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់។ សំណួរមានការពាក់ព័ន្ធ។

សូមអញ្ជើញសហព្រះរាជអាជ្ញាបន្តសំណួរ!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសួរថាតើ មាស មុត មានមុខតំណែងជាអនុរដ្ឋមន្ត្រីការពារប្រទេសនៅក្រោមមួយថ្នាក់ពី សុន សេន ទេ នៅពេលដែលគាត់ទៅខេត្តក្រចេះនៅពេលនោះ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំមិនដឹងថា ប្រធាន ឬអនុប្រធានទេ គ្រាន់ខ្ញុំឃើញគាត់ដែលមកធ្វើការនៅក្រចេះហ្នឹងដល់ពេលរាយការណ៍ពីរឿងការងារដែលគាត់ធ្វើនៅក្រចេះហ្នឹង រាយការណ៍ជូនទៅ បងម៉េត ពីមុនកាន់កងពលទី១ ភូមិនិរតីនេះ ដល់ឥឡូវហ្នឹងមិនដឹងគាត់ធ្វើអីដែរពេលនោះ ខ្ញុំអត់ដឹងទេ គ្រាន់តែនៅអង្គុយស្តាប់ បងមុត គាត់និយាយទាក់ទងគ្នាហ្នឹង។ គ្រាន់តែដឹងតែប៉ុណ្ណឹង។

**ស៖** លោកក៏បាននិយាយពីរបីនាទីកន្លងទៅនេះដែរថា មាស មុត នៅទីនោះក៏គាត់ធ្វើការក្នុងនាម ប៉ុល ពត។ ហេតុអ្វីក៏លោកនិយាយបែបនេះ? តើមានអ្វីដែលនាំឲ្យលោកជឿជាក់ថា មាស មុត ទៅទីនោះ ទៅធ្វើកិច្ចការក្នុងនាម ប៉ុល ពត?

[១៤:០១:១៤]

**ឆ៖** ខ្ញុំនឹកគិតក្នុងចិត្តថា វាគេចាប់គណៈតំបន់អីហ្នឹងអស់ហើយ គាត់ទៅរៀបចំមានតែ មានពីណាទេ បើមិនមាន ប៉ុល ពត ទេ មានតែតាប៉ុន្នានាក់ទៀត គាត់អ្នកគ្រប់គ្រងប្រទេស។ ហើយអ៊ីចឹងនិយាយវាយស្មានក្នុងចិត្តទេ មិនស្រួលគាត់ទៅជំនួសផងមិនដឹង។ នេះខ្ញុំគ្រាន់តែគិតក្នុងចិត្ត ខ្ញុំអត់ហ៊ានថាពិត។

**ស៖** ពាក់ព័ន្ធទៅនឹងស្ថានភាពរបស់ខេត្តក្រចេះ គឺតំបន់៥០៥ តើតំបន់ក្រចេះដែលហៅថាតំបន់៥០៥ ជាផ្នែកនៃភូមិភាគនៅពេលនោះ ឬក៏ជាតំបន់ស្វយ័ត?

**ឆ៖** តាមខ្ញុំដឹងគេហៅថា តំបន់ស្វយ័ត អត់មាននៅក្នុងភូមិភាគណាគ្រប់គ្រងទេ។

**ស៖** តើលក្ខណៈសំខាន់នៃតំបន់ស្វយ័តហ្នឹងដូចម្ដេច? ថាតើគណៈតំបន់ស្វយ័តហ្នឹងរាយការណ៍ទៅណា ពីខេត្តក្រចេះមកនោះ?

**ឆ៖** ខ្ញុំមិនដឹងដែរ ប៉ុន្តែថាចេញពីរបាយការណ៍ចេញពីតំបន់ទៅ១មជ្ឈិមបក្ស តែរួចពីហ្នឹង ពីណាពីណីទេ ខ្ញុំគ្រាន់តែដឹងតែប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេថា គណៈតំបន់<ក្រចេះ>មានការប្រជុំជាទៀងទាត់អ្វីជាមួយមេដឹកនាំ<បក្ស>នៅភ្នំពេញដែរឬទេ?

**ឆ៖** ខ្ញុំទៅដល់ហ្នឹងមិនទាន់បានពេញមួយខែស្រួលបួល ក៏អត់បានដឹងទេ រឿងអីទាំងអស់ហ្នឹងទើបបានគេឲ្យ បងមុត ឲ្យប្រមូលទ័ពដែលបាក់ចេញពីព្រំដែនយួនមកហ្នឹង តែប៉ុណ្ណឹងទេ ខ្ញុំ។

[១៤:០៣:៥៤]

**ស៖** បាទ មិនអីទេ។ អ៊ីចឹងគឺថា ភាគច្រើននៃមនុស្សនៅក្នុងគណៈតំបន់ ឬក៏កម្មាភិបាលដែលចាស់ៗនៅទីនោះ ត្រូវបានគេបោសសម្អាតរួចហើយមុននឹង<>ក្រុមលោកទៅជំនួស គឺនៅតែ នៅស្រុកពីរទេ <>។ អ៊ីចឹងគឺយើងនិយាយអំពីបទសម្ភាសន៍<របស់លោក ដែលលោក>និយាយអំពីលេខាមកពីស្រុកក្រចេះ ហើយនិងស្រុកស្នួល។ តើលោកអាចប្រាប់តុលាការបានដែរឬទេ ថាតើលេខាស្រុកទាំងពីរនេះមានបញ្ហាអ្វីទេ បន្ទាប់ពីលោកទៅដល់ហើយនោះ?

**ឆ៖** ខ្ញុំមិនដឹងថាអីទេ ប៉ុន្តែពេលនុំងរួចខ្លួន គណៈស្រុកតែពីរហ្នឹង ឯពីរទៀតដែលខ្ញុំទៅទាន់ហ្នឹង ចំពេលហ្នឹង បងមុត គាត់ដូចថាមិនមែនបោសសម្អាតទេ គាត់ចាប់បញ្ជូនឲ្យឡើងយន្តហោះទៅភ្នំពេញទៅ ខ្ញុំ អាហ្នឹងនៅស្រុកជាមួយខ្ញុំដែរ។ គឺ អាភ័ន នៅស្រុកកំណើតវាហៅ អាចិន វាបងបង្កើតវាជាគ្រូបង្រៀនខ្ញុំកាលនៅសម័យមុន៧០ ឈ្មោះ ខៀវ វ៉ាន់ហាន នេះ។ ហើយអាមួយទៀត គណៈស្រុក

ក្រចេះ ខ្ញុំភ្លេចឈ្មោះហើយអាហ្នឹង អាហ្នឹងនៅចេញពីកងពល កងពលទី២ ភូមិភាគនិរតីហ្នឹង។ ឯពីរនាក់ស្រុកឆ្លូង និងស្រុកសំបូរហ្នឹង នៅហ្នឹងក៏ចេញពីកងពលលេខ២ មួយចេញពីពលទី១ដែរ មកធ្វើគណៈស្រុកហ្នឹង។ នេះខ្ញុំបានស្គាល់តែប៉ុណ្ណឹង ឯពីរនាក់ដែល បងមុត ឲ្យឡើងយន្តហោះទៅក៏មិនដឹងគេយកទៅណា ប៉ុន្តែដឹងតែទៅភ្នំពេញហើយ ប្រហែលបាត់ខ្លួន ខ្ញុំសួរដំណឹងទៅស្រុកភូមិ ថាអត់ឃើញ។

[១៤:០៦:១៩]

**ស៖** បាទ ខ្ញុំចង់ដឹងថាតើ<ខ្ញុំអាចកំណត់អត្តសញ្ញាណ>លេខាស្រុកពីរនាក់ដែលជិះយន្តហោះមកភ្នំពេញ<នោះដែរឬទេ។> នេះគឺឯកសារ E3/1651 ជាបញ្ជីអ្នកទោសស-២១ ខែធ្នូ ១៩៧៨។ ទំព័រភាសាខ្មែរគឺ 00086832, អង់គ្លេស 00789507, បារាំង 00841431 នេះគឺឯកសារ E3/1651។ លេខរៀងទី១០ នៃបញ្ជីអ្នកទោសស-២១នេះគឺឈ្មោះ <ហួន> យ៉េង ជាលេខាស្រុកក្រចេះ។ លេខរៀងទី១១ ឈ្មោះ <ឈុំ ចិន> ហៅ <ភ័ន> ជាលេខាស្រុកស្នួល។ អ្នកទាំងពីរនេះគឺបានចូលមកស-២១ នៅថ្ងៃទី១២ ធ្នូ ៧៨។ លោកដើមបណ្ដឹងរដ្ឋប្បវេណី យ៉េង និង <ភ័ន> តើអ្នកទាំងពីរនេះជាលេខាស្រុកដែលលោកបានឆ្លើយថាត្រូវបានយកមកឲ្យជិះយន្តហោះមកភ្នំពេញនោះឬ?

**ឆ៖** បាទ ហ្នឹងហើយ។ ខ្ញុំទើបរកនឹកឈ្មោះបាន ឈ្មោះវា អាយ៉េង គណៈស្រុកក្រចេះ ហើយអាចិន នេះហៅ អាភ័ន ទេ គេផ្លាស់ថ្មី ប៉ុន្តែឈ្មោះដើមវា អាចិន។ អាហ្នឹងខ្ញុំជួបផ្ទាល់ កាលហ្នឹងរៀបឡើងយន្តហោះស្គាល់គ្នាហើយនៅភូមិជាមួយគ្នា អាចិន ហើយនិងខ្ញុំហ្នឹង។ ខ្ញុំមិនហ៊ាន វាក៏អត់ហ៊ាន ខ្ញុំក៏អត់ហ៊ាននិយាយរកគ្នាទេ ព្រោះ មាស មុត ហ្នឹងនៅក្ដែក្បែរខ្លួនដែរ អត់ហ៊ានដែរ នេះខ្លាចងាប់ដែរ។ ក៏គេដាក់ឡើងយន្តហោះទៅ។ នេះដំណើររឿងខ្ញុំ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់បន្តិចលេខាស្រុកស្នួលឈ្មោះ ភ័ន នេះគឺជាមនុស្សម្នាក់ដែលលោកស្គាល់តាំងពីមុនមកម្ល៉េះមែនឬ?

**ឆ៖** បាទ ឈ្មោះ អាចិន ឥឡូវគេផ្លាស់ថ្មីហៅ ភ័ន ហ្នឹង។ ដូចខ្ញុំជម្រាបអ៊ីចឹងថា បងវាបង្កើតជាគ្រូបង្រៀនខ្ញុំថ្នាក់ទី៧ មុន៧០ ហើយវាចូលជួរ៧០ គេខាងនីរសារ។ ឯខ្ញុំចូលអ៊ីចេះទៅ ខ្ញុំឧស្សាហ៍មកលេងផ្ទះម្ដាយវា ស្គាល់វានេះ និយាយថាស្គាល់ជិតដិតតែម្ដងហ្នឹង។ ហើយ អាយ៉េង ខ្ញុំអត់ទេ នៅភូមិផ្សេង ឃុំផ្សេងទេ។

[១៤:០៩:៣៩]

**ស៖** បើខ្ញុំស្ដាប់មិនច្រឡំទេ គឺមនុស្សទាំងពីរនាក់នេះ គឺមកពីអតីតកងពលលេខ២ មែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយបើខ្ញុំយល់មិនច្រឡំទេ អ្នកទាំងពីរហ្នឹងគឺមកពីជាកងទ័ពចំណុះឲ្យកងពលភូមិភាគនិរតីមែនទេ?

**ឆ៖** ពីរនាក់ដែលខ្ញុំ លោកព្រះរាជអាជ្ញាសួរខ្ញុំនេះ បើ អាយ៉េង អាហ្នឹងដឹងចេញពីកងពលលេខ ១ ឬកងពលលេខ២។ ខ្ញុំថាបើ អាចិន ហៅ ភ័ន ហ្នឹង វាអត់ចេញពីទ័ពទេ វាក្រុមនីរសាររបស់តំបន់១៣ ដំបូង។ ហើយស្រាប់តែ ខ្ញុំក៏បែកតាំងពី៧០, ៧១មកទៅ មិនដឹងវាទៅធ្វើអីទៀតទេអាហ្នឹង អាចិន ហៅ ភ័ន ហ្នឹង។

**ស៖** សូមអរគុណច្រើនលោកដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងបញ្ជីអ្នកទោសស-២១ដដែល នេះគឺឯកសារ E3/1651 នៅត្រង់ទំព័របន្ទាប់ គឺបន្ទាប់ពីទំព័រដែលខ្ញុំទើបអានឲ្យលោកស្តាប់មុននេះ។ ឥឡូវខ្ញុំសូមអានឲ្យលោកស្តាប់ម្តងទៀត ដើម្បីកំណត់ត្រាប្រតិចារឹកគឺ E3/1651, ខ្មែរ 00086833 ដល់ 34, អង់គ្លេស 00789508 ដល់510, បារាំង 00841432 ដល់<34>។ នៅត្រង់នេះគឺថាមាន បញ្ជីមួយដែលមានអ្នកទោស២២នាក់មកពីតំបន់ក្រចេះ គឺតំបន់៥០៥ ចូលមក ស-២១ នៅថ្ងៃទី២៧ ខែ ធ្នូ ៧៨។ ឥឡូវខ្ញុំសុំឲ្យលោកដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យមើលបញ្ជីនេះ ដោយសារថាលោកអានឈ្មោះ មិនបាន សុំឲ្យសហការីរបស់ខ្ញុំអានឈ្មោះនេះ ឲ្យលោកស្តាប់ពីអ្នកដែលមកពីក្រចេះមក គឺតំបន់៥០៥ មកចូលមកស-២១ ថ្ងៃទី២៧ ធ្នូ ៧៨ និងចង់ដឹងថា តើលោកស្គាល់អ្នកទាំងនេះដែរឬទេ? ហើយសុំ ឲ្យសហការីរបស់ខ្ញុំ សុំអានអំពីឈ្មោះ ហើយនិងតួនាទីរបស់អ្នកដែលមកពីក្រចេះនេះ។

[១៤:១២:៥២]

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន។ សូមការអនុញ្ញាត ដើម្បីអានឈ្មោះទាំង២២រូប។ ឈ្មោះអ្នកទោស ផ្នែកតំបន់៥០៥។ ពិន យឹម អាយុ៤៥ឆ្នាំ ភេទប្រុស ប្រធានឃុំថ្មី ស្រុកក្រចេះ។ ប៉ៀន លន់ អាយុ៥៧ ឆ្នាំ ភេទប្រុស។ សេត នន អាយុ៤៣ឆ្នាំ ភេទប្រុស។ ម៉ឹង ស៊ឹង ហៅ សែន អាយុ៦៣ឆ្នាំ ភេទប្រុស។ ហង់ ហុន អាយុ៣៩ឆ្នាំ ភេទប្រុស។ យឹម លន អាយុ៣១ឆ្នាំ ភេទប្រុស។ យ៉ាវ ផូ អាយុ៤១ឆ្នាំ ភេទ ប្រុស។ សួន យ៉ុត ហៅ យា អាយុ១៩ឆ្នាំ ភេទប្រុស។ ឈ ឃឹម អាយុ៦០ឆ្នាំ។ ញ៉ិល សំ អាយុ៣៥ឆ្នាំ ភេទប្រុស។ មៀន ភន អាយុ៣៤ឆ្នាំ ភេទប្រុស។ នួន យុទ្ធ អាយុ៤០ឆ្នាំ ភេទប្រុស។ ម៉ប់ ប៊ិន ហៅ សុ ខា អាយុ៣១ឆ្នាំ។ អ៊ិន គីមហោ ហៅ ហោ អាយុ២៦ឆ្នាំ ភេទប្រុស។ឃួន គឹមស៊ុន អាយុ៣៤ឆ្នាំ ភេទ ប្រុស។ ថៃ ច្រឹក ហៅសំបាត់ អាយុ៣៨ឆ្នាំ។ កែ ថុន អាយុ២០ឆ្នាំ ភេទប្រុស។ ម៉ី ភឿន ហៅ ស៊ីថា សូមទោសកន្លែងនេះ សូម្បីជាអក្សរជាអក្សរខ្មែរក៏អត់ច្បាស់ មិនដឹងថាអក្សរ “ភ” ឬអក្សរ “ក” អ៊ិចឹង

01355206



អាចថា មុី កឿន ឬក៏ មុី ភឿន ហៅ សុីថា អាយុ២៧ឆ្នាំ ភេទប្រុស។ កូប ហុីម អាយុ២០ឆ្នាំ ភេទ ប្រុស។ យុន តេង អាយុ៣៩ឆ្នាំ។ ទុយ ស៊ាន អាយុ៣៦ឆ្នាំ។ និង ចាន់ យឿន អាយុ៣១ឆ្នាំ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សហការីរបស់ខ្ញុំទើបតែអានឈ្មោះមនុស្សទាំង២២នាក់មកពីតំបន់ក្រចេះ។ ខ្ញុំលើកតែ ឈ្មោះពីរបីនាក់ទេ ទី១គឺ ពិន យឹម ជាមេឃុំថ្មី។ លេខ<១០> ញឹល សំ <ប្រធានសហករណ៍ឃុំ សំបុក>។ លេខ១២ <នុន> យុទ្ធ ជា<អនុ>លេខាឃុំថ្មី។ តើលោកស្គាល់ឈ្មោះអ្នកទាំងអស់នេះខ្លះ ទេ? <តើលោកចាំពីការចាប់ខ្លួន>មានប្រធានសហករណ៍ឃុំ ប្រធានឃុំជាដើម។ល។ <បានកើតឡើង នៅ>ខែធ្នូ ឆ្នាំ១៩៧៨នោះ<ដែរទេ>?

[១៤:១៦:១៣]

**លោក សេង សឿន៖**

**ឆ៖** អត់ទេ ខ្ញុំអត់ស្គាល់ទេ។ ខ្ញុំទៅស្គាល់អី ទៅនៅស្គាល់ក្រចេះទើបនឹងឃើញបានមួយខែ ស្រួលបួលផង។

**ស៖** ខ្ញុំយល់ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ឥឡូវខ្ញុំសួរពាក់ព័ន្ធទៅនឹងចម្លើយរបស់ លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/409 ត្រង់សំណួរចម្លើយលេខ៣៦។ ចម្លើយ នេះវែងបន្តិច។ លោកបានឆ្លើយថា៖ “មានតែ<សមាជិកគណៈ>ស្រុក<>ទេ ដែលត្រូវបញ្ជូនឲ្យទៅជិះ យន្តហោះ។ <លោកបាននិយាយអំពីប្រធានស្រុកពីរនាក់ បន្ទាប់មកលោកនិយាយថា> ឯកម្មាភិបាល ថ្នាក់ក្រោមដែលត្រូវបោសសម្អាតផង គឺត្រូវបញ្ជូនទៅមន្ទីរសន្តិសុខនៅក្នុងខេត្តក្រចេះ។” បញ្ចប់ការដក ស្រង់។ លោកចាំទេ ថាតើកម្មាភិបាលថ្នាក់ក្រោមទាំងនេះគឺជាអ្នកណាដែរ? <តើ>មានអ្វីកើតឡើង បន្ទាប់ពីបញ្ជូនអ្នកទាំងនេះទៅមន្ទីរសន្តិសុខក្នុងខេត្តក្រចេះ?

**ឆ៖** ខ្ញុំដូចជាមិនបានដឹងទេ ខ្ញុំបានដឹងតែមួយទេ។ ពេលដែលខ្ញុំបានទៅដល់ក្រចេះ ខ្ញុំបានជួប ម្នាក់ដែលនៅភូមិជាមួយខ្ញុំ រៀនជាមួយគ្នា ភូមិកំណើតនៅឃុំពពេល ស្រុកត្រាំកក់នេះ។ វាមាន១តួនាទី សមាជិកតំបន់ទទួលបន្ទុកខាងយោធា។ ពេលនោះ ខ្ញុំទៅជួបបានម្ដងហ្នឹង រំលង៣ថ្ងៃ បងមុត ប្រាប់ខ្ញុំ ថា អើ! អញធ្វើការឲ្យ អាអឿង អ្នែងថានៅភូមិជាមួយ សឿន ឯងអ្ហ៎? ខ្ញុំថា បាទនៅភូមិជាមួយខ្ញុំ។ អើ អញដោះស្រាយរួចហើយ។ ខ្ញុំដឹងតែប៉ុណ្ណឹង។ គឺ ម៉ៅ អឿង នៅភូមិជាមួយខ្ញុំដែលពេលហ្នឹង មាស មុត ហ្នឹងគាត់ផ្ទាល់តែម្ដង គាត់ថាគាត់បាញ់ ឲ្យនីរសារគាត់បាញ់សម្លាប់វាចោល ហើយគាត់ប្រាប់ខ្ញុំ។ មាន

ដឹងរឿងតែប៉ុណ្ណឹងទេ ក្រៅពីហ្នឹងអត់ដឹងដែរ។

[១៤:១៨:៥១]

**ស៖** ខ្ញុំមានសំណួរតិចតួចទៀតទេដែលត្រូវសួរទៅលោក។ លោកបាននិយាយសំដៅឈ្មោះ សុន សេន។ ថា សុន សេន ត្រូវបានគេចាត់តាំង លោកនិយាយថាភូមិភាគឧត្តរ។ តាមលោកយល់នៅពេលដែលគេបញ្ជូនលោកទៅក្រចេះ តើ សុន សេន នៅទីណាដែរនៅពេលនោះ? តើ សុន សេន នៅភ្នំពេញ ឬក៏ សុន សេន នៅឯសមរភូមិមុខ ទាក់ទងទៅនឹងការប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាមនោះ?

**ឆ៖** ពេលនោះខ្ញុំគ្រាន់តែដឹងទេ មិនបានជួបគាត់ផ្ទាល់ទេ គ្រាន់តែគេយកទៅបូព៌ា ព្រោះចាប់អស់ហើយខាងបូព៌ា អ៊ីចឹងគាត់ទៅកាន់តំណែងនុ៎ង។

**ស៖** ចុះលោកដឹងថាគាត់ទៅបូព៌ាហ្នឹង ដឹងដោយរបៀបណា?

**ឆ៖** ខ្ញុំ មិនដឹងប្រាប់ថាអ្នកណា ឈ្មោះណាទេ ប៉ុន្តែមិត្តភក្តិវាច្រើន នៅជួរខ្មែរក្រហមហ្នឹងសុទ្ធតែអ្នកវរសេនាតូច អ្នកវរសេនាធំខ្លះ មិនដល់កងពលទេ ត្រឹមវរសេនាធំហ្នឹង ស្គាល់ៗហ្នឹង ក៏ចង់ដឹងសួរនោះ សួរនាំទៅ ក៏គេប្រាប់ បងខៀវ ទៅណាហើយ? ថាអ៊ំវាទៅកាន់បូព៌ាហើយ ចាប់ខាងណោះអស់ហើយ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើលោកបានជួប សុន សេន ដែរឬទេ នៅចុងឆ្នាំ៧៨ ឬដើមឆ្នាំ៧៩ នៅពេលដែលរត់គេចវៀតណាមនោះ?

[១៤:២០:៥៩]

**ឆ៖** ក្រោយពីយួនចូលនៅ ខ្ញុំឡើងភ្នំដងរែកទៅ ពេលហ្នឹងបានខ្ញុំជួបស្គាល់ និងគាត់ស្គាល់ច្បាស់ ហៅខ្ញុំ ទាំងកម្មាភិបាលខាងក្រោមៗហ្នឹង ទៅបើករគ្គរៀនសូត្របានបីដង។ រួចក៏ខ្ញុំឈប់ទៅ នៅតែសមរភូមិឯក្រចេះនេះទៅ។ រឿងបងខៀវ – សុន សេន។

**ស៖** សូមអរគុណ។ ចំណុចមួយចុងក្រោយ ខ្ញុំសូមសួរលោកពីអ្វីដែលលោកឆ្លើយជូនមជ្ឈ-មណ្ឌលឯកសារកម្ពុជា។ នេះគឺឯកសារ E3/5643 ខ្មែរគឺ 00059360 ដល់61, អង់គ្លេស00753864, បារាំង 00756607 ដល់08។ នេះគឺជាអ្វីដែលលោកឆ្លើយជាមួយកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា សូមដកស្រង់៖ "នៅពេលមនុស្សណាម្នាក់ត្រូវគេចោទថាជាខ្មាំង នៅពេលដែលអ្នកទាំងអស់នោះ <>ធ្វើឲ្យបាក់ស្លាបព្រា ឬក៏បែកចាន។ ការចោទប្រកាន់បែបនេះ មិនមែនធ្វើឡើង

ដោយថ្នាក់លើទេ។ សួរ៖ តើថ្នាក់លើមិនដឹងអំពីរឿង<នេះតាមរយៈ>រាយការណ៍<>ទេ? ឆ្លើយ៖ គឺថាមិនមានការរាយការណ៍រឿងអ៊ីចឹងទេ។ <សួរ៖> តើរបាយការណ៍នោះមិនបញ្ជូនទៅមជ្ឈិមទេឬ? អត់ទេ សូម្បីតែឃុំក៏គេមិនរាយការណ៍ទៅឲ្យដឹងផង។ ការបកស្រាយរបស់មេភូមិនោះ គឺអាស្រ័យទៅលើអារម្មណ៍<ស្អប់> ហើយនិងការសងសឹក។ គេអាចធ្វើ<អ្វីដែលគេចង់ធ្វើ> ហើយគេ<រាយការណ៍> ថាគេសម្លាប់ខ្មាំង <ប៉ុន្តែ>តាមការពិតសម្លាប់មនុស្ស<ដែលអត់ឃ្លាន> ដែលគ្រាន់តែលួចចំណីអាហារតែប៉ុណ្ណោះ។" បញ្ចប់ការដកស្រង់។

អ្វីដែលខ្ញុំចង់សួរទៅលោក លោកដើមបណ្តឹងរដ្ឋប្បវេណី គឺថាការបកស្រាយចំពោះមនុស្សដែលធ្វើឲ្យបែកចាន បាក់ស្លាបព្រាថាជាខ្មាំង នេះគឺជាការបកស្រាយរបស់ពួកមេភូមិទេ មិនមែនជាការបកស្រាយរបស់ថ្នាក់លើថាអ៊ីចឹងទេ តើអ៊ីចឹងមែនទេ?

[១៤:២៣:៤៣]

**ឆ៖** បាទ ពេលនេះខ្ញុំឆ្លើយសម្រាប់អ្នកព័ត៌មានអីទាំងអស់ថា រឿងរ៉ាវអីទាំងអស់ គ្មានដឹងទេ ថ្នាក់មេភូមិនេះហ៊ានធ្វើសម្លាប់ធ្វើអីនេះ នៅអាខាងលើ គ្មានដឹងមាំងកាលំាងអីទេ។ ខ្ញុំគ្រាន់ឆ្លើយប្រាប់តែប៉ុណ្ណឹង។

**ស៖** មូលហេតុដែលខ្ញុំសួរលោកពីចំណុចនេះ មានភស្តុតាងបង្ហាញថាផ្ទុយ វាមានលក្ខណៈផ្ទុយគ្នា។ អ៊ីចឹងហើយបានខ្ញុំសួរលោកដើម្បីបញ្ជាក់មើល ថាតើលោកមានប្រតិកម្មយ៉ាងដូចម្តេចដែរ។ លោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍របស់លោក ថាលោកទទួលឯកសារទង់បដិវត្ត <ដែលបោះពុម្ព>នៅខែកក្កដា មួយពាន់ប្រាំបួន -- គឺឯកសារទង់បដិវត្តចុះខែកក្កដា ៧៨ គឺឯកសារ E3/746, ខ្មែរ 0006 4495, អង់គ្លេស 00428297, បារាំង 00611878។ នៅ<ក្នុងអត្ថបទ>មួយ<មានចំណងជើង>ថា៖ "ការខិតខំព្យាយាម ដើម្បីរែករកមុខខ្មាំងដែលលាក់ខ្លួន" <ជាការបោះពុម្ពផ្សាយរបស់បក្ស>បញ្ជាក់ថា "ខ្មាំងគ្រប់ប្រភេទ គឺវាធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន។ គេធ្វើឲ្យខូច<ទឹក ខូច>សម្លូងសំណាប ធ្វើឲ្យខូចឧបករណ៍ប្រើប្រាស់ ធ្វើឲ្យបាក់ស្លាបព្រា បែកចាន បែកឆ្នាំងជាដើម។ល។" លោកដើមបណ្តឹងរដ្ឋប្បវេណី យើងបានស្តាប់នៅក្នុងបន្ទប់សវនាការនេះ ដែលលោក នួន ជា ឆ្លើយផ្ទាល់ទៅលើប្រធានបទមួយនេះ គឺពាក់ព័ន្ធទៅនឹងប្រជាជនដែលធ្វើឲ្យបែកបាក់ចានស្លាបព្រា <គឺជាខ្មាំង។ នៅក្នុងបន្ទប់សវនាការនេះ>គឺនៅក្នុងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ គឺឯកសារ E1/21.1 នៅម៉ោង១០:៣៥នាទី នួន ជា បានពិភាក្សានិយាយអំពីខ្មាំងនៅក្នុងសហករណ៍។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:២៥:៥៨]

នេះគឺជាអ្វីដែលគាត់ឆ្លើយ សូមដកស្រង់៖ “គឺថានៅតែមានសមាសភាពមិនល្អ<>នៅតាមសហករណ៍<មួយចំនួន> ពួកគេព្យាយាមបំផ្លិចបំផ្លាញសហករណ៍ ឧទាហរណ៍ ពួកគេបំផ្លិចបំផ្លាញឧបករណ៍ នង្គ័ល ចាន ស្លាបព្រា របស់របរផ្សេងៗ ។ល។”

ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណី <យើងក៏បានស្ដាប់ឮនៅក្នុងបន្ទប់សវនាការនេះដែរ> នៅថ្ងៃទី១២ ខែមិថុនា ២០១៣ គឺឯកសារ <E1/206.1> <ម៉ោង១៤:១១នាទី> គឺ<យើងបានឮពីសាក្សីម្នាក់>ដែលធ្វើការនៅឃ្លាំង<រដ្ឋ>នៅទួលទំពូង ដែលបានរៀបរាប់អំពីចម្លើយរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មឈ្មោះ វ៉ាន់ រិទ្ធ ដែល<ជាមនុស្សម្នាក់នៅក្រោមការគ្រប់គ្រងរបស់> ខៀវ សំផន។ គឺគាត់បានលើកឡើងដូចតទៅ សូមដកស្រង់៖ “លោក រិទ្ធ គឺជាអ្នកទទួលខុសត្រូវពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ហើយតាមធម្មតាគាត់ជួបយើង ដើម្បីឃោសនាយើងថា យើងត្រូវតែប្រុងប្រយ័ត្ន។ គាត់ថាបើសិនណាជាយើងធ្វើសូម្បីតែធ្វើឲ្យបាក់ស្លាបព្រាមួយ ក៏ត្រូវចាត់ទុកថា ជាខ្មាំងដែរ។” បញ្ចប់ការដកស្រង់។

ហេតុផលដែលខ្ញុំសួរលោកអំពីចំណុចនេះ លោកបានឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា ការយល់ឃើញទៅលើ ទៅអ្នកដែលធ្វើឲ្យបាក់បែកចានឆ្នាំងនោះ និងបាក់ស្លាបព្រាហ្នឹង គឺមេភូមិទេ ជាអ្នកយល់ឃើញបែបនេះ ហើយចាត់ទុកអ្នកទាំងនោះជាខ្មាំង។ <យើងមានទស្សនាវដ្ដីទង់បដិវត្ត> ចម្លើយរបស់លោក នួន ជា <និង>ចម្លើយ<មួយដែលនិយាយអំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម> ដែល<បញ្ជាក់>ថា អ្នកដែលធ្វើឲ្យបាក់បែកស្លាបព្រាហ្នឹង គឺជាខ្មាំងហើយ។ ប្រហែលជាលោកឆ្លើយទៅយល់ច្រឡំក៏មិនដឹង នៅពេលដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់។

[១៤:២៧:៥៩]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់។ គឺថាចំណុចនេះ គឺថាវានៅក្រៅបរិបទនេះទាំងស្រុង ការដកស្រង់សម្រង់នេះមក។ គឺថាមានភស្តុតាងច្រើនណាស់ដែលវាផ្ទុយពីការលើកឡើងនេះ។ ខ្ញុំអាចផ្តល់ឧទាហរណ៍ជាច្រើនជូនបាន។ <ខ្ញុំសូមយោងទៅបញ្ហា>ដែល<ថា> សុន សេន នោះ ដែល<>ដើមបណ្តឹងរដ្ឋប្បវេណីថាជាមេបញ្ជាការរបស់គាត់បានធ្វើសេចក្តីសម្រេចច្បាស់លាស់ហើយ ពាក់ព័ន្ធទៅនឹងខ្មាំងបដិវត្តន៍ ឬក៏ពួកក្បត់ណានោះ គឺថាសំដៅទៅលើអ្នកណាដែលធ្វើឲ្យបាក់បែកស្តាបព្រា ហើយចាត់ទុកថាជាខ្មាំង <ហើយសម្លាប់>នោះ <>ថាគួរឲ្យអស់សំណើចណាស់។ ខ្ញុំយល់ឃើញថា រឿងនេះ គឺជារឿងមួយដែលស្ថិតនៅខាងក្រៅបរិបទរបស់យើងនេះហើយ។

[១៤:២៩:០៣]

**លោក ខេល លីសាក់៖**

ខ្ញុំមិនយល់<ពីការជំទាស់នេះទេ>។ <>មេធាវីការពារក្តី<>ក៏បានសួរតទល់ជាមួយសាក្សីនៅចំពោះមុខតុលាការយើងដែរ។ សាក្សីបានឆ្លើយ<ពីបញ្ហាមួយ>នៅ<ក្នុងបទសម្ភាសន៍ជាមួយ>មជ្ឈមណ្ឌលឯកសារកម្ពុជា<>។ <មានភស្តុតាងផ្ទុយគ្នាគួរឲ្យចាប់អារម្មណ៍> អ៊ីចឹងហើយបានជាខ្ញុំមានសិទ្ធិសួរតទល់ជាមួយសាក្សីរូបនេះ <អំពីបញ្ហានេះ>។ សូមកែតម្រូវ គឺសូមកែតម្រូវជាដើមបណ្តឹងរដ្ឋប្បវេណីទេ។

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់។

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំ ប្រហែលជាលោកអាចឆ្លើយច្រឡំហើយ នៅពេលដែលលោកផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាថា មេភូមិទេដែលយល់ឃើញថា អ្នកដែលធ្វើឲ្យបាក់បែកចានស្តាបព្រានេះ ហើយចាត់ទុកគេជាខ្មាំងនេះ គឺជាជំហរ ឬក៏យល់ឃើញរបស់មេភូមិ?

[១៤:៣០:១៥]

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំមិនបាននៅចាំ មិនដឹងបាននិយាយ ឬក៏មិនបានអី ព្រោះពេលនោះខ្ញុំ តែការធ្លាប់ដឹង ធ្លាប់ឮក្នុងសម័យនោះ អារឿងបាក់ចាន បាក់ស្តាបព្រាអីៗហ្នឹង មិនមែនជាការងាររបស់រដ្ឋាភិបាលទេ អា

ហ្នឹងការងារមេក្រុម មេភូមិហ្នឹង កំប៉ិកកំប៉ុក មិនមែនបង្កជារឿងធំដុំអីណា អាហ្នឹងខ្ញុំគ្រាន់អានក្នុងចិត្តខ្ញុំទេ ឬអារម្មណ៍តែងនិយាយប្រាប់គ្នីគ្នាទៅវិញទៅមក មុននឹងគេថាខ្ញុំ។ ហ្នឹងបានតែប៉ុណ្ណឹងទេ។

**ស៖** ក្នុងឋានៈលោកធ្វើការនៅថ្នាក់ស្រុក តើអាជ្ញាធរមូលដ្ឋានត្រូវតែគោរពតាមថ្នាក់លើ ដើម្បីរកខ្មាំងគ្រប់ទីកន្លែង គ្រប់ច្រកល្ហកទាំងអស់នោះឬទេ? តើនៅក្នុងឯកសារទង់បដិវត្តមានបង្គាប់ណែនាំឱ្យលោកនេះត្រូវតែតាមដានឃ្លាំមើលខ្មាំងគ្រប់ពេលវេលា ដោយប្រុងប្រយ័ត្ននោះដែរឬទេ?

**ឆ៖** ខ្ញុំមិនបានទទួលភារកិច្ច ឬការងារដែលហៅថា តាមដាន ស៊ើបអង្កេតអីនោះទេពេលនោះ។ វាមិនដឹងស៊ើបរឿងអី បើក្បែរៗខ្លួនហ្នឹងតិចចាប់បាត់ តិចៗគណៈអីនេះ ឱ្យតែថ្នាក់កម្មាភិបាលលិចកើតសុទ្ធតែងាកចាប់បាត់ ងាកចាប់ គ្រាន់រកតាមដាន ស៊ើបពីណា គិតតែខ្លួនឯងឱ្យរួចខ្លួនបានហើយសម័យនោះ។ ខ្ញុំមានយោបល់តែប៉ុណ្ណឹង។

**លោក ឌេល លីសាក់៖**

សូមអរគុណច្រើនលោកដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការចំណាយពេលវេលាឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១៤:៣២ នាទី ដល់ម៉ោង ១៤:៤៨ នាទី)*

[១៤:៤៨:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក មានសំណួរ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរពីរដើម្បីសួរលោក។ សំណួរទី១ ពាក់ព័ន្ធនឹងកាលៈទេសៈដែលលោករងរបួស។ បើតាមខ្ញុំស្តាប់មិនច្រឡំទេកាលពីព្រឹកមិញនេះលោកថា លោករងរបួសក្នុងពេលប្រយុទ្ធគ្នា ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ តើខ្ញុំយល់អីចឹងត្រឹមត្រូវទេ? លោកអាចរៀបរាប់អំពីពេលដែលលោកត្រូវរបួសហ្នឹងបន្តិចបានទេ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំត្រូវរបួសក្រោយ១៧ មេសា រួចហើយហ្នឹងទេ ដូចលោកសួរខ្ញុំមក រឿងពិតតើ។

**ស៖** លោកឆ្លើយថា ពេលនុ៎ងគេបញ្ជូនលោកទៅក្បែរព្រំដែនវៀតណាម ហើយលោករងរបួសពេលប្រយុទ្ធគ្នា។ ពេលប្រយុទ្ធហ្នឹង ប្រយុទ្ធជាមួយអ្នកណា? ជាមួយនឹងកងទ័ពវៀតណាម ឬក៏ជាមួយកងទ័ពណា?

**ឆ៖** ពេលនោះមិនមែនគេបញ្ជូនខ្ញុំទៅទេ គឺខ្ញុំជាធ្វើកងទ័ពនៅប្រចាំព្រំដែនខេត្តក្រចេះ ស្រុកភ្លេចឈ្មោះហើយ។ អ៊ីចឹងភារកិច្ចខ្ញុំត្រូវការពារទឹកដីនៅព្រំដែនហ្នឹង ប្រយុទ្ធគ្មានសត្រូវណាក្រៅពីទាហានខាងពួកខ្ញុំ ហើយនិងទាហានយួនទេ ដែលវាចូលមកផុតទឹកដីយើង ខ្មែរយើងហ្នឹងណា។

[១៤:៥១:៤១]

**ស៖** បើខ្ញុំមិនច្រឡំទេ លោកបាននិយាយថា លោកបានប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាមខាងត្បូងដែលជួយដល់កងទ័ព លន់ នល់។ តើខ្ញុំយល់អ៊ីចឹត្រឹមត្រូវទេ? បើខ្ញុំនិយាយថា គឺវាមានរឿងពីរផ្សេងគ្នា ទី១គឺមុនឆ្នាំ៧៥ មានការប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាមដែលគាំទ្រ លន់ នល់ ហើយក្រោយឆ្នាំ៧៥ ក៏មានការប្រយុទ្ធគ្នាដែរ ជាមួយនឹងកងទ័ពវៀតណាមដែលចូលមកលុកលុយក្នុងទឹកដីកម្ពុជានៅខេត្តក្រចេះ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំនៅចាំ មិនមែនយួនខាងជើងទេ ព្រោះពេលនោះស្រុកខ្មែរ ១៧ មេសា រួចហើយយួនខាងត្បូងនៅក្នុងគេហៅស៊្កីគេ អ្នកដឹកនាំគណបក្ស -- នាយករដ្ឋមន្ត្រី បើអ៊ីចឹងមិនមែនយួនខាងជើងទេដែលនៅប្រយុទ្ធនៅពេលនុ៎ង គឺខ្ញុំប្រយុទ្ធជាមួយពួកអាធីវគី ពេលនោះខ្ញុំ។

**ស៖** ចុះយុទ្ធជនកងទ័ពវៀតណាមខាងត្បូងហ្នឹងជាអ្នកណា? យើងហៅពួក ធីវគី ឬក៏ជាអ្នកណា?

**ឆ៖** អាធីវគី ហ្នឹងគឺមេយួនខាងត្បូង ហើយត្រូវប្រយុទ្ធ ខ្ញុំតតាំង វានៅអត់ទាន់បូកបញ្ចូលគ្នានៅឡើងទេ យួនខាងជើង ហើយយួនខាងត្បូង នៅដាច់ដោយឡែក។

**ស៖** អ៊ីចឹងខ្ញុំចង់សួរលោកថា ទាហានដែលលោកប្រយុទ្ធជាមួយហ្នឹងជាពួកកុម្មុយនីស្ត ឬក៏ជាពួកទាហានរបស់ ធីវគី?

[១៤:៥៤:២០]

**ឆ៖** បាទ ខ្ញុំប្រយុទ្ធពួកទាហាន ធីវគី។

**ស៖** ដូច្នេះលោករងរបួសនៅពេលដែលលោកប្រយុទ្ធគ្នាជាមួយនឹងកងទ័ពរបស់ ធីវគី អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ ពិត។

**ស៖** លោកអាចរៀបរាប់អំពីរបួសរបស់លោកនៅពេលនោះបន្តិចបានទេ? លោកត្រូវរបួសហ្នឹង ត្រូវរបួសនៅកន្លែងណា? ហើយវាបង្កផលវិបាកអ្វីខ្លះចំពោះលោក?

**ឆ៖** ខ្ញុំរកកំណត់ពេលថ្ងៃណាមិនដឹងទេ គ្រាន់តែគិតទៅក្នុងដំណើរខ្ញុំរបួសបីដង ប្រយុទ្ធតែជាមួយពួកទាហានអាធីវគី យួនហ្នឹងទេ។ ទី១ របួសមធ្យម, ទី២ មធ្យម, ទី៣បាន អ្រោមិនថាធំអីទេ គ្រាន់តែបាក់ជើងខាងឆ្វេងទៅ ដើរលេងរួចបណ្ដោយ។ នេះខ្ញុំរបួស។

**ស៖** របួសទាំងអស់ហ្នឹង គឺលោកទៅត្រូវហ្នឹងគឺក្នុងពេលប្រយុទ្ធគ្នាតែជាមួយនឹងកងទ័ព ធីវគីទេមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ ចាំមីក្រូហ្វូនដំណើរការចេញភ្លើងក្រហមសិនចាំឆ្លើយ។

[១៤:៥៦:១៧]

**លោក សេង សឿន៖**

**ឆ៖** ម៉េចហើយទេអំមិញ សួរបញ្ជាក់។ ប៉ុន្តែខ្ញុំប្រយុទ្ធតែជាមួយទាហានអាធីវគី អត់ដែលទាហានស៊ីវិល ទាហាន លន់ នល់ ទេ គ្រាន់តែទៅដែរ ប៉ុន្តែមិនបានប្រយុទ្ធទេ អាហ្នឹងជាមួយទាហាន លន់ នល់ កាលនោះខ្ញុំ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ សូមអរគុណ។ ចុះកងទ័ពវៀតណាមកុម្មុយនីស្តនោះ លោកមានបានប្រយុទ្ធជាមួយទេ គឺកងទ័ពនៃទីក្រុងហាណូយ លោកមានបានប្រយុទ្ធជាមួយទេ?

**ឆ៖** ផុតហើយ ខ្ញុំពិការហើយ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ដឹងថា ពេលដែលលោកធ្វើការនៅស្រុកស្អាង មានអ្នកណាជាជនជាតិចាមទេដែលរស់នៅក្នុងស្រុកស្អាងរបស់លោកហ្នឹងណា?

**ឆ៖** ខ្ញុំទៅនៅស្រុកហ្នឹង ដូចជម្រាបបន្តបន្ទាប់មក ខ្ញុំអត់ទាន់ដឹងឯណាឯណីទេ។ ឃើញមនុស្ស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម្នា ប៉ុន្តែឯណាមានចាម មានចាមជ្វាអីមកនៅត្រង់ណាត្រង់ណី អត់ទាំងស្គាល់ផងហ្នឹង មិនបានមួយខែស្រួលបួលផងខ្ញុំ។

**ស៖** បាទ ដើម្បីឱ្យខ្ញុំយល់ច្បាស់។ ខ្ញុំអត់និយាយពីរឿងហេតុដែលកើតឡើងនៅខេត្តក្រចេះទេ ខ្ញុំនិយាយពេលដែលលោកបំពេញការងារមុននៅខេត្តក្រចេះ គឺដូចជាក្រោយពេលលោកចេញពីមន្ទីរជនពិការ លោកដឹងទេថា មានជនជាតិចាមនៅក្នុងតំបន់ដែលលោកបំពេញការងារហ្នឹងទេ?

[១៤:៥៩:០៤]

**ឆ៖** ខ្ញុំចេញពីតំបន់ហ្នឹងឯង ពិការរបស់តំបន់១៣ ទៅមន្ទីរពិការភូមិភាគនិរតី ខ្ញុំអត់ដែលបានជួបប្រជាជនចាមអីជ្វាអីទេ អត់ នៅតែកន្លែងពិការហ្នឹងទៅ អត់ដែលឃើញនៅជួបអីផង។

**ស៖** ក្នុងពេលរៀនសូត្រដែលលោកបានចូលរួម ក្នុងពេលណាមួយនោះ តើគេមានដែលនិយាយអំពីគោលនយោបាយជាក់លាក់ណាមួយចំពោះជនជាតិចាមទេ? ឧទាហរណ៍ដូចគេ -- លោកបាននិយាយអំពីគោលនយោបាយជាក់លាក់ចំពោះជនជាតិចិន និងជនជាតិវៀតណាម។ ចុះចំពោះជនជាតិចាមនោះ លោកធ្លាប់ឮគេនិយាយអំពីគោលនយោបាយណាមួយចំពោះពួកគាត់ទេ?

**ឆ៖** អត់ដែលឮទេ។ គេអត់ដែលនិយាយពីរឿងចាមអី អត់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំអស់សំណួរហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ ជាបន្តសូមជូនលោកមេធាវីការពារក្ដីលោក នួន ជា មានសំណួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ សូមគោរពភាគីទាំងអស់។

[១៥:០០:៥១]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីការពារមេធាវីជាតិការពារក្ដីលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួន ទាក់ទងនឹងប្រធានបទការរៀបអាពាហ៍

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ព្រឹកមិញ គឺក្នុងព្រឹកមិញ ហើយក៏ដូចជាមុនសម្រាក គឺលោកបានឆ្លើយច្រើនហើយ ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើឆ្លងកាត់បទពិសោធន៍ ឬក៏ការសង្កេតរបស់លោកផ្ទាល់ លោកមានដែលឃើញ មានគូយុវជនណា ឬ/និងយុវនារីណា ដែលគាត់ព្រមព្រៀង គាត់ស្រឡាញ់គ្នា ហើយគាត់ស្នើសុំរៀបការទៅថ្នាក់លើ ឬក៏ទៅកម្មាភិបាលដែលគ្រប់គ្រងគាត់ សុំរៀបបានដែរទេ លោកដែលបានឃើញ ឬបានជួបប្រទះបែបនេះទេ?

**លោក សេង សឿន៖**

**ឆ៖** រឿងហ្នឹង ខ្ញុំជួបប្រទះដែរ។ មិនមែនដែលទេ ជួបហើយ ជួយដោះស្រាយ។ ហ្នឹងកាលខ្ញុំនៅស្អាងនេះ ឯស្រុកខេត្តណាទេ ខ្ញុំមិនដឹងទេ ប៉ុន្តែស្រុកស្អាងហ្នឹង ឃើញមួយគូ ពីរគូ ដល់វាស្រឡាញ់គ្នាទៅ វានាំគ្នាមកលើកដៃសំពះ។ កាលហ្នឹង បងផុន ហ្នឹងគាត់គណៈស្រុកហ្នឹង រៀបឱ្យវាទៅ មានកើតអី។

**ស៖** បាទ អ៊ីចឹងក្នុងករណីដែលគាត់ស្រឡាញ់គ្នា គាត់មកសុំចៅហ្វាយស្រុក ឬក៏មេគាត់ហ្នឹង គឺមេគាត់អនុញ្ញាតឱ្យគាត់រៀបការបានដែរ អ៊ីចឹងលោក?

[១៥:០២:៥៦]

**ឆ៖** នេះខ្ញុំនិយាយតែ បងផុន គណៈស្រុកទេ ដែលអារកាត់អ៊ីចឹង តែមេៗខាងក្រោមអីត្រូវរៀបការអីអ៊ីចឹង ដូចអត់មានឮ មានកិច្ចធ្វើអ៊ីចឹងទេ។ ខ្ញុំជួបប្រទះតែម្តងប៉ុណ្ណឹងទេ ដែលគេ វាស្រឡាញ់គ្នាហើយ ក៏នាំគ្នាមកសំពះទាំងពីរហ្នឹង ទាំងពីរនាក់ប្តីប្រពន្ធហ្នឹងតែម្តងទៅ គាត់ព្រមទៅៗ។ ជាការស្រេចឯផ្សេងទៀត អត់ដឹងដែរ។

**ស៖** បាទ អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងបទពិសោធន៍ ក៏ដូចជាការងាររបស់លោក តើលោកដែលឮសីលធម៌១២ប្រការរបស់ជនបដិវត្តទេ? លោកមានដែលឮគេលើកអំពីសីលធម៌១២ប្រការរបស់ជនបដិវត្តហ្នឹង លោកដែលឮទេ?

**ឆ៖** រឿងហ្នឹង ដូចជាថាមេរៀន ប៉ុន្តែឥឡូវនេះខ្ញុំភ្លេចបាត់ហើយ រឿងប៉ុន្មានប្រការ ប៉ុន្មានប្រការហ្នឹង ប៉ុន្តែវាដូចជាគ្មានន័យអីផងទេ តាមខ្ញុំនេះគិតទៅ។ បើនិយាយឱ្យខ្លីតែម្តង គឺថាងាកងាប់ ឮតែចាប់។ ឯសម័យនោះ ឱ្យតែចាប់ខ្លួន អត់ដែលមកវិញទេ គឺថាទៅ ទៅបង្ហួតតែម្តង។ ខ្ញុំថា អ្ហ៎! ស្រេចហើយយើង ដឹងឯណា រឿងឯណីទេអ្ហា! ទាំងគេ ទាំងអញ។ នេះខ្ញុំគ្រាន់តែនិយាយតែប៉ុណ្ណឹងទេ មិនបាន

និយាយរឿងមួយប្រកបប៉ុន្មានកាំប្រការអី ក៏អត់មានចាំទេ។ ដឹងដែរ ព្រោះរៀនដឹងណាស់ដែរ ប៉ុន្តែវាលែងចាំហើយឥឡូវហ្នឹង។

**សៈ** ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នេះដែរ លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានឯកសារលេខ E3/765 គឺទង់យុវជន និងយុវនារីបដិវត្ត នៅក្នុង ERN ជាភាសាខ្មែរមានលេខ 00376493-94, ភាសាអង់គ្លេសមានលេខ 00539994, បារាំងមានលេខ 00540024 ដល់25។ ក្នុងហ្នឹងគឺប្រការទី៦ គឺសីលធម៌១២ប្រការហ្នឹង ប្រការទី៦ថា៖ "កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ។ និយាយរួមគឺកុំប៉ះពាល់សីលធម៌នារីបុរសឲ្យសោះ ព្រោះបញ្ហានេះ វាប៉ះពាល់ដល់កិត្តិយស ឥទ្ធិពលយើងជាជនបដិវត្តនាំឲ្យប៉ះពាល់ដល់ប្រពៃណីស្អាតស្អំ ថ្លៃថ្នូរបស់ប្រជាជនយើង។ ចំពោះបញ្ហារៀបគ្រួសារ បច្ចុប្បន្ននេះគ្មានអ្វីជាឧបសគ្គទេ ឲ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាងគឺ ទី១ សាមីខ្លួនទាំងសងខាងយល់ព្រម, ទី២ សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ។ តើមានហេតុផលអ្វីនាំឲ្យយើងប៉ះពាល់សីលធម៌នារីបុរស។" ខ្ញុំបិទការដកស្រង់។ អ៊ីចឹងលោកដែលឮសីលធម៌ចំណុចទី៦នេះដែលទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ មានដែលផ្សព្វផ្សាយដែរទេ?

[១៥:០៦:៤៣]

**ឆៈ** រឿង ខ្ញុំវាហួសពីឮហើយ ប៉ុន្តែវាការអនុវត្ត មិនដឹងជាទៅខាងណាមកខាងណីទេ ព្រោះក្នុងសម័យហ្នឹងតឹងតែងណាស់ គឺខ្ញុំជួបផ្ទាល់អារឿងយុវជននារី នៅទ័ពជាមួយខ្ញុំ ហើយវាស្រឡាញ់គ្នាគេហៅថាខូចគ្នាហ្នឹង។ ស្រឡាញ់រួចលួចលាក់ បាញ់គ្នាចោលហើយ នៅផ្ទាល់ជាមួយខ្ញុំហ្នឹង ក្នុងកងជាមួយគ្នា ប៉ុន្តែអាមួយធ្វើ ខ្ញុំមេក្រុម អានេះវាមេក្រុមខាងណោះ។ នៅកាលខ្ញុំនៅ នៅកងទ័ពជាមួយ បងបាវ។ អាមួយទៀតអ៊ីចឹងដែរ គិតទៅ ខ្ញុំជួបផ្ទាល់ អាហ្នឹងធ្វើម៉េច គ្នាវាជ្រុលហើយ ស្រឡាញ់គ្នាហើយទៅជាសម្លាប់វាដែរហ្នឹង។ ខ្ញុំគ្រាន់តែបានដឹងរឿងតែប៉ុណ្ណឹង ដំណើរខ្ញុំ។

**សៈ** លោកលើកឡើងអំមិញថា គាត់លួចលាក់ស្រឡាញ់គ្នា គេសម្លាប់គាត់។ សំណួរខ្ញុំសួរថា ចុះពួកគាត់មុនដែល គាត់ស្រឡាញ់គ្នា តើគាត់មាន មុនដែលសម្លាប់ គាត់បានសុំទៅប្រធានគាត់ ប្រធានកងគាត់ ឬក៏ប្រធានថ្នាក់ណាមួយរបស់គាត់ សុំរៀបការជាមួយគ្នាដែរឬទេ?

**ឆៈ** អ៎! ខ្ញុំរឿងនិយាយពីអាពីរគូហ្នឹងដែលគេសម្លាប់ហ្នឹង វាអត់បានរាយការណ៍ប្រាប់ទៅមេគេទេ លេសលួចលាក់ គេដឹង ក៏គេសម្លាប់វាទៅ។

[១៥:០៨:៣០]

**ស៖** បាទ សូមអរគុណ។ មុននោះលោកបានថ្លែងថា ពេលដែលលោកធ្លាប់បានផ្គូផ្គងពីរលើកសម្រាប់ការរៀបអាពាហ៍ពិពាហ៍ នៅពេលដែលលោកធ្វើជាប្រធានមន្ទីរស្រុកស្អាង។ អ៊ីចឹងលោកបានថ្លែងទៀតថា ប្រធានកងបុរសបានយកបញ្ជី និងប្រធានកងនារី ក៏យកបញ្ជីមួយមកជូនលោក។ អ៊ីចឹងសំណួរខ្ញុំសួរថា តើពេលដែលប្រធានកងបុរស និងប្រធានកងនារី ដែលយកបញ្ជីអ្នកដែលត្រូវរៀបការមកជូនលោក តើពួកគាត់បានពិភាក្សាជាមួយលោកថា អ្នកណាដែលគាត់អាចស្នើរៀបការជាមួយគ្នាតាមឆន្ទៈរបស់គាត់ទាំងពីរ គាត់មានៗដែលបានបង្ហាញបែបនេះទេ?

**ឆ៖** អត់ទេ។ អ៊ីចេះទេ គេយកប្រវត្តិរូបខាងនារី ខាងបុរសនៅកងចល័តហ្នឹង គេជូនទៅគណៈស្រុក បានគណៈស្រុកគាត់ប្រើគេឲ្យយកមកឲ្យខ្ញុំ ហើយអត់មានឲ្យផ្ទាល់ដៃពីពួកហ្នឹងទេ។

**ស៖** ពេលនោះ តើលោកបានពិភាក្សាជាមួយនឹងប្រធានកងបុរស និងប្រធានកងនារីនោះដែរទេមុនដែលលោកផ្គូផ្គងនោះ?

**ឆ៖** អត់ទេ អត់បានជួប បាននិយាយទេ។ ខ្ញុំសរសេរផ្គូផ្គងតែម្នាក់ខ្ញុំទេ ហើយដល់ពេលគេត្រូវប្រកាសទៅ ខ្ញុំយកបញ្ជីឈ្មោះហ្នឹងទៅឲ្យបងគណៈស្រុកហ្នឹងទៅ។

[១៥:១០:៣២]

**ស៖** បាទ អរគុណ។ កាលពីព្រឹកមិញលោកបានថ្លែងថា នៅពេលថ្ងៃរៀបការនោះ គឺប្រធានគណៈស្រុកហ្នឹងបានប្រកាសថា បើអ្នកណាចង់បដិសេធមិនរៀបការ ពួកគាត់អាចដើរចេញបាន។ ហើយសំណួរសួរ មានសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីថា នៅពេលដែលគាត់ដើរចេញទៅ មានរឿងអីកើតឡើង? ហើយលោកបានលើកឡើងថា លោកអត់បាននៅទេ មិនដឹងរឿងកើតឡើងទេ។ ប៉ុន្តែបើមើលទៅលើចម្លើយរបស់លោក ឯកសារ E3/409 សំណួរទី៧៤ ខ្ញុំបាទសូមដកស្រង់ សំណួរសួរថា ៖ "តើអ្នកទាំងអស់នោះទទួលការគំរាមកំហែងថា ប្រសិនបើគេបដិសេធមិនរៀបការ ត្រូវពួកគេសម្លាប់មែនទេ? ចម្លើយរបស់លោក ចម្លើយ៧៤ បានឆ្លើយថា៖ នៅក្នុងពេលប្រកាសឈ្មោះនៃអ្នកត្រូវរៀបការ ពួកគេត្រូវបានគណៈស្រុកប្រាប់ថា ប្រសិនបើគេចង់បដិសេធ ពួកគេអាចធ្វើបាន ប៉ុន្តែតាមការពិតប្រសិនបើបុរស និងស្ត្រីមិនគោរពការរៀបការនេះ បុរស និងស្ត្រីនោះអាចមានបញ្ហា។ អ្នកដែលមានបញ្ហាជាមួយនឹងការរៀបការនេះ អាចត្រូវបានគេបញ្ជូនទៅការដ្ឋាន។" អ៊ីចឹងសំណួរខ្ញុំសួរថា តើការបញ្ជូនទៅការដ្ឋានហ្នឹង វាមានន័យយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំដូចជាមិនបាននិយាយរបៀបហ្នឹងទេ។ ខ្ញុំដឹង ហើយខ្ញុំតែងនិយាយថា ឲ្យសិទ្ធិពេល

ប្រកាសហើយ ខាងស្រីក៏ដោយ ខាងប្រុសក៏ដោយ បើមិនពេញចិត្តទេ ក្រោកចេញ។ ហើយអ៊ីចឹងវាមានហ្នឹង ដល់ពេលអ៊ីចឹង មានតើ មានចេញ ជូនស្រី ជូនប្រុស ពីរវគ្គហ្នឹង ដែលខ្ញុំធ្វើការហ្នឹង។ តែត្រង់ថាអ្នកដែលក្រោកចេញទាំងអស់ ខាងស្រីខាងប្រុសហ្នឹង គេមានទោសកំហុសអី យ៉ាងណា ខ្ញុំអត់បានដឹងព្រោះគេទៅនៅកងចល័តឯនោះ ឯងខ្ញុំនៅឯមន្ទីរនេះ មិនបានទៅដឹងទេ ព្រោះកិច្ចការយ៉ាងណាមេចល័តខាងស្រីខាងប្រុសហ្នឹង គេគ្រប់គ្រងនោះ ហើយគណៈស្រុកអីទេ។ ខ្ញុំអត់ លែងដឹងត្រឹមតែប៉ុណ្ណឹង។

[១៥:១៣:១៣]

**ស៖** បាទ អរគុណ។ ខ្ញុំចង់បញ្ជាក់មួយចំណុចទៀត គឺទាក់ទងនឹងសំណួរចម្លើយទី៧៥ ក្នុងហ្នឹងសំណួរគេសួរលោកថា៖ "នៅក្នុងគំនិតរបស់លោក តើមនុស្សទាំងអស់ត្រូវបានគេបង្ខំឱ្យរៀបការ ឬក៏រៀបការដោយស្ម័គ្រចិត្ត? ចម្លើយទី៧៥ របស់លោកបានឆ្លើយថា៖ វាមិនមែនជាការរៀបការដោយបង្ខំទេ ប៉ុន្តែពិធីរៀបការត្រូវធ្វើឡើងស្របតាមផែនការតំបន់។" អ៊ីចឹងលោកលើកឡើងថា ពិធីរៀបការត្រូវធ្វើឡើងស្របតាមផែនការតំបន់ហ្នឹង តើពិធីហ្នឹងលោកសំដៅទៅលើអ្វី? ហើយតាមផែនការតំបន់ហ្នឹង តើតំបន់ដាក់យ៉ាងម៉េច?

**ឆ៖** ខ្ញុំបាននិយាយថា រឿងផែនការនេះមិនមែនបង្ខំ ក៏បើនិយាយឱ្យចំ ពួកអស់នេះមិនអ្នកស្រឡាញ់គ្នាទេ។ មិនដឹងជានៅឃុំអីណា ស្រុកអីណា មិនត្រូវ មិននៅ នៅឆ្ងាយពីគ្នា។ អ៊ីចឹងប្រើពាក្យថា "បង្ខំ" ក៏ពិបាកថា។ ឥឡូវគេចាត់តាំង ក៏មិនដឹងថាម៉េច។ ប៉ុន្តែដល់អ៊ីចឹងពេលហ្នឹង ផែនការរបស់បក្សថ្នាក់ស្រុក ថ្នាក់តំបន់គេឱ្យទិសដៅទៅថា ឱ្យរៀបការទៅ អាយុចាស់ៗអស់ហើយ ខាងស្រី ខាងប្រុសហ្នឹង។ អ៊ីចឹងខ្ញុំមិនដឹងថា យកពាក្យណាដែលត្រូវថា ដោយបង្ខំ តែអត់ស្រឡាញ់គ្នាទេ។ អ៊ីចឹងគឺថារៀបការ របៀបណេះ ថាឱ្យដូចគេចាត់តាំង។ អាហ្នឹងខ្ញុំពិបាកនឹងនិយាយ ប្រើពាក្យថា "បង្ខំ" ឬក៏គេចាត់តាំងទេ។ នេះយោបល់ខ្ញុំ គ្រាន់គិត និងគិតអ៊ីចេះដែរ គិតចុះគិតឡើងក្នុងចិត្តហ្នឹងណា៎។

**ស៖** អ៊ីចឹងផែនការថ្នាក់លើ សុំលោកបញ្ជាក់តិចមើល ផែនការដែលលោកនិយាយ ផែនការរបស់ថ្នាក់ស្រុកហ្នឹង ដាក់មកហ្នឹង តើផែនការហ្នឹង គាត់ឱ្យគ្រាន់តែថាជំរុញឱ្យមានការរៀបការរវាងបុរស និងនារីដែលយល់ថាវ័យចាស់ហើយ ឬមួយក៏មានផែនការអីផ្សេងទៀត?

[១៥:១៥:៥៣]

**ឆ៖** បាទ អត់មានអី ផែនការអីទៀតទេ ព្រោះគ្រាន់តែរៀបការរួចហើយ មួយក្រុមគ្រួសារហ្នឹងៗនៅក្នុងឃុំណា ព្រោះក្នុងស្រុកហ្នឹងវាមានច្រើនឃុំអ៊ីចឹង។ រៀបការហើយមកកងចល័តហ្នឹង។

ដល់អ៊ីចឹងពេលរៀបការ គណៈឃុំគ្រប់ឃុំហ្នឹង គេមកចាំទទួលយកទៅនៅជាសហករណ៍របស់ឃុំគេ អ្នកដែលគេរៀបការទៅ ព្រមព្រៀងគ្នាទៅជាតាមគូៗទៅ អាហ្នឹងអត់មានអីទៀត។

**ស៖** ទាក់ទងដែលលោកលើកឡើងអំមិញថា ប្រធានឃុំគាត់មកចាំទទួលទៅសហករណ៍វិញ ហ្នឹង អ៊ីចឹងសំណួរខ្ញុំសួរថា ស្ថានភាពរបស់អ្នកដែលរៀបការ ហើយនិងអ្នកដែលនៅលីវ តើស្ថានភាព ការងារខុសគ្នាយ៉ាងណាដែរ?

**ឆ៖** ខ្ញុំម៉េចនឹងដឹងចិត្តគេទៅ បើអ្នកនៅលីវៗហ្នឹងគេ អាណាក៏គេនៅ ស្រេចចង់បានប្រពន្ធ អាណាក៏មិនទាន់ចង់បាន។ អ៊ីចឹងអាហ្នឹងលើចិត្តរបស់គេ ហើយខ្ញុំមិនដឹងដែរ។

**ស៖** បាទ សុំទោសប្រហែលជាសំណួរខ្ញុំមិនច្បាស់។ អំមិញលោកថា នៅពេលដែលរៀបការ ហើយ គឺខាងគណៈឃុំគេចាំទទួលគូស្វាមីថ្មីហ្នឹងទៅ ប្តីប្រពន្ធទៅរស់នៅក្នុងសហករណ៍។ ហើយពី កាលពីព្រឹកលោកបានឆ្លើយថា កាលណារៀបការហើយ គឺពួកគាត់លែងទៅកងចល័តទៀតហើយ។ អ៊ីចឹងបានសំណួរខ្ញុំសួរថា តើស្ថានភាពការងារ ខ្ញុំចង់ដឹងស្ថានភាពការងារនៅកងចល័ត ហើយនិង ស្ថានភាពការងារនៅក្នុងសហករណ៍ហ្នឹង តើស្ថានភាពការងារខាងណាគេប្រសើរជាង?

**ឆ៖** អាហ្នឹងវា ៗមិនដូច ជាដូចទេ។ គ្រាន់តែគេរៀបកងជាកងៗ អាហ្នឹងកងចល័ត ដែលមក នៅភូមិ នឹងឃុំនេះជាសហករណ៍។ អាហ្នឹងគេហៅអ្នកមានប្តី មានប្រពន្ធ បានធ្វើសហករណ៍។ គេនៅ លីវៗនេះ គេកងចល័ត។ អាហ្នឹងគ្រាន់បែងចែក ប៉ុន្តែការធ្វើស្រែទាំងអស់តែគ្នាហ្នឹង។

[១៥:១៨:២៨]

**ស៖** បាទខ្ញុំសួរអ៊ីចេះវិញ ថាតើកងចល័ត លោកអំមិញថាធ្វើស្រែ ក្រៅគេធ្វើស្រែ តើកងចល័ត មានធ្វើការងារអីផ្សេងទៀតទេ?

**ឆ៖** សម័យនោះអត់មានអីក្រៅពីរែកដីធ្វើទំនប់ ហើយនិងធ្វើស្រែហ្នឹង មានតែប៉ុណ្ណឹង។

**ស៖** បាទ ចុះអ្នកដែលនៅក្នុងសហករណ៍វិញ ក្រៅពីការធ្វើស្រែគាត់ តើគាត់ធ្វើអីទៀតដែរទេ?

**ឆ៖** រឿងហ្នឹង ខ្ញុំដូចពិបាកនឹងឆ្លើយណាស់ ព្រោះស្រុក ទាំងគ្រប់ខេត្តហើយ មានអី មានតែ ស្រែមួយមុខសម័យហ្នឹង អត់មានរបបរកស៊ីអី ជួញដូរអីផងហ្នឹង។ ដឹងតែងាកស្រែ ងាកស្រែ សែងដី ធ្វើទំនប់ប្រឡាយអី តែប៉ុណ្ណឹង ការងារសម័យកាលនុ៎ង មិនថាសហករណ៍ មិនថាកងចល័ត។ គេ ប្លូកឡូកទាំងអស់តែគ្នាកាលនុ៎ង។

**ស៖** បាទ អរគុណ។ ឥឡូវលោកថា លោកបានរៀបការជាមួយនឹងប្អូនជីដូនមួយរបស់លោក

គណៈស្រុក សៅ ផុន។ អ៊ីចឹងតើប្រពន្ធរបស់លោកហ្នឹងគាត់ឈ្មោះអីដែរ?

**ឆ៖** ខ្ញុំជូនឈ្មោះគាត់ឈ្មោះ ចន ហៅ រ៉ន នៅភូមិដូង ឃុំដូង ស្រុកស្រែក្នុង ជាប្អូនជីដូនមួយ សៅ ផុន។ ខ្ញុំនៅចាំឈ្មោះឪពុកនាងហ្នឹង ឈ្មោះ ណយ ឯម្ដាយខ្ញុំភ្លេចទៅហើយ គ្រាន់តែប្រាប់ដែរហ្នឹង មិនដែលទៅស្គាល់ឪក្មេក ម៉ែក្មេងមុខយ៉ាងម៉េចផង ខ្ញុំរៀបការរួច បានបន្តិចនេះ រៀបនឹងទៅ បងផុន អត់ឲ្យទៅ ទទួលគេផ្លាស់ឲ្យទៅក្រចេះហ្នឹងទៅ ល្មមត្រង់ហ្នឹងទៅ។

**ស៖** បាទ ពេលការរួចហើយ តើប្ដីប្រពន្ធរបស់លោករស់នៅផ្ទះតែមួយ ឬក៏រស់នៅកន្លែងផ្សេងគ្នា?

[១៥:២១:១៥]

**ឆ៖** គេធ្វើបុគ្គលិក នែ៎!បុគ្គលិកពេទ្យស្រុកនៅស្អាងហ្នឹង គេមានផ្ទះគេមួយជួរអ៊ីចឹង អ្នកមានគ្រួសារ មានបន្ទប់ៗៗទៅ ប្រពន្ធខ្ញុំហ្នឹងគេនៅមួយបន្ទប់បន្តបន្ទាប់ៗគ្នាពីរបីនាក់ហ្នឹងទៅ។ អាហ្នឹងពេលដែលខ្ញុំទៅដេកនៅហ្នឹង។

**ស៖** រយៈពេលដែលលោកលើកឡើងថា ការហើយបានមួយរយៈត្រូវបែកគ្នាដែលលោកត្រូវផ្លាស់ទៅខាងខេត្តក្រចេះ អ៊ីចឹងរយៈពេលហ្នឹងតាមការចងចាំរបស់លោកប្រហែលជាប៉ុន្មានខែដែរ?

**ឆ៖** គិតពីរៀបការហើយ ខ្ញុំឲ្យរួមរស់គ្នា ហើយនិងផ្លាស់ទៅនៅក្រចេះហ្នឹង ប្រហែលជាពីរខែ មិនដល់បីទេ ប្រហាក់ប្រហែលពីរជាង ពីរខែជាងហ្នឹង ត្រូវផ្លាស់ខ្ញុំទាំង បងផុន ទាំងអី ទាំងខ្ញុំ និងគាត់ហ្នឹងទៅក្រចេះទៅ។ ទៅត្រូវបាន១ខែស្រួលបួលផង ខ្វះពីរបីថ្ងៃគ្រប់១ខែ យួនវ៉ៃចូលទៅ ក៏ទៅដល់ភ្នំដងរែកទៅ។

**ស៖** បាទ ក្នុងរយៈពេលហ្នឹង តើលោកមានបានរួមដំណេកជាមួយនឹងប្រពន្ធលោកទេ?

**ឆ៖** អត់មានទេ ខ្ញុំមានដំណឹងអីទេរហូត។ ឥឡូវកាលនុំងមានទូរស័ព្ទទាក់ទងអី អត់មានទេ ទាំង បងផុន ទាំងខ្ញុំ ទាំងអីហ្នឹង គាត់ហ្នឹងប្រាស់ព្រាត់ទៅ ៗនៅភ្នំដងរែករហូតចុះសមរភូមិមកវិញមកក្រចេះវិញទៀតទៅ អត់មានបានដឹងដំណឹងអីទាក់ទងអីគ្នាអត់បាន ក្រចេះទៅដល់ឯកំពតនេះ ស្រែក្នុងឯណោះ រហូតទៅ។

[១៥:២៣:៣៤]

**ស៖** បាទ សូមទោសប្រហែលជាសំណួរខ្ញុំ ៗសូមដូរពាក្យវិញ។ រយៈពេលជាងពីរខែនេះដែលលោករស់នៅជាមួយនឹងប្រពន្ធរបស់លោកហ្នឹង តើលោកមានបានរួមភេទជាមួយគ្នាដែរទេ?

**ឆ៖** ខ្ញុំដឹងថាប្រពន្ធគេប្រាប់ថា នេះគេមានកូន២ខែហើយ គ្រាន់តែបាន តែខ្ញុំគ្រាន់តែនិយាយប្រាប់ទេណ៎ា រួចមកក៏ខ្ញុំទៅក្រចេះអ៊ីចឹងទៅ។

**ស៖** បាទ អរគុណ។ អ៊ីចឹងប្រពន្ធរបស់លោកមានបានប្រាប់លោកថា គាត់សប្បាយចិត្តនឹងការរៀបការជាមួយលោកដែរឬទេ?

**ឆ៖** ដល់ពេលហ្នឹង គេថាជ្រុលនឹងឲ្យចូលនេះទៅហើយ វាលែងនិយាយចំពីរឿងស្រឡាញ់ ឬមិនស្រឡាញ់អីទេ គេៗដូចថាចប់ត្រឹមហ្នឹងទៅហើយ មិនបាច់សួរនាំអីទៀតទេអានេះ រឿងថាស្រឡាញ់មិនស្រឡាញ់អី លែងនិយាយបណ្តោយទៅ។

**ស៖** បាទ អ៊ីចឹងការរួមរស់ជាមួយគ្នា លោកជាមួយប្រពន្ធលោកហ្នឹង គឺមានការបង្ខិតបង្ខំ ភាគីណាបង្ខិតបង្ខំគ្នាទៅវិញទៅមក ឬមួយក៏ជាការស្ម័គ្រចិត្តទាំងសងខាង?

**ឆ៖** រឿងខ្ញុំមិនមែនជាការស្រឡាញ់គ្នា ក៏មិនបាន មិនដែរ។ ហើយថាគេបង្ខំ ក៏មិនៗដែរ ប៉ុន្តែមានម៉ូយគេអ្នកទាក់ទងឲ្យយកប្រពន្ធ ដល់ពេលខ្ញុំយកហ្នឹង ហើយពេលហ្នឹងខ្ញុំមិននឹកថា ស្រឡាញ់អីទេ គិតតែចង់តែបានទៅលេងឯណាឲ្យឆ្ងាយៗខេត្តនេះ ខេត្តនោះទៅ ប៉ុន្តែគាត់ចេះតែនិយាយចុះ និយាយឡើងទៅ ពីរបីសា បីៗបួន បីសាអីណោះ ឲ្យយកប្រពន្ធហ្នឹងបាន សួរច្រើនដងពេក យកក៏យកទៅ។ ក៏អ៊ីចឹងទៅ។

**ស៖** បាទ។ ការដែលគាត់និយាយជាមួយលោកឲ្យការប្រពន្ធហ្នឹង តើគាត់និយាយជាបែបលួងលោម ឬមួយក៏ជាការគំរាមកំហែង?

[១៥:២៦:៣១]

**ឆ៖** អ្នកដែលទាក់ទងឲ្យខ្ញុំយកប្រពន្ធហ្នឹង នារីទេ គាត់អនុប្រធានពេទ្យ អត់មែនការអ្នកគំរាមកំហែងអីខ្ញុំទេនារីហ្នឹង។ បើ បងផុន គណៈស្រុកហ្នឹង មុនគាត់និយាយដែរ "ឯងត្រូវតែយកទៅ ប៉ុន្តែកុំយកគេនោះណ៎ា នែ! អញអត់ទទួលស្គាល់ទេណា មីមួយធ្វើកាត់ដេរនោះ។" អ៊ីចឹងខ្ញុំថា "យី! ចង់សម្តុតឲ្យឯងយកប្អូនគាត់តើហ្នឹង"។ មិនមែនសម្តុតកាចទេ។ ហើយក៏ហីទៅ ខ្ញុំក៏គាត់រៀបការអ៊ីចឹងទៅ។

**ស៖** ឥឡូវលោកក៏បានលើកដែរពីព្រឹកមិញថា មានប្អូនជីដូនមួយមួយរបស់លោក បានរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ។ អ៊ីចឹងតើពួកគាត់ហ្នឹងនៅរស់ រស់ដល់សព្វថ្ងៃ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** រឿងនៅរស់ ឬស្លាប់នោះ ខ្ញុំអត់ដឹងផង ឥឡូវនេះ មិនដែលដឹងដំណឹងអីឯណាឯណីសោះ

ហើយខ្ញុំ។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។

សូមអរគុណលោកប្រធាន ខ្ញុំសូមប្រគល់វេទិកាជូនសហភាគីរបស់ខ្ញុំ គាត់បន្ត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កូប៉េ!

[១៥:២៨:៣៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយបន្តនឹងបញ្ហានៃការរៀបការ។ ចម្លើយរបស់លោកនៅ៧៥នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺ E3/409 ដែលសហព្រះរាជអាជ្ញាបានសួរលោក ហើយសហសេរីកខ្ញុំអំមិញហ្នឹង ក៏បានសួរលោកដែរ។ អ៊ីចឹងខ្ញុំសួរឲ្យមានការបំភ្លឺ ហើយខ្ញុំអានសំណួរ និងចម្លើយម្តងទៀត។ “សំណួរ៖ គឺថាតាមគំនិតរបស់លោក តើគេបង្ខំឲ្យប្រជាជនរៀបការ ឬក៏រៀបការដោយស្ម័គ្រចិត្ត? លោកឆ្លើយថា៖ មិនមែនជាការបង្ខំទេ គឺគេរៀបការទៅតាមផែនការតំបន់។” អម្បាញ់មិញនេះ ក៏លោក<ក៏បាន>និយាយប្រើពាក្យថា “រៀបការដោយបង្ខំ<>”។ <លោកក៏បានប្រើពាក្យថា> “រៀបការ<ដោយការផ្សំផ្គុំ” ដែរ>។ ហើយលោកទើបតែបានស្តាប់អំពី<សីលធម៌ទី៦ ក្នុងចំណោម>សីលធម៌១២ប្រការដែលសហសេរីករបស់ខ្ញុំ អានឲ្យលោកស្តាប់។ ខ្ញុំសួរលោកថា តើលោកយល់ស្របជាមួយខ្ញុំឬទេ ថាគូស្រករដែលគេបង្ខំឲ្យរៀបការនោះ ហើយអ្នកដែលបង្ខំ ឬការបង្ខំនោះ គឺអាចជាការបំពានទៅលើសីលធម៌ទី៦នៃសីលធម៌១២ប្រការរបស់បដិវត្តន៍?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:៣០:៣១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់លោកប្រធាន ពីព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណី គាត់បាននិយាយថា គាត់មិនដឹងអំពីសីលធម៌១២ប្រការ ជាពិសេសប្រកាសទី៦ហ្នឹងទេ។ ដូច្នេះសំណួរនេះគឺជាសំណួរនាំមុខហើយលោកប្រធាន។ មេធាវីព្យាយាមចង់បានចម្លើយពីសាក្សី នូវអ្វីដែលគាត់ចង់បាន។ ដូច្នេះសូមឲ្យមេធាវីរៀបចំសំណួរនេះឡើងវិញ ដើម្បីឲ្យមានលក្ខណៈបើកចំហ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ទាក់ទងទៅនឹងការជំទាស់របស់មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។ តាមពិតទៅ តាមអ្វីដែលខ្ញុំចាំ គឺដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់មិនចាំអំពីគោលការណ៍១២ប្រការនេះទេ ប៉ុន្តែមិនមានន័យថា គាត់មិនធ្លាប់បានដឹងពីមុនមកទេ គាត់បានហើយគាត់ធ្លាប់បានរៀនសូត្រផងដែរ ក៏ប៉ុន្តែគាត់មិនអាចចាំបាន។ ដូច្នេះសំណួរនេះ មិនមែនជាសំណួរនាំមុខទេបាទ។ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំក៏យល់ដូច្នោះដែរ ហើយគាត់មិនបានចាំដោយរត់មាត់ទេនៅពេលនេះ ប៉ុន្តែនៅពេលនោះ គាត់បានដឹងពីសីលធម៌ហ្នឹង ហើយ<យើង>បានអាន<ឲ្យគាត់ស្ដាប់>ម្ដងទៀតនូវប្រការទី៦ ដើម្បីអាចសួរទៅដើមបណ្ដឹងរដ្ឋប្បវេណី។ អ៊ីចឹងជាសំណួរដែលមកវគ្គខាងចុងនៃវគ្គនោះ ថាទាក់ទងទៅនឹងបញ្ហានៃការរៀបការ អ៊ីចឹងគឺគប្បីតែខ្ញុំមានការអនុញ្ញាតឲ្យសួរ។ <កាន់តែសំខាន់បំផុតនោះគឺគាត់បាន>និយាយ<>អំពីការរៀបការ<ដោយការផ្សំផ្គុំ> ឬការរៀបការដោយបង្ខំ ហើយគាត់បញ្ជាក់ខ្លួនគាត់ថា ជាកម្មាភិបាលថ្នាក់ក្រោម គាត់អាចនឹងឆ្លើយសំណួរបែបនេះបាន ដើម្បីបញ្ជាក់ថា បើមានការរៀបការដោយបង្ខំ វាអាចជាការបំពានទៅលើសីលធម៌១២ប្រការ ត្រង់ប្រការ ទី៦។ <ដូច្នេះខ្ញុំគិតថា គួរតែអនុញ្ញាតឲ្យសួរសំណួរនេះលោកប្រធាន។>

[១៥:៣៣:០៨]

**ប្រធានអង្គជំនុំ៖**

ស្នើលោកមេធាវីកែសម្រួលសំណួរឡើងវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំនឹងព្យាយាម។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើសិនជាចង់ លោកចង់បញ្ជាក់ពីអ្វីដែលលោកចង់លើកឡើង គឺថាសូមលើក។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំចង់សួរបញ្ជាក់បន្ថែម ប៉ុន្តែខ្ញុំសូមសួរបែបនេះវិញលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកធ្លាប់ពិភាក្សាអំពីប្រការទី៦ អំពីជីវិតគ្រួសារជាមួយអ្នករួមការងារ ឬថ្នាក់លើរបស់លោកទេ ពីប្រការទី៦នេះ? តើ<លោកចាំថា>ធ្លាប់<បាន>ពិភាក្សាអំពីគោលការណ៍ អំពីជីវិតគ្រួសារអីទេ ក្នុងសម័យបដិវត្តន៍កាលនោះ?

**លោក សេង សឿន៖**

**ឆ៖** ខ្ញុំអត់បានចេះរឿងយ៉ាងម៉េចទេ ព្រោះដែលខ្ញុំមកជាប់រហូតប៉ុន្មានគឺច្បាំង។ ចប់ពីច្បាំងទៅខ្ញុំពិការ ទៅនៅមន្ទីរពិការរហូត ទៅនៅស្រុកស្អាងហ្នឹង រៀបការអីហ្នឹង ឃើញគេរៀបចាត់តាំងអីចឹងទៅ ក៏ឃើញអ៊ីចឹងទៅ ក៏ឲ្យខ្ញុំដឹង រៀបចំអីដែលប្រាកដប្រជាអីហ្នឹងគឺអត់ ជាផ្លូវការហ្នឹង គឺអត់មានទេខ្ញុំ ព្រោះដើបពីសង្គ្រាមទៅ មានដឹងរបៀបរបបអីណាប៉ុន្មានទេ មកនៅស្រុកស្អាងនេះ។

[១៥:៣៥:១៨]

**ស៖** ខ្ញុំព្យាយាមម្យ៉ាងទៀត តើរូបលោក ឬក៏នរណាម្នាក់នៅក្នុងថ្នាក់ស្រុក<ធ្លាប់ត្រូវបានគេ>ចោទប្រកាន់ថា បានបំពានលើប្រការទី៦ នៃប្រការនោះទេ?

**ឆ៖** អានេះក៏ខ្ញុំអត់ដឹងដែរ អារឿងប្រការអីៗដែលអស់លោកលើកឡើងមកនេះ ខ្ញុំមិនដឹងហើយក៏មិនយល់ទៀតផង។

**ស៖** មិនថ្វីទេ លោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមបន្តទៅមុខទៀត គឺសំណួរមួយចំនួនផ្សេងទៀត។ មុននឹងចូលទៅសំណួរទាំងនោះ ខ្ញុំចង់សួរលោកលើរឿងមួយ។ លោកបានផ្តល់សក្ខីកម្មថ្ងៃនេះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានន័យថា លោកយល់ថា ខ្លួនលោកជាជនរងគ្រោះនៃហេតុការណ៍ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហេតុអ្វីដែល<>នាំឲ្យលោកដាក់ពាក្យសុំធ្វើខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី? <ហេតុអ្វីបានជាលោកគិតថាលោកជាជនរងគ្រោះ?> ខ្ញុំសួរសំណួរបែបនេះ ដោយហេតុថា នៅថ្ងៃនេះនៅពេលដែលលោកផ្តល់ភស្តុតាង ហើយក៏ឃើញថា ចម្លើយរបស់លោក <ហាក់ដូចជាថា> លោកបានចូលរួមនៅក្នុងសកម្មភាព<បង្កើត>បញ្ជីជនជាតិវៀតណាម ហើយក្រោយមកគេយកជនជាតិវៀតណាមហ្នឹងទៅសម្លាប់។ អ៊ីចឹងសួរលោកថា ហេតុអ្វីក៏លោកសុំធ្វើ

ជាដើមបណ្ដឹងរដ្ឋប្បវេណី?

[១៥:៣៧:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំធ្វើការកត់សម្គាល់ ហើយអង្គជំនុំជម្រះជាអ្នកសម្រេចថា តើសំណួររបស់មេធាវី កូប៉េ ហ្នឹងមានលក្ខណៈសមស្រប ឬក៏អត់នៅក្នុងដំណាក់កាលនេះ? ខ្ញុំសូមរំឭកថា ការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីនេះ ត្រូវបានសម្រេចតាំងពីពេលដំណាក់កាលស៊ើបអង្កេតមកម្ល៉េះ ហើយគាត់ត្រូវបានទទួលយកនៅឆ្នាំ២០១០ ជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយសារតែគាត់បានបាត់បង់សមាជិកក្នុងគ្រួសារ ក្នុងក្របខ័ណ្ឌនៃការបោសសម្អាតផ្ទៃក្នុង។ ដូច្នេះមានន័យថា គាត់ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះជាអ្វីដែលបញ្ជាក់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះវាមិនមានឥទ្ធិពលអ្វីទៅលើអ្វីដែលគាត់បានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី គាត់មានឋានៈមួយដែលទទួលស្គាល់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយគាត់ត្រូវបានគេចាត់ទុកថា ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះខ្ញុំសូមជម្រាបជូនថា ឋានៈនេះត្រូវបានសម្រេចនៅឆ្នាំ២០១០ ដោយសហចៅក្រមស៊ើបអង្កេត។ ដូច្នេះបើអង្គជំនុំជម្រះយល់ថា សំណួររបស់មេធាវីការពារក្ដីអាចជួយដល់ការស្វែងរកការពិតនោះ ក៏ខ្ញុំគោរពទៅតាមការសម្រេចនេះដែរ។

[១៥:៣៩:០៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របទៅតាមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺជាសេចក្ដីសម្រេចទទួលយកដោយសហចៅក្រមស៊ើបអង្កេត ក៏ប៉ុន្តែផ្អែកលើសក្ខីកម្មរបស់គាត់ <ឃើញថាវាជាការសម្រេចមួយដ៏ចម្លែក> ប៉ុន្តែខ្ញុំនៅតែអាចសួរទៅគាត់ថា ហេតុអីគាត់ចាត់ទុកខ្លួនគាត់ថា ជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយគាត់ជាជនរងគ្រោះ?

ខ្ញុំគិតថា សំណួរមិនសូវសមស្រប ក៏ប៉ុន្តែគាត់គួរមានឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីហើយ ក៏គាត់អាចអះអាងបានដែរថា មូលហេតុដែលគាត់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ហេតុអ្វីក៏លោកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី? ហេតុអ្វីក៏ខ្លួនលោកចាត់ទុកថាជាជនរងគ្រោះនៅក្នុងរឿងក្ដីនេះ?

**លោក សេង សឿន៖**

**ឆ៖** បានជាខ្ញុំដាក់ពាក្យបណ្ដឹង ព្រោះបងថ្លៃខ្ញុំបីនាក់ មួយថាខាងភាគឧត្តរនេះ បម្រើទ័ពតាំង ៧១, ៧២ រហូត ១៧ មេសា មក។ មួយនៅកាន់វរសេនាតូចកង៩២០។ម្នាក់ទៀតធ្វើពេទ្យភូមិភាគឧត្តរ។ ម្នាក់ទៀតនៅកងពលនេះ មកកាន់ឃ្លាំងសាំង ១៧ មេសា មកនេះ តែត្រូវរបបនេះគាត់យក មិនមែនយកទេ សម្លាប់អស់ទៅ គឺជាបងថ្លៃប្រពន្ធខ្ញុំនេះ បងប្រពន្ធនេះ។ អ៊ីចឹងបានខ្ញុំវាតាំងធ្វើដើមបណ្ដឹងនោះ។

[១៥:៤១:២៤]

**ស៖** <តើ>បងថ្លៃប្រុស<របស់លោកទាំងអស់នោះ>ធ្វើជាកងទ័ពនៅក្នុងកងពលនៅភូមិភាគឧត្តរ<>ឬ?

**ឆ៖** បាទ នៅខាង គ្រាន់តែមួយពេទ្យ ពីរនោះទ័ព មានតំណែងត្រឹមវរសេនាតូច និងវរសេនាធំ។ ១៧ មេសា ហើយហ្នឹងណា បានរបបខ្មែរក្រហមនោះ ចាប់សម្លាប់នោះ ថាខ្មែរនេះ ខ្មែរនោះទៅ អស់បីនាក់ហ្នឹងតែម្ដង ប៉ុន្តែផ្សេងៗគ្នា។ អ៊ីចឹងបានរត់រកដំណឹងបានដឹង។

**ស៖**<>ខ្មែរក្បត់របស់<អ្នកណា>?

**ឆ៖** គេចោទថា ខ្លះថាខ្មែរយួន ខ្លះគេថាខ្មែរ សេ.អ៊ី.អា អី។ ខ្ញុំរកកំណត់ថា អ្នកណាឲ្យប្រាកដប្រជាមិនកើតដែរ តែគេថា ក្បត់ៗទៅ ឮតែគេថាអ៊ីចឹងដែរ។

**ស៖** យើងនឹងនិយាយមកពីបញ្ហាយួននេះម្ដងទៀត។ តើពួកគាត់មានទំនាក់ទំនងអ្វីជាមួយបុគ្គលម្នាក់ឈ្មោះ កុយ ធួន ហៅ ធុច ដែរឬទេ?

**ឆ៖** វាខុសគ្នាឆ្ងាយណាស់ ខ្ញុំមិនអាចនិយាយទេ ព្រោះខ្ញុំនៅឯណេះ គាត់នៅឯណោះ រកឆ្លើយមិនកើតទេ អត់ដឹង។

[១៥:៤៣:៣៥]

**ស៖** មូលហេតុដែលខ្ញុំសួរលោកអំពី កុយ ធួន នោះគឺថា ដោយហេតុលោកថា អាចនឹងផ្តល់សេចក្តីពន្យល់ អ៊ីចឹងខ្ញុំយោងខ្លឹមសារនៅក្នុងឯកសារ D22/3605/1, អង់គ្លេស ERN 00567556, បារាំង 00758000។ ខ្ញុំមិនមាន ERN ជាភាសាខ្មែរនៅពេលនេះទេ ប៉ុន្តែខ្ញុំនឹងជូនឆាប់ៗនេះ លោកប្រធាន។ លោកដើមបណ្តឹងបាននិយាយថា សុខ សាឡាញ ហៅ សមមិត្តត្រា ជាបងថ្លៃប្រុស<របស់លោក ហើយគាត់ធ្វើជាវេជ្ជបណ្ឌិតនៅភូមិភាគ៣០៤>ដែលដឹកនាំដោយ កុយ ធួន។ ហើយនៅខាងក្រោមនោះបន្តិច នៅឆ្នាំ១៩៧៧ ក្រោយពីខ្មែរក្រហមយក កុយ ធួន ហើយ សុខ សាឡាញ ក៏ខ្មែរក្រហមយកទៅ ក៏បាត់ខ្លួនដែរ។ អ៊ីចឹង<ហើយជាមូលហេតុដែលខ្ញុំសួរលោកអំពី កុយ ធួន នោះ។> តើលោកដឹងពីបងថ្លៃរបស់លោកថា មានទំនាក់ទំនងនឹង កុយ ធួន ហ្នឹងដឹងដោយរបៀបណា?

**ឆ៖** ខ្ញុំដឹងដំណឹង អ្នកនៅ គាត់ថានៅជួរជាមួយគ្នាពីកាលនោះ ហើយគេនៅមានរស់ទៅបានដឹងដំណឹងដល់ កាលហ្នឹងឪពុកក្មេកខ្ញុំគាត់នៅ ដឹងដំណឹង ក៏ស្រាវជ្រាវតាម ដឹងថាស្លាប់ហើយ។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែតើលោកអាចជម្រាបជូនតុលាការបានទេ ថាមានទំនាក់ទំនងអ្វីដែរទេរវាងខាងសាច់ថ្លៃរបស់លោកជាមួយនឹង កុយ ធួន?

**ឆ៖** ខ្ញុំអត់ដឹងទេ ប៉ុន្តែក្រុមគ្រួសារខ្ញុំទាំងមូលក៏មិនដែលស្គាល់ទេ នេះដល់គេជួរ ចូលជួរទៅ គេទាក់ទងស្គាល់គ្នាទៅបាន តែហ្នឹងទេ ឯប្អូនៗឪពុកអីនៅឯណោះ ក៏អត់ដែលស្គាល់ផងទេ ឈ្មោះ កុយ ធួន ហ្នឹង។

**ស៖** មិនជាថ្វីទេ។ ឥឡូវខ្ញុំបន្តទៅសួរអំពីការជាប់ទាក់ទងដែលថា សាច់ថ្លៃរបស់គ្រួសារលោកនេះអាចនឹងមាន គឺពាក់ព័ន្ធទៅនឹងវៀតណាម ឬក៏យួននេះ។ លោកបាននិយាយច្រើនមកហើយអំពីជនជាតិវៀតណាម តើលោកនៅចងចាំអ្វីខ្លះអំពីវៀតណាម? ខ្ញុំអត់និយាយអំពីប្រជាជនវៀតណាមដែលរស់នៅខាងក្នុងដែនដីកម្ពុជាប្រជាធិបតេយ្យនោះទេ ខ្ញុំសួរពីប្រទេសវៀតណាមតែម្តង ថាតើប្រទេសវៀត-ណាមមានមហិច្ឆតាយ៉ាងដូចម្តេចដែរពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យ?

[១៥:៤៧:៣០]

**ឆ៖** រឿងការងារប្រទេសហ្នឹង ខ្ញុំម៉េចនឹងដឹងគេ ខ្ញុំគ្រាន់កូនទាហានសម្រាប់តែឲ្យការពារទឹកដីច្បាំងតតាំងតែជាមួយយួនតែប៉ុណ្ណឹង ឲ្យដឹងរឿងអីលើសពីហ្នឹងទៀត ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំព្យាយាមជួយរំឭកដល់ការចងចាំរបស់លោកបន្តិច ឧទាហរណ៍ នៅក្នុងចម្លើយរបស់លោក<ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា> E3/5643 លោកបានឆ្លើយថា៖ "យួនចង់ត្រួតត្រាយើង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយយួនចង់ត្រួតត្រាបក្សកុម្មុយនីស្តឥណ្ឌូចិនទាំងមូលតែម្តង។" លោកនឹកឃើញទេ ថាលោកបានឆ្លើយយ៉ាងដូច្នេះទៅមជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** បាទ កាលហ្នឹងខ្ញុំ អើវាភ្លេចយូរហើយ ឥឡូវរំឭកអ៊ីចឹង ហ្នឹងបានខ្ញុំបាននិយាយ អាហ្នឹងនិយាយអំពីប្រាប់គេប្រាប់ឯង មានន័យថាអ្នកនេះដែរ ក៏ផែនការយួន តាមខ្ញុំការរៀនសូត្រពីរបប ប៉ុល ពត នេះគាត់ណែនាំផ្សព្វផ្សាយអ៊ីចឹង គឺយួន គេខំណាស់ដើម្បីអី? យកទឹកដីបីប្រទេសនេះធ្វើជាឥណ្ឌូចិនអាហ្នឹងខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ គ្រាន់តែស្នើសុំថា នៅពេលដែលមេធាវីដកស្រង់ សូមផ្តល់ ERN ឲ្យផងដើម្បីឲ្យយើងតាមទាន់។ ដូច្នេះសូមអរគុណលោកមេធាវី ប្រសិនណាជាលោកអាចផ្តល់លេខ ERN ឲ្យផង។

[១៥:៤៩:៣៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺទី១ ERN ជាភាសាអង់គ្លេស 00753835, ខ្មែរ 00059327, បារាំង 00756977។ សូមដកស្រង់៖ "<>យួនចង់ត្រួតត្រាយើង ក៏ប៉ុន្តែខាងភាគីយើងមិនយល់ព្រមទេ អ៊ីចឹងឯងបានជាមានជម្លោះកើតឡើង។" ហើយ ERN ជាភាសាអង់គ្លេស 00753825, ខ្មែរ 00059318, <បារាំង>គឺ <00756568> គឺដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយដូចតទៅ៖ "<ទោះជាយ៉ាងណា នៅពេលក្រោយមក> យួននេះ គឺថាចង់ត្រួតត្រាយើង <ហើយវាមានន័យថា> បក្សកុម្មុយនីស្តឥណ្ឌូចិន <ជាការបញ្ចូលគ្នារវាង>យួន <និង>ខ្មែរ ហើយអ៊ីចឹងឯងបានជា ប៉ុល ពត <ដកខ្លួនចេញពីបក្ស> ជ្រើសរើសយកឆ្នាំ ១៩៦០ ថាជាថ្ងៃកំណើតបក្ស។ <គាត់ដើរតាមផ្លូវរបស់គាត់ ហើយយួនដើរតាមផ្លូវរបស់វា។>"

ឥឡូវខ្ញុំសុំដកស្រង់សម្រង់តែមួយ៖ "ក្រោយ<មក> យួន<បាន>ខឹងចាប់តាំងពីពេលនោះមក យួនខឹងសម្បាមែនទែន។ នេះគឺវាពាក់ព័ន្ធទៅនឹងចលនាតស៊ូ គឺថាវែងឆ្ងាយណាស់ បើយើងនិយាយអំពីរឿងនេះ។" បញ្ចប់ការដកស្រង់។ តើលោកចាំទេថា លោកបានឆ្លើយយ៉ាងដូច្នេះជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា?

**លោក សេង សឿន៖**

**ឆ៖** បាននឹកឃើញហើយ ខ្ញុំបាននិយាយមែន។

**ស៖** ឥឡូវយើងនិយាយឲ្យច្រើនបន្តិច អំពីវៀតណាម ឬក៏យួនតាមដែលលោកហៅ។ តើលោកដឹងទេថា ក្នុងការអនុវត្តមហិច្ឆតានេះ វៀតណាមពេលខ្លះ គឺប្រើប្រាស់ប្រជាជនដែលរស់នៅខាងក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ១៩៧៥ ទៅដល់៧៩?

[១៥:៥២:១០]

**ឆ៖** ខ្ញុំដូចស្តាប់មិនទាន់ទេ។

**ស៖** អ៊ីចេះលោកបានយល់ស្របហើយ ថាលោកបានឆ្លើយថា យួនចង់ត្រួតត្រាយើង។ ហើយសំណួររបស់ខ្ញុំសួរថា តើលោកដឹងទេ ដើម្បីសម្រេចនូវគោលបំណងនេះបាន តើយួននេះមានប្រើជំនួយ ឬការជួយណាមួយពីប្រជាជនដែលរស់នៅខាងក្នុងប្រទេសកម្ពុជានាពេលនោះដែរឬទេ?

**ឆ៖** ខ្ញុំបាននិយាយមែន តែមិនសំអាងថា មានជំនួយពីប្រទេសខាងក្រៅអីណាទេ។ ខ្ញុំគ្រាន់តែនិយាយដឹងថា នេះជាគំនិតដែលមាគ៌ាដឹកនាំរបស់ ប៉ុល ពត ណែនាំផ្សព្វផ្សាយ រៀនសូត្រឲ្យខ្ញុំខាងក្រោមៗ យល់ដឹងពីរឿងយួន និងខ្មែរយើងតែប៉ុណ្ណឹងទេ។

**ស៖** បាទ ឥឡូវខ្ញុំសុំលើកឧទាហរណ៍ឲ្យបានច្បាស់លាស់បន្តិច។ ឧទាហរណ៍ ប្រជាជនដែលរស់នៅខាងក្នុងប្រទេសកម្ពុជា បានផ្គត់ផ្គង់ស្រូវអង្ករទៅវៀតណាម ឬក៏លាក់ទុកស្រូវអង្ករនៅកន្លែងពិសេសណាមួយ សម្រាប់ឲ្យកងទ័ពវៀតណាមហូបចុកនោះ លោកដឹងទេ?

**ឆ៖** ខ្ញុំអត់សូវដឹងទេ ព្រោះខ្ញុំនៅតែម្ខាងអ៊ីចេះ នៅតែទ័ព អស់ពីទ័ពហ្នឹង ពិការទៅ អត់សូវដឹងឮគេនិយាយដែរ ប៉ុន្តែយកជាការពិតអត់កើតដែរ។

[១៥:៥៤:១៧]

**ស៖** ខ្ញុំព្យាយាមសាកល្បងជួយរំឭកដល់ការចងចាំរបស់លោកម្តងទៀត។ ខ្ញុំយោងទៅលើERN អង់គ្លេសនៃចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ <E3/5643>, អង់គ្លេស 00753854, ខ្មែរ 00059348, បារាំង 00756596។ នេះគឺជាអ្វីដែលលោកបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំសួរលោកមើល៍ លោកចាំថាលោកពិតជាបានឆ្លើយយ៉ាងដូច្នេះដែរឬទេ? “ប្រជាជនយួន គឺថា<បានខ្ចីពី>កងនីមួយៗ។ <ពួកគេជាអ្នក>ដឹកជញ្ជូនស្រូវអង្ករទៅឲ្យយួន <ហើយពួកគេត្រូវបាន>គេរកឃើញ។ ពួកគេនេះ គឺថាធ្វើការឲ្យយួន។ ប្រជាជនទាំងនេះបានផ្តល់ស្រូវអង្ករទៅឲ្យយួន។

ខ្ញុំបានទៅស្រាវជ្រាវស៊ើបអង្កេតរឿងនេះ គឺពិតហើយ គេមានលាក់ទុកអង្ករនៅក្នុងព្រៃ ដើម្បីកុំឲ្យអ្នកដទៃទៀតដឹង។" បញ្ចប់ការដកស្រង់។ លោកដើមបណ្តឹងរដ្ឋប្បវេណី លោកចាំទេ ថាលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំមិនប្រកែកទេ ប៉ុន្តែខ្ញុំភ្លេចអស់ទៅហើយ ទាល់នឹកឃើញដែរ លើកឡើងមកនេះ។ ពេលនោះខ្ញុំបាន ពិតជានិយាយថាអ៊ីចឹងមែន រឿងខ្មែរយើង វាមានសែស្រឡាយទៅ គេយកស្រូវអង្ករលាក់ព្រៃអណ្ដែងចិញ្ចឹមកម្លាំងទ័ពរបស់យួនហ្នឹង។

**ស៖** នៅទំព័រដដែលនៃចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានឆ្លើយថា រឿងនេះគឺបានកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៨។ តើលោកដឹងទេ នៅពេលនោះមានសង្គ្រាមកើតឡើងរវាងកម្ពុជាប្រជាធិបតេយ្យជាមួយនឹងប្រទេសវៀតណាមនោះ លោកដឹងថាមានទេ?

**ឆ៖** ខ្ញុំដឹងថាខ្មែរ ហើយនិងយួន ត្រូវតែច្បាំងគ្នាតែរហូតហ្នឹង ព្រោះវាមិនសុខចិត្តទេ មានកម្លាំងវាច្រើន ប្រជាជនច្រើន ខ្ញុំបាននិយាយហើយតើ។

[១៥:៥៧:២២]

**ស៖** ខ្ញុំយល់ហើយ ខ្ញុំនឹងត្រឡប់មកសួរលោកអំពីចំណុចនេះនៅព្រឹកស្អែក។ ក៏ប៉ុន្តែលោកបានឆ្លើយថា លោកនេះបានចុះទៅស៊ើបអង្កេតអំពីការលាក់អង្ករទុកឲ្យយួន។ នៅពេលលោកទៅស៊ើបអង្កេតរឿងលាក់អង្ករនេះ តើលោកដឹងថាអំពើនេះ វាជាអំពើក្បត់ដែរឬទេ ជាអំពើក្បត់សហការជាមួយខ្មាំងដែរឬទេ? តើមានការណែនាំណាមួយដែរឬទេ?

**ឆ៖** រឿងនេះ ខ្ញុំអត់បានទៅស៊ើបអង្កេតដែររឿងអីហ្នឹងទេ តាមខ្ញុំដឹងក្នុងខ្លួនខ្ញុំ។ អត់មែនទៅតាមដាន ស៊ើបអង្កេតអារឿងថាគេលាក់ គេបំពួនអីជាមួយរបស់របរពី យកទៅឲ្យទាហានយួន ទ័ពយួនអីហ្នឹង ខ្ញុំគឺអត់មាននិយាយផង។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានភាពច្របូកច្របល់បន្តិច។ និយាយឲ្យត្រង់ទៅ លោកបាននិយាយ<ថា> "ខ្ញុំបានចុះទៅស៊ើបអង្កេតរឿងនេះ។ វាពិតណាស់ គឺថាមានគេលាក់អង្ករអ៊ីចឹងមែន គឺគេលាក់អង្ករនៅក្នុងព្រៃ ដើម្បីកុំឲ្យអ្នកដទៃទៀតដឹង។" បញ្ចប់ការដកស្រង់។ តើម៉េចទៅ លោកអាចបញ្ជាក់មូលហេតុបានទេ លោកពិតជាបានឆ្លើយអ៊ីចឹង ឬក៏អត់ទេ ត្រឹមត្រូវដែរអ៊ីចឹងទេ?

**ឆ៖** ទេ ខ្ញុំគិតទៅៗ អត់បាននិយាយអ៊ីចឹងទៅផង។ បានអីទៅដឹង ព្រោះខ្ញុំនៅតែណោះ មានណាទៅដឹង គេថាតែព្រំដែនទេអាហ្នឹង ហើយគេមានការងារអ៊ីចឹងទៅ ឯខ្ញុំនៅកណ្តាលប្រទេស អត់ដឹងទេ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ អ៊ីចឹងគឺថាលោកមិនបានចុះទៅស៊ើបអង្កេតរឿងនេះទេ អ៊ីចឹងឬក៏យ៉ាងណា?

[១៦:០០:០១]

**ឆ៖** បាទ អត់បានទៅស៊ើប ទៅអង្កេតអីផង។ គ្មានភារកិច្ចអីទេខ្ញុំនោះ នៅតែមន្ទីរហ្នឹង។

**ស៖** ឥឡូវទុកបញ្ហានេះមួយអន្លើសិនចុះ ថាតើលោកបានស៊ើបអង្កេត ឬក៏អត់នោះ។ ប៉ុន្តែតើត្រឹមត្រូវដែរឬទេ ដែលថា មានប្រជាជនលាក់ទុកអង្ករនៅកន្លែងពិសេសៗមួយចំនួនសម្រាប់ឲ្យកងទ័ពវៀតណាម តើមានអ៊ីចឹងទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបថា ខ្ញុំអត់ ដូចថាមិនមែនចងចាំ ថាមិនដឹងតែម្តង ព្រោះអត់ការងារអីខ្ញុំទៅហ្នឹងទេ ខ្ញុំនៅតែខាងស្រុកស្អាងនេះ ខ្ញុំមកបានមិនពេញ១ខែស្រួលបួលផង។ ហើយនៅក្រចេះ ខ្ញុំនៅតែមន្ទីរពិការ មន្ទីរពិការតំបន់១៣ មកភូមិភាគ។ រឿងអីខ្ញុំទៅដឹង ទៅស៊ើបការណ៍អីអារឿងលក់អង្ករលក់ស្រូវអីណា ខ្ញុំអត់ដឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថា សមល្មមនឹងចប់ថ្ងៃ<នេះ>សិនហើយ ខ្ញុំនឹងបន្តសួរថ្ងៃស្អែកទៀត។

[១៦:០១:៣៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី៣០ ខែសីហា ឆ្នាំ២០១៦ ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-219 បញ្ចប់ ហើយនិងសក្ខីកម្ម -- ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-286។

អង្គជំនុំជម្រះអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ដំណើរការស្តាប់សក្ខីកម្មរបស់លោកនៅពេលនេះ មិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ក្នុងការជូនលោកដើមបណ្តឹងរដ្ឋប្បវេណីវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យ

អញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅបន្ទប់សវនាការនេះវិញ នៅថ្ងៃទី -- ថ្ងៃអង្គារ ទី៣០ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីរត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*